# មេរៀនចេតសិក និង ចិត្ត

## អមដោយវីដេអូ

ផស្សៈ
វេទនា
សញ្ញា
ចេតនា
ឯកគ្គតា
ជីវិតិន្ទ្រីយ៍
មនសិការ



បង្រៀនដោយ

**ភិក្ខុវជិរប្បញ្ញោ សាន សុជា**

វត្តសមណគោតមារាម

ប្រទេសអូស្ត្រាលី ព.ស. ២៥៦៤ គ.ស. ២០២០

ស្កេនវេបសាយ
Scan QR Code

Playlists
Scan QR Code


អាយុរូបមួយ (អារម្មណ៍) ស្មើ ១៧ ខណៈចិត្ត
ចក្ខុ
សោ
ឃា
ជី
កា
វិថីចិត្តតាមបញ្ចទ្វារ
អ ច ទ អា ឃា ស តី វ ជ ជ ជ ជ ជ ជ ជ ទា ទា ភ ភ
វិថីចិត្តតាមមនោទ្វារ
ច ទ ម ជ ជ ជ ជ ជ ជ ជ ទា ទា ភ ភ

# ពាក្យប្រារព្ធ

សូមប្រគេន និងជម្រាបដល់សិក្ខាកាមទាំងឡាយថា នេះគឺជាអត្ថបទមេរៀនដែលខ្ញុំបានបង្រៀនសារឡើងវិញនូវមេរៀន**ចេតសិក** បូករួមនឹង**ចិត្ត** ក្នុងអំឡុងពេលដែលខ្ញុំកំពុងស្នាក់នៅក្នុង**វត្តសមណគោតមារាម** ប្រទេសអូស្ត្រាលី។ កាលពីពេលចាប់ផ្តើមបង្រៀនដំបូង មានសិក្ខាកាមមួយចំនួនបានអញ្ជើញមកចូលរួមរៀនដោយផ្ទាល់ លុះដល់ពេលមានមេរោគកូវីដ-១៩កើតឡើង ថ្នាក់រៀននេះត្រូវបានផ្អាកជាបណ្តោះអាសន្ន។ ក្រោយពីបានផ្អាកមួយរយៈធំ និងយល់ឃើញថា ស្ថានភាពនៃមេរោគនឹងមិនងាយស្ងប់ទៅវិញ ទើបសម្រេចចិត្តបន្តបង្រៀនតាមប្រព័ន្ធសង្គម (Zoom) រហូតដល់ចប់។

ស្មេរយល់ឃើញថា អត្ថបទនេះនឹងផ្តល់នូវភាពងាយស្រួលយ៉ាងច្រើនដល់អ្នកដែលមានបំណងចង់សិក្សាមេរៀនព្រះអភិធម្មថ្នាក់ដំបូង ដោយក្នុងនោះមានការចង្អុលបង្ហាញប្រាប់លេខរៀងវីដេអូនៃការបង្រៀនរបស់ខ្ញុំនោះតែម្តង អ្នកសិក្សាមិនចាំបាច់ចំណាយពេលក្នុងការស្វែងរក វីដេអូមេរៀនត្រង់កន្លែងដែលខ្លួនចង់សិក្សាឡើយ។



ជាថ្មីម្តងទៀត សូមជម្រាបសិក្ខាកាមទាំងឡាយថា អត្ថបទនៅក្នុងសៀវភៅនេះ អ្នកសិក្សាថ្មីៗ មិនអាចនឹងយល់ដោយហេតុត្រឹមតែអាននោះទេ គឺត្រូវទស្សនាវីដេអូនៃការបង្រៀនផងទើបអាចយល់បាន។ រីឯវីដេអូ ក្រុមការងារធម្មទានបានផ្សាយរួចជាស្រេចនៅលើ YouTube របស់ខ្ញុំ ឈ្មោះថា San Sochea Official ត្រង់បញ្ជីមាតិកា ឈ្មោះថា ***មេរៀនចេតសិកនិងចិត្ត (កាត់តរួច)***។

*វត្តសមណគោតមារាម រដ្ឋវិចតូរីយ៉ា ប្រទេសអូស្ត្រាលី*

*ថ្ងៃ ១២រោច ខែមាឃ ឆ្នាំជូត ទោស័ក ពស ២៥៦៤*

*ត្រូវនឹងថ្ងៃអង្គារ ទី៩ ខែកុម្ភៈ ឆ្នាំ ២០២០*

*ភិក្ខុវជិរប្បញ្ញោ* ***សាន សុជា***

# បញ្ជីមាតិកាធម៌


| លរ. | | ទំព័រ |
|---|---|---|
| ១- របៀបអានភាសាបាលី | ..................................... | ១ |
| ២- ពាក្យថា បរមត្ថធម៌ | ..................................... | ១១ |
| ៣- ចេតសិកបរមត្ថ | ..................................... | ១៣ |
| ៤- ចេតសិក ៥២ | ..................................... | ១៧ |
| ៥-សព្វចិត្តសាធារណចេតសិក ផស្សចេតសិក | ..................................... | ១៩ |
| ៦- វេទនាចេតសិក | ..................................... | ២១ |
| ៧- សញ្ញាចេតសិក | ..................................... | ២៩ |
| ៨- ចេតនាចេតសិក | ..................................... | ៣១ |
| ៩- ឯកគ្គតាចេតសិក | ..................................... | ៣៣ |
| ១០- ជីវិតិន្ទ្រិយចេតសិក | ..................................... | ៣៥ |
| ១១- មនសិការចេតសិក | ..................................... | ៣៧ |
| ១២- ចែកសព្វចិត្តសាធារណចេតសិក ៧ ដោយន័យផ្សេងៗគ្នា | ................... | ៤១ |
| ១៣- បកិណ្ណកចេតសិក វិតក្កចេតសិក | ..................................... | ៤៤ |
| ១៤- វិចារចេតសិក | ..................................... | ៤៦ |





| | | |
|---|---|---|
| ១៥- អធិមោក្ខចេតសិក | ..................................... | ៤៨ |
| ១៦- វីរិយចេតសិក | ..................................... | ៥០ |
| ១៧- បីតិចេតសិក | ..................................... | ៥៣ |
| ១៨- ឆន្ទចេតសិក | ..................................... | ៥៦ |
| ១៩- អធិប្បាយអកុសលចេតសិក ១៤ | ..................................... | ៦០ |
| ២០- មោហចេតសិក | ..................................... | ៦៣ |
| ២១- អហិរិកចេតសិក | ..................................... | ៦៦ |
| ២២- អនោត្តប្បចេតសិក | ..................................... | ៦៨ |
| ២៣- ឧទ្ធច្ចចេតសិក | ..................................... | ៧០ |
| ២៤- លោភចេតសិក | ..................................... | ៧២ |
| ២៥- ទិដ្ឋិចេតសិក | ..................................... | ៧៥ |
| ២៦- មានចេតសិក | ..................................... | ៧៨ |
| ២៧- ទោសចេតសិក | ..................................... | ៨៣ |
| ២៨- ឥស្សាចេតសិក | ..................................... | ៨៧ |
| ២៩- មច្ឆរិយចេតសិក | ..................................... | ៨៩ |
| ៣០- កុក្កុច្ចចេតសិក | ..................................... | ៩២ |

៣១- ថីនចេតសិក ........................................ ៩៤
៣២- មិទ្ធចេតសិក ........................................ ៩៦
៣៣- វិចិកិច្ឆាចេតសិក ........................................ ៩៩
៣៤- សោភណចេតសិក ២៥ ........................................ ១០៤
៣៥- សទ្ធាចេតសិក ........................................ ១០៥
៣៦- សតិចេតសិក ........................................ ១១០
៣៧- ហិរិចេតសិក ........................................ ១១៤
៣៨- ឱត្តប្បចេតសិក ........................................ ១១៦
៣៩- អលោភចេតសិក ........................................ ១១៩
៤០- អទោសចេតសិក ........................................ ១២១
៤១- តត្រមជ្ឈត្តតាចេតសិក ........................................ ១២៣
៤២- យុគលធម៌ ៦គូ យុគលធម៌គូទី ១ ........................................ ១២៦
៤៣- យុគលធម៌គូទី ២ ........................................ ១២៨
៤៤- យុគលធម៌គូទី ៣ ........................................ ១៣០
៤៥- យុគលធម៌គូទី ៤ ........................................ ១៣២



៤៦- យុគលធម៌គូទី ៥ ........................................ ១៣៤
៤៧- យុគលធម៌គូទី ៦ ........................................ ១៣៦
៤៨- វិរតិចេតសិក ៣ ........................................ ១៣៨
៤៩- សម្មាវាចាចេតសិក ........................................ ១៣៩
៥០- សម្មាកម្មន្តចេតសិក ........................................ ១៤២
៥១- សម្មាអាជីវចេតសិក ........................................ ១៤៤
៥២- អប្បមញ្ញាចេតសិក ២ ........................................ ១៤៨
៥៣- ករុណាចេតសិក ........................................ ១៤៩
៥៤- មុទិតាចេតសិក ........................................ ១៥២
៥៥- បញ្ញិន្ទ្រិយចេតសិក ១ ........................................ ១៥៦
៥៦- ការរួបរួមចេតសិកចូលជាមួយនឹងចិត្ត ........................................ ១៦០
៥៧- ចិត្តមាន៤ប្រភេទ ........................................ ១៦១
៥៨- កាមាវចរចិត្ត ........................................ ១៦២
៥៩- លោភមូលចិត្ត ៨ ដួង ........................................ ១៦៤
៦០- ទោសមូលចិត្ត ២ ដួង ........................................ ១៩១

៦១- មោហមូលចិត្ត ២ ដួង ........................................ ២០១
៦២- សម្បយោគន័យ ........................................ ២១៣
៦៣- អកុសលកម្មបថ ១០ ........................................ ២១៨
៦៤- វិនិច្ឆ័យបាណាតិបាត ........................................ ២២១
៦៥- វិនិច្ឆ័យអទិន្នាទាន ........................................ ២២៨
៦៦- វិនិច្ឆ័យកាមេសុមិច្ឆាចារ ........................................ ២៣៣
៦៧- វិនិច្ឆ័យមុសាវាទ ........................................ ២៣៥
៦៨- វិនិច្ឆ័យបិសុណាវាទ ........................................ ២៣៨
៦៩- វិនិច្ឆ័យផរុសវាទ ........................................ ២៤១
៧០- វិនិច្ឆ័យសម្ផប្បលាបវាទ ........................................ ២៤៤
៧១- វិនិច្ឆ័យអភិជ្ឈា ........................................ ២៤៨
៧២- វិនិច្ឆ័យព្យាបាទ ........................................ ២៥១
៧៣- វិនិច្ឆ័យមិច្ឆាទិដ្ឋិ ........................................ ២៥៤
៧៤- កាមាវចរសោភណចិត្ត ២៤ ........................................ ២៥៨
៧៥- មហាកុសលចិត្ត ៨ ដួង ........................................ ២៥៩





៧៦- អត្ថរបស់កុសល ៥ យ៉ាង ................................ ២៧១
៧៧- បុញ្ញកិរិយាវត្ថុ ១០ ................................ ២៧៤
៧៨- សម័យនៃមហាកុសល ៥ យ៉ាង ................................ ២៧៧
៧៩- វត្ថុជាទីសប្បាយនៃមហាកុសល ................................ ២៧៩
៨០- ការចែកមហាកុសលចិត្តដោយឧក្កដ្ឋៈ និងឱមកៈ ................................ ២៨០
៨១- អហេតុកចិត្ត ១៨ ដួង ................................ ២៨៥
៨២- អកុសលវិបាកចិត្ត ៧ ដួង ................................ ២៨៦
៨៣- អហេតុកកុសលវិបាកចិត្ត ៨ ដួង ................................ ៣០៩
៨៤- អារម្មណ៍ ២ យ៉ាង ................................ ៣២៧
៨៥- ប្រៀបធៀបអកុសលវិបាក និងអហេតុកកុសលវិបាក ................................ ៣២៨
៨៦- អហេតុកកិរិយាចិត្ត ៣ ដួង ................................ ៣២៩
៨៧- សង្គហន័យនៃអហេតុកចិត្ត ១៨ ................................ ៣៤០
៨៨- ការចែកអសោភណចិត្ត ៣០ ដោយន័យផ្សេងៗ ................................ ៣៤២
៨៩- គាថាសង្គហអហេតុកចិត្ត ................................ ៣៤៧
៩០- សោភណចិត្ត ៥៩ ឬ ៩១ ដួង ................................ ៣៤៨

៩១- កាមាវចរសោភណចិត្ត ២៤ ដួង ................................ ៤៣៩
៩២- ការចែកមហាកុសលចិត្ត ៨ ដួងដោយន័យផ្សេង ៗ ................................ ៣៥១
៩៣- មហាវិបាកចិត្ត ៨ ដួង ................................ ៣៥៣
៩៤- អានិសង្សរបស់តិហេតុកកុសល ................................ ៣៦៥
៩៥- អានិសង្សរបស់ទុហេតុកកុសល ................................ ៣៦៩
៩៦- កុសលឱ្យផលផ្សេង ៗ គ្នា ៧ យ៉ាង ................................ ៣៧៣
៩៧- ការចែកមហាវិបាកចិត្ត ៨ ដួងដោយន័យផ្សេង ៗ ................................ ៣៧៤
៩៨- មហាវិបាកចិត្ត ៨ ដួង មានឈ្មោះច្រើនយ៉ាង ................................ ៣៧៦
៩៩- កាមាវចរវិបាកចិត្តទាំងអស់មាន ២៣ ដួង ................................ ៣៧៧
១០០- មហាកិរិយាចិត្ត ៨ ដួង ................................ ៣៧៨
១០១- មហាកិរិយាចិត្ត ៨ ដួងមានឈ្មោះហៅច្រើនយ៉ាង ................................ ៣៩០
១០២- ការចែកមហាកិរិយាចិត្ត ៨ ដួងដោយន័យផ្សេង ៗ ................................ ៣៩១
១០៣- សរុបកាមាវចរចិត្ត ៥៤ ដួង ................................ ៣៩៣
១០៤- រូបាវចរឈានចិត្ត ១៥ ដួង ................................ ៣៩៤
១០៥- រូបាវចរកុសលចិត្ត ៥ ដួង ................................ ៣៩៦



១០៦- ប្រៀបធៀបបីតិ និងសុខ ................................ ៤២២
១០៧- សមាធិ ៣ យ៉ាង ................................ ៤២៤
១០៨- ការចែករូបាវចរកុសលចិត្ត ៥ ដួងដោយន័យផ្សេង ៗ ................................ ៤២៥
១០៩- រូបាវចរវិបាកចិត្ត ៥ ដួង ................................ ៤២៧
១១០- បញ្ចកន័យ និងចតុក្កន័យ ................................ ៤៣៩
១១១- ការចែករូបាវចរវិបាកចិត្ត ៥ ដួងដោយន័យផ្សេង ៗ ................................ ៤៤០
១១២- រូបាវចរកិរិយាចិត្ត ៥ ដួង ................................ ៤៤២
១១៣- ការចែករូបាវចរកិរិយាចិត្ត ៥ ដួងដោយន័យផ្សេង ៗ ................................ ៤៤៩
១១៤- អរូបាវចរកុសលចិត្ត ៤ ដួង ................................ ៤៥១
១១៥- អាកាសមាន ៤ ប្រការ ................................ ៤៥៤
១១៦- អរូបាវចរវិបាកចិត្ត ៤ ដួង ................................ ៤៦៧
១១៧- អរូបាវចរកិរិយាចិត្ត ៤ ដួង ................................ ៤៧១
១១៨- ការចែកអរូបាវចរចិត្ត ១២ ដួងដោយន័យផ្សេង ៗ ................................ ៤៧៦
១១៩- លោកុត្តរសោភណចិត្ត ៨ ដួង ................................ ៤៧៩
១២០- លោកុត្តរកុសលចិត្ត ៤ ដួង ................................ ៤៨១

១២១- ការឆ្លងផុតលោក ............................ ៤៨៨
១២២- អកុសលធម៌ ៩ កង ............................ ៤៩៦
១២៣- មគ្គចិត្តលះអកុសលធម៌ ៩ កង ............................ ៤៩៨
១២៤- មគ្គចិត្តលះអកុសលចិត្ត១២ដួង ............................ ៥០២
១២៥- មគ្គចិត្តលះអកុសលកម្មបថ ១០ ............................ ៥០៣
១២៦- ព្រះសោតាបន្ន ៣ ប្រភេទ ............................ ៥០៤
១២៧- ព្រះសកទាគាមី ៥ ប្រភេទ ............................ ៥០៥
១២៨- ព្រះអនាគាមី ៥ ប្រភេទ ............................ ៥០៦
១២៩- ព្រះអរហន្ត ២ ប្រភេទ ............................ ៥០៨
១៣០- បច្ចវេក្ខណវិថី ១៩ វារៈ ............................ ៥០៩
១៣១- លោកុត្តរវិបាកចិត្ត ៤ ដួង ............................ ៥១៥
១៣២- លោកុត្តរចិត្តបែបពិស្តារ ............................ ៥១៩
១៣៣-ចេតសិកសម្បយុត្តជាមួយលោកុត្តរឈានចិត្តទាំង ៤០ ដួង .................... ៥២៣
១៣៤- ការចែកលោកុត្តរចិត្ត ៨ ដួងដោយន័យផ្សេង ៗ ............................ ៥២៨
១៣៥- ការចែកចិត្ត ៨៩ ឬ ១២១ ដួងដោយន័យផ្សេង ៗ ............................ ៥៣០

ដឹ

១៣៦- សម្បយោគដោយពិស្តារ មាន ១៦ ន័យ ............................ ៥៣៧
១៣៧- អកុសចេតសិក ១៤ ប្រកបជាមួយអកុសលចិត្ត ១២ ........................ ៥៤៧
១៣៨- សោភណចេតសិក ២៥ ប្រកបជាមួយសោភណចិត្ត ៥៩ ឬ ៩១ ដួង ...... ៥៤៨
១៣៨- អនិយតយោគីចេតសិក និង និយតយោគីចេតសិក ........................ ៥៥៣
១៣៩- នានាកទាចិចេតសិក ............................ ៥៥៤
១៤០- កទាចិចេតសិក ............................ ៥៥៥
១៤១- សហកទាចិចេតសិក ............................ ៥៥៦

មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ១

# របៀបអានភាសាបាលី

ស្កេនដើម្បីមើលមេរៀន

San Sochea Official



~១~

## អក្ខរវិធី

**អក្ខរៈ (អក្សរ) ក្នុងភាសាបាលី**

**មាន ៤១ តួ**

**ស្រៈ មាន ៨ តួ គឺ**

**ស្រៈពេញតួ អ** អានថា អាក់ ឬ អៈ

**អា** អានថា អា

**ឥ** អានថា អ៊ិ

**ឦ** អានថា អ៊ី

**ឧ** អានថា អ៊ុ

~២~

**ឩ** អានថា អ៊ូ

**ឯ** អានថា អេ

**ឱ** អានថា អោ

**ព្យញ្ជនៈមាន ៣៣ តួ គឺ**

**ក** អានថា កាក់ ឬ កៈ

**ខ** អានថា ខាក់ ឬ ខៈ

**គ** អានថា គាក់ ឬ គៈ

**ឃ** អានថា ឃាក់ ឬ ឃៈ

**ង** អានថា ងាក់ ឬ ងៈ

~៣~

| | | |
|---|---|---|
| ច | អានថា | ចាក់ ឬ ចះ |
| ឆ | អានថា | ឆាក់ ឬ ឆះ |
| ជ | អានថា | ជាក់ ឬ ជះ |
| ឈ | អានថា | ឈាក់ឬ ឈះ |
| ញ | អានថា | ញាក់ ឬ ញះ |
| ដ | អានថា | ដាក់ ឬ ដះ |
| ឋ | អានថា | ឋាក់ ឬ ឋះ |
| ឌ | អានថា | ឌាក់ ឬ ឌះ |
| ឍ | អានថា | ឍាក់ ឬ ឍះ |
| ណ | អានថា | ណាក់ឬ ណះ |

~៤~

| | | |
|---|---|---|
| ត | អានថា | តាក់ ឬ តះ |
| ថ | អានថា | ថាក់ ឬ ថះ |
| ទ | អានថា | ទាក់ ឬ ទះ |
| ធ | អានថា | ធាក់ ឬ ធះ |
| ន | អានថា | នាក់ ឬ នះ |
| ប | អានថា | ប៉ាក់ ឬ ប៉ះ |
| ផ | អានថា | ផាក់ ឬ ផះ |
| ព | អានថា | ពាក់ ឬ ពះ |
| ភ | អានថា | ភាក់ ឬ ភះ |
| ម | អានថា | មាក់ ឬ មះ |



~៥~

| | | |
|---|---|---|
| យ | អានថា | យាក់ ឬ យះ |
| រ | អានថា | រាក់ ឬ រះ |
| ល | អានថា | លាក់ ឬ លះ |
| វ | អានថា | វាក់ ឬ វះ |
| ស | អានថា | សាក់ ឬ សះ |
| ហ | អានថា | ហាក់ ឬ ហះ |
| ឡ | អានថា | ឡាក់ ឬ ឡះ |
| ំ | អានថា | អាំង |

~៦~

## ស្រៈទាំង០៨តួ កាលប្រើជាស្រៈនិស្ស័យ

### មានរូបដូច្នេះ

អ > | ផ្សំនឹងព្យញ្ជនៈក ទៅជា ក[១]

អា > -ា ផ្សំនឹងព្យញ្ជនៈក ទៅជា កា

ឥ > -ិ ផ្សំនឹងព្យញ្ជនៈក ទៅជា កិ

ឦ > -ី ផ្សំនឹងព្យញ្ជនៈក ទៅជា កី

ឧ > -ុ ផ្សំនឹងព្យញ្ជនៈក ទៅជា កុ

ឩ > -ូ ផ្សំនឹងព្យញ្ជនៈក ទៅជា កូ

ឯ > េ- ផ្សំនឹងព្យញ្ជនៈក ទៅជា កេ

ឱ > េ-ា ផ្សំនឹងព្យញ្ជនៈក ទៅជា កោ

(១) អានថា កាក់ ឬ កះ

## ស្រះចែកចេញជាពីរប្រភេទ

### ១~ស្រះរស្សៈ (សម្លេងខ្លី) មាន ៣ គឺ

**អ　　ឥ　　ឧ**

ា　　ិ　　ុ

ស្រះទាំង៣តួនេះ ទោះនៅជាស្រះពេញតួក្តី ក្លាយទៅជាស្រះនិស្ស័យក្តី ពេលអាន ត្រូវមានសម្លេងខ្លី ៗ ។

ឧទាហរណ៍ **អ**វិជ្ជា, **ព**ហូ, **ឥ**ទានិ, **ឥ**ន្ទុគ្គោ,



**ឧ**ទបាទិ, **សុ**ភាសិតា ..... ។

### ២~ស្រះទីឃៈ (សម្លេងវែង) មាន ៥ គឺ

**អា　　ឦ　　ឩ　　ឯ　　ឱ**

-ា　　-ី　　-ូ　　េ-　　េ-ា

ស្រះទាំង៥តួនេះ ទោះនៅជាស្រះពេញតួក្តី ក្លាយទៅជាស្រះនិស្ស័យក្តី ពេលអាន ត្រូវមានសម្លេងវែង ៗ។

ឧទាហរណ៍ **អា**ចរិយំ, អ**គា**រំ, **ឦ**ទិសោ,





**ឦ**ណិ, **ឩ**មិ, **ឩ**រតោ, **ឯ**កតោ, **ឯ**ទេសុ, **ឱ**កិរតុ, **សោ**ភណំ .... ។

## ឃោសាឃោសៈ

### អឃោសៈ

ព្យញ្ជនៈអឃោសៈមាន ១១ តួ គឺ **ក ខ ច ឆ ដ ឋ ត ថ ប ផ** និង **ស**។

ព្យញ្ជនៈអឃោសៈទាំង ១១ តួនេះ ជាព្យញ្ជនៈមានសម្លេងមិនគឹកកង មិនថាស្ថិតនៅខាងមុខ ឬខាងក្រោយព្យញ្ជនៈណាក៏ដោយ ក៏មិន



ដែលប្រែសម្លេង ទៅតាមព្យញ្ជនៈដទៃទេគឺនៅតែរក្សាសម្លេងជាអឃោសៈដដែល ដូចជា **វាចា** អានថា វ៉ាចា គឺថា **ចា** មិនមែនក្លាយទៅជាមានសម្លេង **ជា** តាមអំណាច **វា** ឡើយ ហើយថែមទាំងអាចទាញសម្លេង ព្យញ្ជនៈឃោសៈខ្លះឱ្យដួលទៅតាមខ្លួនទៀតផង ដូចជា **ករោតុ** អានថា កៈ <u>រ៉ោ</u> តុ, **ខមាបេថ** អានថា ខៈ <u>ម៉ា</u> ប៉េ ថៈ, **ចរណំ** អានថា ចៈ <u>រ៉ៈ</u> ណាំង, .... ជាដើម ។

-១១-

## ឃោសៈ

ព្យញ្ជនៈឃោសៈមាន ២១ តួ គឺ **គ ឃ ង ជ ឈ ញ ឌ ឍ ណ ទ ធ ន ព ភ ម យ រ ល វ ហ ឡ** ។

### ព្យញ្ជនៈឃោសៈមាន ២ យ៉ាង

### ១-ឃោសៈប្រែប្រួល

ព្យញ្ជនៈឃោសៈ ១១ តួ គឺ **ង ញ ណ ន ម យ រ ល វ ហ ឡ** តែងមានការប្រែប្រួលទៅជាមានសម្លេងមិនគឹកកង នៅពេលដែលមានព្យញ្ជនៈអឃោសៈ នៅខាងដើម

-១២-

ដូចជា **បមាណំ** តាមសម្លេងដើម គួរអានថា ប៉ះ មា ណាំង ប៉ុន្តែដោយសារមាន **ប** ដែលជាអឃោសៈ នៅខាងដើម ក៏ត្រឡប់ទៅជាអានថា ប៉ះ ម៉ា ណាំង ដូច្នេះវិញជាដើម ។

### ២-ឃោសៈមិនប្រែប្រួល

ព្យញ្ជនៈឃោសៈ ១០ តួ គឺ **គ ឃ ជ ឈ ឌ ឍ ទ ធ ព ភ** ទាំង ១០ តួនេះ ជាព្យញ្ជនៈរឹង មិនចេះប្រែប្រួលសម្លេងទៅតាមការអូសទាញរបស់ព្យញ្ជនៈដទៃឡើយ ទោះបីមានព្យញ្ជនៈអឃោសៈ នៅខាងដើមក៏ដោយ ដូចជា



-១៣-

**កទាចិ** នៅតែមានសម្លេងថា កៈ ទា ចិ មិនមែនក្លាយទៅជាមានសម្លេង កៈ តា ចិ តាមអំណាច **ក** នៅខាងដើម ដូច្នេះជាដើមឡើយ ។

## ព្យញ្ជនៈសំយោគ

ព្យញ្ជនៈសំយោគ គឺជាព្យញ្ជនៈតម្រួត ពេលអានត្រូវតែសង្កត់ ហើយមានសម្លេងធ្ងន់ យូរប្រហាក់ប្រហែលនឹងស្រះទីឃៈដែរ ដូចជា **សត្តធា** អានថា សាត់ (សង្កត់-យូរ) តៈ ធា, **សម្មាសតិ** អានថា សាំ (សង្កត់-យូរ) ម៉ា សៈ តិ ............។

-១៤-

## និគ្គហិត

ព្យញ្ជនៈគឺ ំ នេះ តែងតែអាស្រ័យនៅលើព្យញ្ជនៈ ឬស្រៈ ហើយមានសម្លេងធ្ងន់យូរដូចសំយោគដែរ ដូចជា **ពុទ្ធំ** អានថា ពុត ធាំង (សង្កត់-យូរ) ដូច្នេះជាដើម ។

~១៥~

## របៀបអាន

## សុបដិបន្លានិគុណសំយុត្តំ

សុ ប៉ះ ដិ ប៉ាន់ ណា ទិ គុ ណះ សាំង យុត តាំង

រស្សៈ ទីឃៈ សំយោគ និគ្គហិត

ខ្លីស្រាល វែង សង្កត់យូរ

~១៦~

## កំណត់ចំណាំបន្ថែម

ចំពោះស្រះទីឃៈ ៣ តួ គឺ **អា ឯ ឱ** ប្រសិនបើមានព្យញ្ជនៈតម្រួតគ្នា ២ តួនៅខាងចុង បែរជាមានសូរខ្លីដូចជារស្សៈទៅវិញ ដូចជា

អេត តះ កាំង = ខុស

អេត់ តះ កាំង = ត្រូវ

**អាត្តំ** **ឯត្តកំ** **ឱដ្ឋោ**

**ស្វាក្ខាតោ** **តេត្តឹស** **ហោន្តិ**

ស្វាក់ ខា តោ = ត្រូវ

ស្វាក ខា តោ = ខុស

ហោន់ តិ = ត្រូវ

ហោន តិ = ខុស

# សិក្សាព្រះអភិធម្ម



មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ២

# បរមត្ថធម៌

ពាក្យថា បរមត្ថ មកពី បរម + អត្ថ = បរមត្ថ

បរម ប្រែថា ប្រសើរ ខ្ពង់ខ្ពស់ មិនវិបរិត

អត្ថ ប្រែថា អត្ថ សេចក្តី ឬន័យ

រួមពាក្យទាំងពីរចូលគ្នា បានជា បរមត្ថ ប្រែថា អត្ថ ឬសេចក្តីដ៏ប្រសើរ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# បរមត្ថធម៌ មាន ៤ គឺ ៖

| | |
|---|---|
| ១- ចិត្តបរមត្ថ | បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង |
| ២- ចេតសិកបរមត្ថ | បានដល់ ចេតសិក ៥២ |
| ៣- រូបបរមត្ថ | បានដល់ រូប ២៨ |
| ៤- និព្វានបរមត្ថ | បានដល់ ព្រះនិព្វាន |



# ចេតសិកបរមត្ថ

## បរិច្ឆេទទី ២

ចេតសិក គឺជាធម៌ដែលកើតឡើងអាស្រ័យនឹងចិត្ត ឬថាជាធម៌ប្រកបជាមួយនឹងចិត្ត ប្រៀបដូចសិស្សនិងគ្រូ ដែលត្រូវអាស្រ័យគ្នា ទើបអាចញុំាងថ្នាក់រៀនមួយឲ្យប្រព្រឹត្តទៅបាន។

ដូចមានវិគ្គហៈ ថា ៖

ចេតសិ ភវំ ចេតសិកំ វា ចេតសិ និយុត្តំ = ចេតសិកំ ធម្មជាតិកើត ក្នុងចិត្ត ឬប្រកបក្នុងចិត្ត ឈ្មោះថា ចេតសិក។

ចេតសិក មានអាការសម្គាល់ ៤ យ៉ាងគឺ ៖

១- ឯកុប្បាទៈ កើតព្រមគ្នាជាមួយនឹងចិត្ត

២- ឯកនិរោធៈ រលត់ព្រមគ្នាជាមួយនឹងចិត្ត



៣- ឯកាលម្ពណៈ មានអារម្មណ៍តែមួយជាមួយនឹងចិត្ត គឺថា ចិត្ត ដឹងអារម្មណ៍ណា ចេតសិកក៏ដឹងនូវអារម្មណ៍នោះ

៤- ឯកវត្ថុកៈ មានវត្ថុតែមួយដូចគ្នានឹងចិត្ត គឺថា ចិត្តអាស្រ័យ វត្ថុណា ចេតសិកក៏អាស្រ័យវត្ថុនោះ (វត្ថុមាន ៦ គឺ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុ និង ហទយវត្ថុ)។

# លក្ខណាទិចតុក្កៈរបស់ ចេតសិក

| | |
|---|---|
| ១- ចិត្តនិស្សិតលក្ខណំ | មានការអាស្រ័យនឹងចិត្ត ជាលក្ខណៈ |
| ២- អវិយោគុប្បាទនរសំ | មានការកើតរួមគ្នាជាមួយនឹងចិត្ត ជាកិច្ច |
| ៣- ឯកាលម្ពណបច្ចុប្បដ្ឋានំ | មានអារម្មណ៍តែមួយជាមួយនឹងចិត្ត ជាអាការប្រាកដ |
| ៤- ចិត្តុប្បាទបទដ្ឋានំ | មានការកើតឡើងនៃចិត្ត ជាហេតុជិត។ |



# ចេតសិក ៥២

### អញ្ញសមានា ១៣
១- ផស្សៈ
២- វេទនា
៣- សញ្ញា
៤- ចេតនា
៥- ឯកគ្គតា
៦- ជីវិតិន្ទ្រិយ
៧- មនសិការៈ
៨- វិតក្កៈ
៩- វិចារៈ
១០- អធិមោក្ខៈ
១១- វីរិយៈ
១២- បីតិ
១៣- ឆន្ទៈ

### អកុសលចេតសិក ១៤
១- មោហៈ
២- អហិរិកៈ
៣- អនោត្តប្បៈ
៤- ឧទ្ធច្ចៈ
៥- លោភៈ
៦- ទិដ្ឋិ
៧- មានៈ
៨- ទោសៈ
៩- ឥស្សា
១០- មច្ឆរិយៈ
១១- កុក្កុច្ចៈ
១២- ថីនៈ
១៣- មិទ្ធៈ
១៤- វិចិកិច្ឆា

### សោភណចេតសិក ២៥
១- សទ្ធា
២- សតិ
៣- ហិរិ
៤- ឱត្តប្បៈ
៥- អលោភៈ
៦- អទោសៈ
៧- តត្រមជ្ឈត្តតា
៨- កាយបស្សទ្ធិ
៩- ចិត្តបស្សទ្ធិ
១០- កាយលហុតា
១១- ចិត្តលហុតា
១២- កាយមុទុតា
១៣- ចិត្តមុទុតា
១៤- កាយកម្មញ្ញតា
១៥- ចិត្តកម្មញ្ញតា
១៦- កាយបាគុញ្ញតា
១៧- ចិត្តបាគុញ្ញតា
១៨- កាយុជុកតា
១៩- ចិត្តុជុកតា
២០- សម្មាវាចា
២១- សម្មាកម្មន្តៈ
២២- សម្មាអាជីវៈ
២៣- ករុណា
២៤- មុទិតា
២៥- បញ្ញា

# អញ្ញសមានាចេតសិក ១៣ ចែកជាពីរពួក

### សព្វចិត្តសាធារណចេតសិក ៧

| | |
|---|---|
| ១- ផស្សៈ | ការប៉ះខ្ទប់ |
| ២- វេទនា | ការសោយអារម្មណ៍ |
| ៣- សញ្ញា | ការចងចាំ |
| ៤- ចេតនា | ការតាំងចិត្ត |
| ៥- ឯកគ្គតា | ការមិនរវើរវាយ |
| ៦- ជីវិតិន្ទ្រិយ | ការរក្សាសហជាតធម៌ |
| ៧- មនសិការៈ | ការរួបរួមសហជាតធម៌ |

### បកិណ្ណកចេតសិក ៦

| | |
|---|---|
| ១- វិតក្កៈ | ការលើកចិត្តឡើងកាន់អារម្មណ៍ |
| ២- វិចារៈ | ការពិចារណា |
| ៣- អធិមោក្ខៈ | ការដាក់ចិត្តស៊ប់ (សន្និដ្ឋាន) |
| ៤- វិរិយៈ | ការឧស្សាហ៍ |
| ៥- បីតិ | ការឆ្អែតចិត្ត |
| ៦- ឆន្ទៈ | ការប្រាថ្នាដើម្បីធ្វើ |

ស្កេនដើម្បីមើលមេរៀន

San Sochea Official



# សព្វចិត្តសាធារណចេតសិក ៧

## ១ - ផស្សចេតសិក (Contact or sense-impression)

ផុស្សតីតិ = ផស្សោ ធម៌ដែលឈ្មោះថា ផស្សៈ ព្រោះអត្ថថា ប៉ះខ្ទប់ ។ ប្រៀបដូចពពែ ២ ពពែមួយដូចជាអាយតនៈខាងក្នុង ពពែមួយទៀតដូចជា អាយតនៈខាងក្រៅ ផស្សៈដូចជាការជល់គ្នានៃពពែទាំងពីរនោះឯង។

តួនាទីរបស់ផស្សៈ គឺការប៉ះខ្ទប់អារម្មណ៍ដែលចិត្តដឹង និងជាបច្ច័យឲ្យធម៌ ៣ ប្រជុំគ្នាគឺ  អារម្មណ៍ វត្ថុ និងវិញ្ញាណ។

# លក្ខណាទិចតុក្កៈរបស់ ផស្សចេតសិក

១- ផុស្សនលក្ខណោ    មានការប៉ះខ្ទប់ ជាលក្ខណៈ

២- សង្ឃដ្ដនរសោ    មានការធ្វើឲ្យចិត្ត និងអារម្មណ៍ប៉ះខ្ទប់គ្នា ជាកិច្ច

៣- សន្និបាតបច្ចុប្បដ្ឋានោ    មានការប្រជុំរវាង អារម្មណ៍ វត្ថុ ចិត្ត ជាអាការប្រាកដ

៤- អាបាថគតវិសយបទដ្ឋានោ    មានអារម្មណ៍មកកាន់គន្លង ជាហេតុជិត។



## ២ - វេទនាចេតសិក (Feeling or sensation)

វេទិយតីតិ = វេទនា  ធម្មជាតិណារមែងសោយ (នូវ អារម្មណ៍ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា វេទនា។

វេទិយតិ អាលម្ពណរសំ អនុភវតិ = វេទនា ធម៌ដែលឈ្មោះ ថា វេទនា ព្រោះអត្ថថា រលឹកដឹងខ្លួន គឺសោយរសនៃអារម្មណ៍។

**វេទនា** បើពោលដោយលក្ខណៈនៃការសោយអារម្មណ៍មាន ៣ គឺ សុខវេទនា ១  ទុក្ខវេទនា ១  និងអទុក្ខមសុខវេទនា (ឧបេក្ខា)១។ បើពោលតាម ឥន្ទ្រិយមាន ៥ គឺ សុខវេទនា ១  ទុក្ខវេទនា ១ សោមនស្សវេទនា ១  ទោមនស្សវេទនា ១  និងឧបេក្ខាវេទនា ១

*(ហៅថា សុខិន្ទ្រិយ ទុក្ខិន្ទ្រិយ ជាដើមក៏បាន) ។*



## លក្ខណាទិចតុក្កៈរបស់វេទនាចេតសិក

| | |
|---|---|
| ១ - អនុភវនលក្ខណា | មានការសោយអារម្មណ៍ ជាលក្ខណៈ |
| ២ - វិសយរសសម្ភោគរសា | មានការបរិភោគរសអារម្មណ៍ ជាកិច្ច |
| ៣ - សុខទុក្ខបច្ចុប្បដ្ឋានា | មានសុខនិងទុក្ខ ជាអាការប្រាកដ |
| ៤ - ផស្សបទដ្ឋានា | មានផស្សៈ ជាហេតុជិត។ |

# លក្ខណាទិចតុក្កៈរបស់សុខវេទនា

| | |
|---|---|
| ១- ឥដ្ឋផោដ្ឋព្វានុភវនលក្ខណា | មានការសោយនូវផោដ្ឋព្វៈ គួរជាទីប្រាថ្នា ជាលក្ខណៈ |
| ២- សម្បយុត្តានំ ព្រូហនរសា | មានការធ្វើឲ្យសម្បយុត្តធម៌ ចម្រើន ជាកិច្ច |
| ៣- កាយិកអស្សាទបច្ចុប្បដ្ឋានា | មានការត្រេកអរផ្លូវកាយ ជាអាការប្រាកដ |
| ៤- កាយិន្ទ្រិយបទដ្ឋានា | មានកាយបសាទ ជាហេតុជិត។ |



# លក្ខណាទិចតុក្កៈរបស់ទុក្ខវេទនា

| | |
|---|---|
| ១- អនិដ្ឋផោដ្ឋព្វានុភវនលក្ខណា | មានការសោយផោដ្ឋព្វៈ មិនគួរប្រាថ្នា ជាលក្ខណៈ |
| ២- សម្បយុត្តានំ មិលាបនរសា | មានការធ្វើឲ្យសម្បយុត្តធម៌ សៅហ្មង ជាកិច្ច |
| ៣- កាយិកាពាធបច្ចុប្បដ្ឋានា | មានអាពាធផ្លូវកាយ ជាអាការ ប្រាកដ |
| ៤- កាយិន្ទ្រិយបទដ្ឋានា | មានកាយបសាទ ជាហេតុជិត។ |

# លក្ខណាទិចតុក្កៈរបស់សោមនស្សវេទនា

១- ឥដ្ឋារម្មណានុភវនលក្ខណា — មានការសោយនូវអារម្មណ៍ជាទីប្រាថ្នា ជាលក្ខណៈ

២- ឥដ្ឋាការសម្ភោគរសា — មានការប្រសព្វនឹងអារម្មណ៍ដែលគួរប្រាថ្នា ជាកិច្ច

៣- ចេតសិកអស្សាទបច្ចុប្បដ្ឋានា — មានការត្រេកអរផ្លូវចិត្ត ជាអាការប្រាកដ

៤- បស្សទ្ធិបទដ្ឋានា — មានការស្ងប់កាយ ជាហេតុជិត។



# លក្ខណាទិចតុក្កៈរបស់ទោមនស្សវេទនា

១- អនិដ្ឋារម្មណានុភវនលក្ខណា — មានការសោយអារម្មណ៍មិនជាទីប្រាថ្នា ជាលក្ខណៈ

២- អនិដ្ឋាការសម្ភោគរសា — មានការប្រសព្វនឹងអារម្មណ៍ដែលមិនគួរប្រាថ្នា ជាកិច្ច

៣- ចេតសិកាពាធបច្ចុប្បដ្ឋានា — មានអាពាធផ្លូវចិត្ត ជាអាការប្រាកដ

៤- ឯកន្តេនេវហទយវត្ថុបទដ្ឋានា — មានហទយវត្ថុតែម្យ៉ាង ជាហេតុជិត។

# លក្ខណាទិចតុក្កៈរបស់ឧបេក្ខាវេទនា

| | |
|---|---|
| ១- មជ្ឈត្តវេទយិតលក្ខណា | មានការសោយអារម្មណ៍ជាកណ្តាល ជាលក្ខណៈ |
| ២- សម្បយុត្តានំ នាតិឧបព្រូហនមិលាបនរសា | មានការរក្សា សម្បយុត្តធម៌ឲ្យចម្រើន និងមិនឲ្យសាបសូន្យជាកិច្ច |
| ៣- សន្តភាវបច្ចុប្បដ្ឋានា | មានការស្ងប់ ជាអាការប្រាកដ |
| ៤- និប្បីតិកចិត្តបទដ្ឋានា | មានចិត្តដែលមិនប្រកបដោយបីតិ ជាហេតុជិត។ |



មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៤

## ៣- សញ្ញាចេតសិក (Perception)

នីលាទិភេទារម្មណំ សញ្ជានាតិ សញ្ញំ កត្វា ជានាតីតិ = សញ្ញា

ធម្មជាតិដែលឈ្មោះថា សញ្ញា ព្រោះសេចក្តីថា ចងចាំអារម្មណ៍ផ្សេងៗ មានពណ៌ខៀវជាដើម គឺធ្វើនូវការកំណត់សម្គាល់ (ឬចំណាំ)។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់សញ្ញាចេតសិក

១- សញ្ញានលក្ខណា មានការចងចាំ (ឬ សម្គាល់) ជាលក្ខណៈ

២- បុនសញ្ញាននបច្ចយនិមិត្តករណរសា មានការស្គាល់ និងធ្វើនូវការសម្គាល់ទុកជាកិច្ច (*ដូចជាងឈើធ្វើនូវសញ្ញាសម្គាល់ត្រង់ដើមឈើជាដើម*)

៣- យថាគហិតនិមិត្តវសេន អភិនិវេសករណបច្ចុប្បដ្ឋានាមានការអាស្រ័យនូវនិមិត្តតាមដែលបានកំណត់ទុក (ឬចាំបាន) ជាអាការប្រាកដ

៤- យថាឧបដ្ឋិតវិសយបទដ្ឋានា មានអារម្មណ៍ដែលប្រាកដ ជាហេតុជិត។



# ៤ - ចេតនាចេតសិក (Volition)

ចេតនាចេតសិក ជាធម្មជាតិផ្តួងចិត្ត គឺចាត់ចែងដាស់តឿនសម្បយុត្តធម៌ដែលកើតព្រមជាមួយនឹងខ្លួន ឱ្យធ្វើកិច្ចរបស់ខ្លួន។

ចេតេតិ អត្តនា សម្បយុត្តធម្មេ អារម្មណេ អភិសន្ទហតិ សង្ខតាភិសង្ខរណេ វា ព្យាបារមាបជ្ជតីតិ = ចេតនា ធម្មជាតិដែលឈ្មោះថា ចេតនា ព្រោះអត្ថថា តាំងចិត្ត គឺ ញុំាងសម្បយុត្តធម៌ ឲ្យព្រមព្រៀងជាមួយនឹងខ្លួនក្នុងអារម្មណ៍ ឬ ដែលឈ្មោះថា ចេតនា ព្រោះអត្ថថា ដល់នូវសេចក្តីខ្វល់ខ្វាយក្នុងការតាក់តែងធម៌ដែលជាសង្ខតៈ។

# លក្ខណាទិចតុក្កៈរបស់ចេតនា

| | |
|---|---|
| ១. ចេតនាភាវលក្ខណា | មានការផ្តួងចិត្ត ជាលក្ខណៈ |
| ២. អាយូហនរសា | មានការប្រមូលមក ជាកិច្ច |
| ៣. សំវិធានបច្ចុប្បដ្ឋានា | មានការចាត់ចែង ជាអាការប្រាកដ (ដូចជាងឈើធ្វើកិច្ចឱ្យសម្រេច) |
| ៤. សេសខន្ធត្តយបទដ្ឋានា | មានខន្ធ ៣ ដែលនៅសល់ (វេទនា សញ្ញា វិញ្ញាណ) ជាហេតុជិត។ |



មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៥

## ៥ - ឯកគ្គតាចេតសិក (One-Pointedness)

ឯកគ្គតាចេតសិក ជាធម្មជាតិស្ងប់ និងធ្វើឲ្យសម្បយុត្តធម៌ តាំងនៅក្នុងអារម្មណ៍តែមួយដូចគ្នា។

នានាលម្ពនវិក្ខេបាភាវេន ឯកំ អារម្មណំ អគ្គំ ឥមិស្សាតិ ឯកគ្គំ ចិត្តំ តស្ស ភាវោ = ឯកគ្គតា ចិត្តដែលឈ្មោះថា ឯកគ្គៈ ដោយអត្ថថា មានអារម្មណ៍តែមួយ ព្រោះមិនមានសេចក្តីរវើរវាយ ទៅក្នុងអារម្មណ៍ផ្សេងៗ ភាវៈនៃចិត្តមានអារម្មណ៍តែមួយនោះ ឈ្មោះថា ឯកគ្គតា។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់ឯកគ្គតា

១. អវិក្ខេបលក្ខណា មានការមិនរវើរវាយ ជាលក្ខណៈ

២. សហជាតានំ សម្បិណ្ឌនរសា មានការប្រមូលសហជាតធម៌មក ជាកិច្ច

៣. ឧបសមបច្ចុប្បដ្ឋានា មានការចូលទៅស្ងប់ ជាអាការប្រាកដ

៤. សុខបទដ្ឋានា មានសុខវេទនា ជាហេតុជិត។



## ៦ - ជីវិតិន្ទ្រិយចេតសិក (Psychic life)

ជីវិតិន្ទ្រិយចេតសិក ជាធម៌រក្សាសម្បយុត្តធម៌ គឺ ធ្វើឲ្យសម្បយុត្តធម៌តាំងនៅនិងប្រព្រឹត្តទៅ។ ធម៌ដែលឈ្មោះថា ឥន្ទ្រិយ ព្រោះភាពជាធំ ក្នុងការរក្សាធម៌ដែលកើតរួមគ្នា។

ជីវន្តិ តេន សម្បយុត្តធម្មាតិ ជីវិតំ តទេវ សហជាតានុបាលនេ អធិបច្ចយោគេន ឥន្ទ្រិយន្តិ = ជីវិតិន្ទ្រិយំ ឈ្មោះថា ជីវិត ព្រោះអត្ថថា ជាគ្រឿងតាំងនៅនៃសម្បយុត្តធម៌។ ជីវិតនោះឯង ជាធំក្នុងការរក្សាសហជាតធម៌ ដោយគួរដល់ សេចក្តីជាធំ ព្រោះដូច្នោះ ទើបឈ្មោះថា ជីវិតិន្ទ្រិយ។

# លក្ខណាទិចតុក្កៈរបស់ជីវិតិន្ទ្រិយ

| | |
|---|---|
| ១ - សហជាតានំ អនុបាលនលក្ខណំ | មានការតាមរក្សាសហជាតធម៌ ជាលក្ខណៈ *(ប្រៀបដូចទឹករក្សាផ្កាឈូកជាដើម)* ។ |
| ២ - តេសំ បវត្តនរសំ | មានការញ៉ាំងសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅ ជាកិច្ច |
| ៣ - តេសញ្ញេវ ឋបនបច្ចុប្បដ្ឋានំ | មានការតាំងនៅនៃសហជាតធម៌ ជាអាការប្រាកដ |
| ៤ - សេសខន្ធត្តយបទដ្ឋានំ | មានខន្ធ ៣ ដែលនៅសល់ ជាហេតុជិត។ |



មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៦

## ៧ - មនសិការចេតសិក (Attention)

មនសិការចេតសិក ជាធម្មជាតិនាំសម្បយុត្តធម៌ ទៅកាន់ អារម្មណ៍។

ករណំ ការោ មនស្មឹ ការោ = មនសិការោ ការធ្វើ ឈ្មោះថា ការៈ។

ការធ្វើទុកក្នុងចិត្ត ឈ្មោះថា មនសិការៈ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់មនសិការៈ

១ - សារណលក្ខណោ មានការធ្វើឲ្យសម្បយុត្តធម៌ត្រាច់ទៅ ជាលក្ខណៈ

២ - សម្បយុត្តានំ អារម្មណេ សំយោជនរសោ មានការញ៉ាំង សម្បយុត្តធម៌ ឲ្យប្រកបក្នុងអារម្មណ៍ ជាកិច្ច

៣ - អារម្មណាភិមុខីភាវបច្ចុប្បដ្ឋានោ មានការធ្វើឲ្យសម្បយុត្តធម៌ តម្រង់មុខឆ្ពោះទៅទល់នឹងអារម្មណ៍ ជាអាការប្រាកដ *(ដូចនាយសារថីនាំសេះឲ្យទៅកាន់ទិសដែលត្រូវការ)*

៤ - អារម្មណបទដ្ឋានោ មានអារម្មណ៍ ជាហេតុជិត។



# ចេតនា និងមនសិការចេតសិក (Attention)

ចេតសិកទាំង២នេះ មានសភាពស្រដៀងគ្នា ប៉ុន្តែមិនដូចគ្នាទេ។ ចេតនា មានតួនាទីតាក់តែងដាស់តឿនសម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួន ឲ្យធ្វើកិច្ចរបស់ខ្លួន។ ចំណែកមនសិការចេតសិក មានតួនាទីប្រាថ្នានាំសម្បយុត្តធម៌ដែលកើតព្រមនឹងខ្លួនឲ្យប្រព្រឹត្តទៅ។

ចេតសិកទាំង ៧ នេះ ប្រកបជាមួយនឹងចិត្តគ្រប់ដួង ព្រោះសភាពរបស់ចិត្តនោះ កើតឡើងដើម្បី ដឹងអារម្មណ៍, ការដែលនឹងដឹងអារម្មណ៍បានព្រោះ ៖

- ផស្សៈ ធ្វើកិច្ចប៉ះខ្ទប់អារម្មណ៍
- វេទនា ជាសភាពសោយអារម្មណ៍
- សញ្ញា ធ្វើកិច្ចចាំអារម្មណ៍
- ចេតនា ធ្វើកិច្ចខ្វល់ខ្វាយឲ្យសម្រេច ឬដាស់តឿន
- ឯកគ្គតា ធ្វើសម្បយុត្តធម៌ដែលកើតព្រមគ្នាឲ្យ តាំងនៅក្នុងអារម្មណ៍តែមួយ
- ជីវិតិន្ទ្រិយ ជាធម៌រក្សាសម្បយុត្តធម៌ឲ្យប្រព្រឹត្តទៅ
- មនសិការៈ ការនាំសម្បយុត្តធម៌ ទៅកាន់អារម្មណ៍

** បើចេតសិកទាំង ៧ នេះ មិនកើតទេ ចិត្តក៏មិនអាចកើតបានដែរ ដូច្នេះ ចេតសិកទាំង ៧ នេះ ទើបមានឈ្មោះថា សព្វចិត្តសាធារណចេតសិក។*



## ចែកសព្វចិត្តសាធារណចេតសិក ៧ ដោយន័យផ្សេងៗគ្នា

**១ - ដោយខន្ធ** វេទនាចេតសិក ជាវេទនាខន្ធ សញ្ញាចេតសិក ជាសញ្ញាខន្ធ ចេតសិក ៥ ទៀត ជាសង្ខារក្ខន្ធ។

**២ - ដោយជាតិ** ចេតសិក ៦ *(វៀរវេទនា)* ជាជាតិទាំង ៤។ សុខ ទុក្ខ ជាវិបាកជាតិ ទោមនស្ស ជាអកុសលជាតិ សោមនស្សឧបេក្ខា ជាជាតិទាំង ៤។

**៣ - ដោយទ្វារ** ចេតសិក ៦ *(វៀរវេទនា)* កើតបាន ទ្វារ ៦ និងទ្វារវិមុត្ត។ សុខ ទុក្ខ កើតតាមកាយទ្វារ ទោមនស្ស កើតតាមទ្វារ ៦ សោមនស្ស ឧបេក្ខា កើតតាមទ្វារ ៦ និងទ្វារវិមុត្ត។

៤ - ដោយអារម្មណ៍ ចេតសិក ៦ *(វៀរវេទនា)* ដឹងអារម្មណ៍បាន ៦។ សុខ ទុក្ខ ដឹងផោដ្ឋព្វារម្មណ៍ ទោមនស្ស ដឹងអារម្មណ៍បាន ៦ សោមនស្ស ឧបេក្ខា ដឹងអារម្មណ៍បាន ៦ *(គ្រប់ទាំងអស់)*

៥ - ដោយភូមិ ចេតសិក ៦ *(វៀរវេទនា)* ប្រព្រឹត្តទៅក្នុងភូមិទាំង ៤ *(កើតក្នុងភូមិ៣០)*។ សុខ ទុក្ខ ទោមនស្ស ជាកាមភូមិ *(កើតក្នុងកាមភូមិ ១១)* សោមនស្ស ជាកាមភូមិ រូបភូមិ លោកុត្តរភូមិ *(កើតក្នុងភូមិ ៣០)* ឧបេក្ខា ជាភូមិទាំង ៤ *(កើតក្នុងភូមិ ៣០ វៀរអសញ្ញីភូមិ)*



៦ - ដោយវត្ថុ ចេតសិក ៦ *(វៀរវេទនា)* កើតអាស្រ័យវត្ថុទាំង ៦ សុខ ទុក្ខ កើតត្រង់កាយវត្ថុ ទោមនស្ស សោមនស្ស កើតត្រង់ហទយវត្ថុ ឧបេក្ខា កើតបានត្រង់វត្ថុ ៥ *(វៀរកាយវត្ថុ)*

៧ - ដោយហេតុ ចេតសិក ៧ ជានហេតុ

៨ - ដោយសោភណ ចេតសិក ៧ ជាសោភណក៏មាន អសោភណក៏មាន

៩ - ដោយលោក ចេតសិក ៧ ជាលោកិយក៏មាន លោកុត្តរក៏មាន។

# បកិណ្ណកចេតសិក ៦

## ១ - វិតក្កចេតសិក (Initial Application)

អារម្មណំ វិតក្កេតិ សម្បយុត្តធម្មេ អភិនិរោបេតីតិ = វិតក្កោ ធម៌ណារមែងត្រិះរិះ (នឹក) ដល់អារម្មណ៍ គឺ លើកសម្បយុត្តធម៌ឡើងកាន់អារម្មណ៍ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា វិតក្កៈ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



# លក្ខណាទិចតុក្កៈរបស់វិតក្កៈ

១ - អារម្មណេ ចិត្តស្ស អភិនិរោបនលក្ខណោ មានការលើកចិត្តឡើងកាន់អារម្មណ៍ ជាលក្ខណៈ

២ - អាហននបរិយាហននរសោ មានការធ្វើចិត្តឲ្យប៉ះខ្ទប់អារម្មណ៍រឿយៗ ជាកិច្ច

៣ - អានយបច្ចុប្បដ្ឋានោ មានការនាំចិត្តទៅក្នុងអារម្មណ៍ ជាអាការប្រាកដ

៤ - អាបាថវិសយបទដ្ឋានោ មានអារម្មណ៍ក្នុងវិថី ជាហេតុជិត។

## ២ - វិចារចេតសិក (Sustained Application)

អារម្មណេ តេន ធម្មេន ចិត្តំ វិចរតីតិ = វិចារោ ចិត្តរមែងត្រាច់ទៅក្នុងអារម្មណ៍ ដោយធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា វិចារៈ ។



## លក្ខណាទិចតុក្កៈរបស់វិចារៈ

| | |
|---|---|
| ១ - អារម្មណានុមជ្ជនលក្ខណោ | មានការពិចារណាក្នុងអារម្មណ៍ ជាលក្ខណៈ |
| ២ - តត្ថ សហជាតានុយោជនរសោ | មានការតាមប្រកបសហជាតធម៌ទុកក្នុងអារម្មណ៍ ជាកិច្ច |
| ៣ - ចិត្តានុបពន្ធបច្ចុប្បដ្ឋានោ | មានការចងចិត្តទុកក្នុងអារម្មណ៍ ជាអាការប្រាកដ |
| ៤ - អារម្មណបទដ្ឋានោ | មានអារម្មណ៍ ជាហេតុជិត។ |

## ៣ - អធិមោក្ខចេតសិក (Decision)

អធិមុច្ចនំ = អធិមោក្ខោ ការបង្អោនចិត្តទៅ (ឬជឿយ៉ាងស៊ប់) ឈ្មោះថា អធិមោក្ខៈ ។



## លក្ខណាទិចតុក្កៈរបស់អធិមោក្ខៈ

| | |
|---|---|
| ១ - សន្និដ្ឋានលក្ខណោ | មានការដាក់ចិត្តស៊ប់ ឬសម្រេច *(សន្និដ្ឋាន)* ជាលក្ខណៈ |
| ២ - អសំសប្បនរសោ | មានការមិនសង្ស័យ *(ឬមិនឃ្លេងឃ្លោង)* ជាកិច្ច |
| ៣ - វិនិច្ឆយបច្ចុប្បដ្ឋានោ | មានការចុះចិត្តស៊ប់ *(ឬកាត់សេចក្តី)* ជាការប្រាកដ |
| ៤ - សន្និដ្ឋេយ្យធម្មបទដ្ឋានោ | មានធម៌ដែលគប្បីសម្រេច *(សន្និដ្ឋាន)* ជាហេតុជិត។ |

** អធិមោក្ខៈនេះ ជាបដិបក្ខនឹងវិចិកិច្ឆា ។*

# ៤ - វីរិយចេតសិក (Effort)

វីរានំ ភាវោ កម្មំ វា វិធិនា ឥរយិតព្វំ បវត្តេតព្វន្តិ វា = វីរិយំ

ឧស្សាហោ ភារៈ ឬការងាររបស់អ្នកអង់អាច ឈ្មោះថា វីរិយៈ។

មួយទៀត ធម្មជាតិណា ដែលបុគ្គលគប្បីឲ្យមានដំណើរទៅ គប្បីឲ្យប្រព្រឹត្តទៅដោយវិធី ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា វីរិយៈ បានដល់សេចក្តីព្យាយាម។



## លក្ខណាទិចតុក្កៈរបស់វីរិយៈ

| | |
|---|---|
| ១ - ឧស្សាហនលក្ខណំ | មានការឧស្សាហ៍ ជាលក្ខណៈ |
| ២ - សហជាតានំ ឧបត្ថម្ភនរសំ | មានការឧបត្ថម្ភដល់សហជាតធម៌ ជាកិច្ច |
| ៣ - អសំសីទនភាវបច្ចុប្បដ្ឋានំ | មិនមានការរាថយ ជាអាការប្រាកដ |
| ៤ - សំវេគវត្ថុបទដ្ឋានំ | មានសំវេគវត្ថុ ជាហេតុជិត ។ |

## សំវេគវត្ថុ ៨

ហេតុជាទីតាំងនៃសេចក្តីសង្វេគ ហៅថា សំវេគវត្ថុ មាន ៨ គឺ ៖

- ការពិចារណាដល់ជាតិទុក្ខ ១
- ការពិចារណាដល់ជរាទុក្ខ ១
- ការពិចារណាដល់ព្យាធិទុក្ខ ១
- ការពិចារណាដល់មរណទុក្ខ ១
- ការពិចារណាដល់អបាយិកទុក្ខ ១
- ការពិចារណាដល់អតីតវដ្តមូលកទុក្ខ ១
- ការពិចារណាដល់អនាគតវដ្តមូលកទុក្ខ ១
- និងការពិចារណាដល់ទុក្ខ ក្នុងការស្វែងរកអាហារក្នុងបច្ចុប្បន្ន ១។



មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៨

## ៥ - បីតិចេតសិក (Joy)

បីនយតិ កាយចិត្តំ តប្បេតិ វឌ្ឍេតីតិ វា = បីតិ ធម្មជាតិដែលឈ្មោះថា បីតិ ព្រោះអត្ថថា ញ៉ាំងកាយ និងចិត្តឲ្យឆ្អែតឲ្យរីករាយ ឬញ៉ាំងកាយនិងចិត្តឲ្យចម្រើន ដូចផ្កាបទុមរីកល្អហើយ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់បីតិ

| | |
|---|---|
| ១ - សម្បិយាយនលក្ខណា | មានការស្រស់ស្រាយ សប្បាយ ពេញចិត្ត ជាលក្ខណៈ |
| ២ - កាយចិត្តសម្បីណនរសា | មានការធ្វើឲ្យកាយនិងចិត្តឆ្អែត ជាកិច្ច |
| ៣ - ឱទគ្យបច្ចុប្បដ្ឋានា | មានការត្រេកអររីករាយ ជាអាការប្រាកដ |
| ៤ - សេសខន្ធត្តយបទដ្ឋានា | មាននាមខន្ធ ៣ *(គឺ វេទនាខន្ធ សញ្ញាខន្ធ និងវិញ្ញាណក្ខន្ធ)* ដែលនៅសល់ ជាហេតុជិត។ |



# បីតិ ៥ យ៉ាង

| | |
|---|---|
| ១ - ខុទ្ទកាបីតិ | សេចក្តីត្រេកអរតិច ត្រឹមព្រឺរោម ព្រឺស្បែក ដែលកើតឡើងម្តងម្កាល |
| ២ - ខណិកាបីតិ | សេចក្តីត្រេកអរមួយខណៈៗ ប្រាកដដូចជាផ្លេកបន្ទោរ *(តាំងនៅមិនយូរ)* |
| ៣ - ឱក្កន្តិកាបីតិ | សេចក្តីត្រេកអរមួយស្របក់ មានអាការប្រាកដដូចជាទឹករលកបោកខ្ទប់ច្រាំង ហើយក៏បែកទៅ |
| ៤ - ឧព្វេង្គាបីតិ | សេចក្តីត្រេកអរខ្លាំង អាចញ៉ាំងកាយឲ្យអណ្តែតឡើង |
| ៥ - ផរណាបីតិ | សេចក្តីត្រេកអរធ្វើឲ្យផ្សព្វផ្សាយជ្រួតជ្រាបទូទៅក្នុងកាយ ដូចសំឡីជប់ទឹក។ |

## ៦ - ឆន្ទចេតសិក (Conation)

ឆន្ទនំ = ឆន្ទោ សេចក្ដីពេញចិត្ត ឈ្មោះថា ឆន្ទៈ។

ឆន្ទៈនេះ មានការប្រាថ្នារូបារម្មណ៍ជាដើម។



## លក្ខណាទិចតុក្កៈរបស់ឆន្ទៈ

១ - កត្តុកម្យតាលក្ខណោ មានការប្រាថ្នាដើម្បីធ្វើ ជាលក្ខណៈ

២ - អារម្មណបរិយេសនរសោ មានការស្វែងរកអារម្មណ៍ ជាកិច្ច

៣ - អារម្មណេន អត្ថិកតាបច្ចុប្បដ្ឋានោ មានសេចក្ដីប្រាថ្នាត្រូវការអារម្មណ៍ ជាអាការប្រាកដ

៤ - អារម្មណបទដ្ឋានោ មានអារម្មណ៍ ជាហេតុជិត។

**បកិណ្ណកចេតសិកទាំង ៦** នេះ ជាសង្ខារក្ខន្ធទាំងអស់ មិនចាំបាច់ចែកដោយន័យផ្សេង ៗ ទេ ព្រោះប្រកបជាមួយនឹងចិត្តយ៉ាងណា ចេតសិកទាំង ៦ នេះ ក៏ជាយ៉ាងនោះ។



## សរុបអញ្ញសមានាចេតសិក ១៣

- អញ្ញសមានាចេតសិក១៣
  - សព្វចិត្តសាធារណចេតសិក ៧
    - ផស្សៈ
    - វេទនា
    - សញ្ញា
    - ចេតនា
    - ឯកគ្គតា
    - ជីវិតិន្ទ្រិយ៍
    - មនសិការៈ
  - បកិណ្ណកចេតសិក ៦
    - វិតក្កៈ
    - វិចារៈ
    - អធិមោក្ខៈ
    - វីរិយៈ
    - បីតិ
    - ឆន្ទៈ

ចប់ អញ្ញសមានាចេតសិក

# អធិប្បាយ អកុសលចេតសិក ១៤

អកុសលចេតសិកទាំង ១៤ នេះ ជាចេតសិកផ្នែកអាក្រក់ ជាបាប កាលប្រកបជាមួយនឹងចិត្ត រមែងធ្វើ ឲ្យចិត្តសៅហ្មង។ អកុសលចេតសិកទាំង ១៤ នេះ កើតតែនៅក្នុងចិត្តជាអកុសលចិត្ត ១២ ដួង ប៉ុណ្ណោះ។



# អកុសលចេតសិក ១៤ មាន ៥ ន័យ

| | |
|---|---|
| ១ - មោចតុក្កៈ | បានដល់ ចេតសិក ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ |
| ២ - លោតិកៈ | បានដល់ ចេតសិក ៣ គឺ លោភៈ ទិដ្ឋិ មានៈ |
| ៣ - ទោចតុក្កៈ | បានដល់ ចេតសិក ៤ គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ |
| ៤ - ថីទុកៈ | បានដល់ ចេតសិក ២ គឺ ថីនៈ មិទ្ធៈ |
| ៥ - ឯកវិចិកិច្ឆា | បានដល់ ចេតសិក ១ គឺ វិចិកិច្ឆា |

មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ៩

មោចតុក្កចេតសិក ៤ តែងប្រកបជាមួយអកុសលចិត្តបានទាំង ១២ ដួង ដូច្នេះទើបមានឈ្មោះថា **សព្វាកុសលសាធារណចេតសិក** (ចេតសិកកើតទូទៅគ្រប់អកុសលចិត្ត)។

ស្កេនដើម្បីមើលមេរៀន
San Sochea Official



## ១ - មោហចេតសិក (Delusion)

**អារម្មណេ មុយ្ហតីតិ = មោហោ អញ្ញាណំ** ធម៌ដែលមានឈ្មោះថា **មោហៈ** ព្រោះអត្ថថា វង្វេងក្នុងអារម្មណ៍បានដល់ អញ្ញាណ។

**មុយ្ហន្តិ សត្តា ឯតេនាតិ = មោហោ** សភាវៈធ្វើឲ្យពពួកសត្វវង្វេង។

# លក្ខណាទិចតុក្កៈមោហៈ

១ - អញ្ញាណលក្ខណោ — មានការមិនដឹង (សភាវធម៌) តាមសេចក្តីពិត ជាលក្ខណៈ

២ - អារម្មណសភាវច្ឆាទនរសោ — មានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច

៣ - អន្ធការបច្ចុប្បដ្ឋានោ — មានភាពងងឹត (ល្ងង់) ជាអាការប្រាកដ

៤ - អយោនិសោមនសិការបទដ្ឋានោ — មានអយោនិសោមនសិការៈ ជាហេតុជិត។

** មោហៈ គឺអវិជ្ជា បានដល់ការមិនដឹងតាមសេចក្តីពិត។*



## ក្នុងទីនេះលោកសម្តែងដល់សេចក្តីមិនដឹងក្នុងធម៌ ៨ យ៉ាង គឺ ៖

១ - ទុក្ខេ អញ្ញាណំ — សេចក្តីមិនដឹងក្នុងទុក្ខសច្ចៈ

២ - ទុក្ខសមុទយេ អញ្ញាណំ — សេចក្តីមិនដឹងក្នុងទុក្ខសមុទយសច្ចៈ

៣ - ទុក្ខនិរោធេ អញ្ញាណំ — សេចក្តីមិនដឹងក្នុងទុក្ខនិរោធសច្ចៈ

៤ - ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ — សេចក្តីមិនដឹងក្នុងមគ្គសច្ចៈ

៥ - បុព្វន្តេ អញ្ញាណំ — សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត

៦ - អបរន្តេ អញ្ញាណំ — សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអនាគត

៧ - បុព្វន្តាបរន្តេ អញ្ញាណំ — សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអតីត និងអនាគត

៨ - ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ — សេចក្តីមិនដឹងក្នុងបដិច្ចសមុប្បាទ គឺ មិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នាកើតឡើងថា "ធម៌នេះជាបច្ច័យ"។

# ២ - អហិរិកចេតសិក

(Shamelessness of consequences or to commit wrong)

**ន ហិរិយតិ ន លជ្ជិយតីតិ អហិរិកោ បុគ្គលោ ធម្មសមូហោ វា** បុគ្គលឬប្រជុំនៃធម៌ ឈ្មោះថា **អហិរិកៈ** ព្រោះអត្ថថា មិនខ្មាស គឺមិនរង្កៀសចំពោះបាប។ **កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណន្តិ ច អលជ្ជាលក្ខណន្តិ ច** អហិរិកៈ មាន លក្ខណៈមិនស្អប់ខ្ពើម មិនខ្មាសចំពោះកាយទុច្ចរិតជាដើម។ **អហិរិ** គឺជាបដិបក្ខនឹង **ហិរិ** *(សេចក្តីខ្មាស ស្អប់ ឬខ្ពើមបាប)*។



# លក្ខណាទិចតុក្កៈរបស់អហិរិកៈ

**១ - កាយទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណំ អលជ្ជនលក្ខណំ វា** មានការមិនខ្ពើម ឬមិនខ្មាសនូវទុច្ចរិត មានកាយទុច្ចរិត ជាដើម ជាលក្ខណៈ

**២ - បាបានំ ករណរសំ** មានការធ្វើបាប ជាកិច្ច

**៣ - អសង្កោចនបច្ចុប្បដ្ឋានំ** មានការមិនថយចាកបាប ជាអាការប្រាកដ

**៤ - អត្តនិ អគារវបទដ្ឋានំ** មានការមិនគោរពខ្លួន គឺ មិនខ្មាសដល់ចិត្តខ្លួនឯង ជាហេតុជិត។

** អហិរិកៈ មានការមិនស្អប់ មិនខ្ពើម មិនខ្មាសអំពើបាប ប្រៀបដូចសត្វត្មាតមិនខ្ពើមសាកសពដូច្នោះ។*

# ៣ - អនោត្តប្បចេតសិក

(Fearlessness of consequences or to commit wrong)

**ន ឱត្តប្បតីតិ = អនោត្តប្បំ** ឈ្មោះថា អនោត្តប្បៈ ព្រោះអត្ថថា មិនតក់ស្លុតចំពោះបាប *(ឬមិនតក់ស្លុត មិនខ្លាចចំពោះផលនៃទុច្ចរិតកម្ម)*។ **អនោត្តប្បៈ** គឺជាបដិបក្ខនឹងឱត្តប្បៈ *(សេចក្តីតក់ស្លុត ខ្លាច ឬញញើតចំពោះបាប)*។



## លក្ខណាទិចតុក្កៈរបស់អនោត្តប្បៈ

**១ - អនុត្តាសលក្ខណំ** មានការមិនតក់ស្លុតចំពោះបាប ជាលក្ខណៈ

**២ - បាបានំ ករណរសំ** មានការធ្វើបាប ជាកិច្ច

**៣ - អសង្កោចនបច្ចុប្បដ្ឋានំ** មានការមិនថយចាកបាប ជាអាការប្រាកដ

**៤ - បរាគារវបទដ្ឋានំ** មានការមិនគោរពអ្នកដទៃ ជាហេតុជិត។

** អហិរិកៈ មានការមិនខ្ពើមកាយទុច្ចរិតជាដើម ដូចជ្រូកមិនខ្ពើមលាមកចំណែកអនោត្តប្បៈ មានការមិនខ្លាចក្រែង ចំពោះកាយទុច្ចរិតជាដើម ដូចសត្វមមាចមិនខ្លាចភ្លើង។*

# ៤ - ឧទ្ធច្ចចេតសិក (Restlessness)

ឧទ្ធតស្ស ភាវោ = ឧទ្ធច្ចំ ភាវៈនៃចិត្តដែលរវើរវាយ *(មិនស្ងប់)* ឈ្មោះថា ឧទ្ធច្ចៈ។

ឧទ្ធច្ចៈ មានការឆ្លាទៅឆ្លាមក នៃចិត្តចំពោះអារម្មណ៍ គឺរាយមាយ ប្រៀបដូចកន្ទុយទង់ត្រូវខ្យល់បក់។



## លក្ខណាទិចតុក្កៈរបស់ឧទ្ធច្ចៈ

| | |
|---|---|
| ១- អវូបសមនលក្ខណំ | មានការមិនចូលទៅស្ងប់ ជាលក្ខណៈ ដូចទឹករលកព្រោះខ្យល់បក់ |
| ២- អនវដ្ឋានរសំ | មានការមិនតាំងនៅនឹងក្នុងអារម្មណ៍ ជាកិច្ច ដូចកន្ទុយទង់ត្រូវខ្យល់បក់ |
| ៣- ភន្តត្តបច្ចុប្បដ្ឋានំ | មានការភ័ន្តភាំង អណ្តែតអណ្តូងនៃចិត្ត ជាអាការប្រាកដ |
| ៤- អយោនិសោមនសិការបទដ្ឋានំ | មានអយោនិសោមនសិការ ជាហេតុជិត។ |

មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ១០

# ៥ - លោភចេតសិក (Attachment)

លុព្ភតីតិ = លោភោ ឈ្មោះថា លោភៈ ព្រោះអត្ថថា ចង់បាន។

លុព្ភន្តិ សម្បយុត្តា ធម្មា ឯតេនាតិ = លោភោ សភាវធម៌ធ្វើឲ្យ

សម្បយុត្តធម៌ចង់បាន។ លោភៈនេះ កើតជាមួយនឹង

លោភមូលចិត្ត ៨ ដួង ប៉ុណ្ណោះ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## លក្ខណាទិចតុក្កៈរបស់លោភៈ

១ - អារម្មណគ្គហណលក្ខណោ មានការកាន់យកនូវអារម្មណ៍ ជាលក្ខណៈ ដូចស្វាជាប់ជ័រ

២ - អភិសំគរសោ មានការជាប់ជំពាក់នឹងអារម្មណ៍ ជាកិច្ច ដូចដុំសាច់ដែលដាក់លើអំបែងក្តៅ

៣ - អបរិច្ចាគបច្ចុប្បដ្ឋានោ មានការមិនលះបង់ ជាអាការប្រាកដ ដូចសំពត់ប្រឡាក់ប្រេង ឬទឹកថ្នាំពណ៌

៤ - សំយោជនីយធម្មេសុ អស្សាទទស្សនបទដ្ឋានោ មានការមើលដោយសេចក្តីគាប់ចិត្ត ក្នុងធម៌ដែលជាអារម្មណ៍របស់សំយោជនៈ ជាហេតុជិត។

ក្នុងបរមត្ថទីបនី បានរៀបរាប់អំពីវេវចនៈ នៃលោភៈ មាន ១០ យ៉ាងគឺ ៖

| | |
|---|---|
| ១ - តណ្ហា | ចំណង់ |
| ២ - រាគៈ | តម្រេក |
| ៣ - កាមៈ | សេចក្តីប្រាថ្នា ឬស្រឡាញ់ |
| ៤ - នន្ទិ | សេចក្តីរីករាយ ភ្លើតភ្លើន |
| ៥ - អភិជ្ឈា | ការសម្លឹងរំពៃ |
| ៦ - ជនេត្តី | អ្នកបង្កើត |
| ៧ - បោនោព្ភវិកា | អ្នកឲ្យកើតក្នុងភពថ្មី |
| ៨ - ឥច្ឆា | សេចក្តីប្រាថ្នាចង់បាន |
| ៩ - អាសា | ការប៉ុនប៉ង ឬសង្ឃឹម |
| ១០ - សញ្ញោជនៈ | គ្រឿងចង។ |



## ៦ - ទិដ្ឋិចេតសិក (Misbelief or Wrong View)

ទស្សនំ = ទិដ្ឋិ សេចក្តីយល់ឃើញ ឈ្មោះថា ទិដ្ឋិ។ ទិដ្ឋិក្នុងទីនេះ សំដៅយកតែមិច្ឆាទិដ្ឋិប៉ុណ្ណោះ។

# ទិដ្ឋិ មាន ២ យ៉ាង ៖

១ - សាមញ្ញទិដ្ឋិ បានដល់ សក្កាយទិដ្ឋិដែលមានសេចក្តីយល់ខុសចាកសភាវធម៌ថា "ជាមនុស្ស ជាសត្វ ជាអត្តា"។ ទិដ្ឋិនេះ មានទូទៅសម្រាប់បុថុជ្ជន វៀរលែងតែ ព្រះអរិយៈប៉ុណ្ណោះ ទើបហៅថា សាមញ្ញទិដ្ឋិ។

២ - ទិដ្ឋិវិសេស  បានដល់ ទិដ្ឋិ ៦២ និងនិយតមិច្ឆាទិដ្ឋិជាដើម (វៀរសក្កាយទិដ្ឋិ) ព្រោះទិដ្ឋិនេះមានចំពោះមនុស្សពួកខ្លះ និងឱកាសខ្លះប៉ុណ្ណោះ។



# លក្ខណាទិចតុក្កៈរបស់ទិដ្ឋិ

| | |
|---|---|
| ១ - អយោនិសោ អភិនិវេសលក្ខណា | មានការប្រកាន់ទុក ដោយមិនត្រូវទំនង ជាលក្ខណៈ |
| ២ - បរាមាសរសា | មានការស្ទាបអង្អែលខុសពីសភាវៈ ជាកិច្ច |
| ៣ - មិច្ឆាភិនិវេសនបច្ចុប្បដ្ឋានា | មានការប្រកាន់មាំ ក្នុងផ្លូវខុស ជាអាការប្រាកដ |
| ៤ - អរិយានំ អទស្សនកាមតាទិ បទដ្ឋានា | មានការមិនចង់ឃើញព្រះអរិយៈជាដើម ជាហេតុជិត។ |

## ៧ - មានចេតសិក (Conceit)

សេយ្យោហមស្មីតិ អាទិនា មញ្ញតីតិ = មានោ ឈ្មោះថា មានៈ ព្រោះអត្ថថា សម្គាល់ខ្លួនដោយលក្ខណៈ មានជាដើមថា "យើងជាអ្នកប្រសើរជាងគេ" ដូច្នេះ ជាដើម។



## មានៈ មាន ២ យ៉ាង

មានៈ ដែលព្រះសោតាបន្នលះ ហៅថា អយាថាវមានៈ មាន ៦ គឺ ៖

| | | |
|---|---|---|
| ១ - ល្អជាងគេ | សម្គាល់ខ្លួនថា | ស្មើនឹងគេ |
| ២ - ល្អជាងគេ | សម្គាល់ខ្លួនថា | ទាបជាងគេ |
| ៣ - ស្មើនឹងគេ | សម្គាល់ខ្លួនថា | ល្អជាងគេ |
| ៤ - ស្មើនឹងគេ | សម្គាល់ខ្លួនថា | ទាបជាងគេ |
| ៥ - ទាបជាងគេ | សម្គាល់ខ្លួនថា | ល្អជាងគេ |
| ៦ - ទាបជាងគេ | សម្គាល់ខ្លួនថា | ស្មើនឹងគេ។ |

មានៈ ដែលព្រះអរហន្តលះ ហៅថា យាថាវមានៈ

មាន ៣ គឺ ៖

១ - ល្អជាងគេ សម្គាល់ថា ល្អជាងគេ

២ - ស្មើនឹងគេ សម្គាល់ថា ស្មើនឹងគេ

៣ - ទាបជាងគេ សម្គាល់ថា ទាបជាងគេ។



ម្យ៉ាងទៀត មានៈ មានវេវចនៈ ច្រើនយ៉ាងដូច្នេះ គឺ ៖

១ - ឈ្មោះថា អតិមានៈ ការមើលងាយ បន្តុះបង្អាប់អ្នកដទៃ

២ - ឈ្មោះថា មានាតិមានៈ សេចក្តីឆ្មើងកន្ទ្រើង ក្រអឺតក្រទម

៣ - ឈ្មោះថា ឱមានៈ ការប្រកាន់ដ៏ថោកទាប

៤ - ឈ្មោះថា អធិមានៈ សម្គាល់ថា សម្រេចធម៌វិសេស

៥ - ឈ្មោះថា អស្មិមានៈ សម្គាល់ថា មានអត្តា (មានតែអញ)

៦ - ឈ្មោះថា មិច្ឆាមានៈ សម្គាល់ខុស។

## លក្ខណាទិចតុក្កៈរបស់មានៈ

១ -ឧន្នតិលក្ខណោ — មានការលើកខ្លួន *(អួតខ្លួន)* ជាលក្ខណៈ

២ - សម្បគ្គហរសោ — មានការលើកតម្កើងខ្លួន *(ប្រកាន់ប្ញក)* ជាកិច្ច

៣ - កេតុកម្យតាបច្ចុប្បដ្ឋានោ — មានសេចក្តីត្រូវការខ្ពស់ ដូចជាទង់ ជាអាការប្រាកដ

៤ - ទិដ្ឋិវិប្បយុត្តលោភបទដ្ឋានោ — មានលោភៈ មិនប្រកប ដោយទិដ្ឋិ ជាហេតុជិត។



មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ១១

ស្កេនដើម្បីមើលមេរៀន
San Sochea Official

## ៨ - ទោសចេតសិក (Hatred)

ទុស្សតីតិ = ទោសោ ឈ្មោះថា ទោសៈ ព្រោះអត្ថថា ប្រទូសរ៉ាយ។

ក្នុងវិសុទ្ធិមគ្គ ពោលថា ទុស្សន្តិ តេន សយំ វា ទុស្សតិ ទុស្សនមត្តមេវ វា តន្តិ = ទោសោ ឈ្មោះថា ទោសៈ ព្រោះអត្ថថា ជាហេតុប្រទូសរ៉ាយសត្វ ឬឈ្មោះថា ទោសៈ ព្រោះអត្ថថា ប្រទូសរ៉ាយខ្លួនឯង ឬថា ត្រឹមតែប្រទូសរ៉ាយប៉ុណ្ណោះ ក៏ឈ្មោះថា ទោសៈ ។

** ទោសៈ នេះគប្បីឃើញដូចជាទឹកមូត្រស្អុយលាយដោយថ្នាំពិស។*

# លក្ខណាទិចតុក្កៈរបស់ទោសៈ

១ - ចណ្ឌិកលក្ខណោ — មានការកាច ជាលក្ខណៈ ដូចអាសិរ្ពិសដែលត្រូវគេវាយ

២ - វិសប្បនរសោ — មានការក្រហល់ក្រហាយ ជាកិច្ច ដូចត្រូវថ្នាំពិសជ្រាបចូល

អត្តនោ និស្សយទហនរសោ វា — ឬមានការដុតកំដៅទីនៅរបស់ខ្លួន ជាកិច្ច ដូចភ្លើងឆេះព្រៃ

៣ - ទុស្សនបច្ចុប្បដ្ឋានោ — មានការប្រទូសរ៉ាយ ជាអាការប្រាកដ ដូចសត្រូវបានឱកាស

៤ - អាឃាតវត្ថុបទដ្ឋានោ — មានអាឃាតវត្ថុ ជាហេតុជិត។



# អាឃាតវត្ថុ ១០

១. គំនុំកើតឡើងថា — ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

២. គំនុំកើតឡើងថា — ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

៣. គំនុំកើតឡើងថា — ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ

៤. គំនុំកើតឡើងថា — ជនឯណោះ បានប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ

៥. គំនុំកើតឡើងថា — ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ

៦. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់បុគ្គល ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់អាត្មាអញ

៧. គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

៨. គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

៩. គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ

១០. សេចក្តីក្រោធកើតឡើងក្នុងទីមិនគួរ ដូចពេលដែលដើរជំពប់ ឬ ជាន់បន្លាជាដើម ។



## ៩ - ឥស្សាចេតសិក (Jealousy)

ឥស្សតីតិ = ឥស្សា ឈ្មោះថា ឥស្សា ព្រោះ ឫស្យា ឬ ច្រណែន។

ឥស្សា នេះច្រណែនគ្នា មិនឲ្យអ្នកដទៃបានលាភសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន និងការបូជាជាដើម។

## លក្ខណាទិចតុក្កៈរបស់ឥស្សា

១ - បរសម្បត្តីនំ ឧស្សូយនលក្ខណា មានការច្រណែនសម្បត្តិ (អ្វីដែលល្អ) របស់អ្នកដទៃ ជាលក្ខណៈ

២ - តត្ថេវ អនភិរតិរសា មានការមិនត្រេកអរក្នុងសម្បត្តិ របស់អ្នកដទៃ ជាកិច្ច

៣ - វិមុខភាវបច្ចុប្បដ្ឋានា មានការបែរមុខចេញ ជាអាការប្រាកដ

៤ - បរសម្បត្តិបទដ្ឋានា មានសម្បត្តិអ្នកដទៃ ជាហេតុជិត ។



## ១០ - មច្ឆរិយចេតសិក (Avarice)

មច្ឆេរស្ស ភាវោ = មច្ឆរិយំ ភាវៈនៃបុគ្គលអ្នកកំណាញ់ ឈ្មោះថា មច្ឆរិយៈ។

យោជនា អធិប្បាយថា៖

ធម្មជាតិដែលប្រព្រឹត្តទៅដោយអាការថា ″សេចក្ដីអស្ចារ្យនេះ ចូរកុំមានដល់ពួកជនដទៃ សេចក្ដីអស្ចារ្យនេះ ចូរមានដល់យើងប៉ុណ្ណោះ‶ ដូច្នេះ ឈ្មោះថា មច្ឆរិយៈ។

** បណ្ឌិតគប្បីឃើញមច្ឆរិយៈថា ជាសេចក្ដីពិការរបស់ចិត្ត ។*

# មច្ឆរិយៈ ៥ យ៉ាង ៖

១ - អាវាសមច្ឆរិយំ សេចក្តីកំណាញ់អាវាស

២ - កុលមច្ឆរិយំ សេចក្តីកំណាញ់ត្រកូល

៣ - លាភមច្ឆរិយំ សេចក្តីកំណាញ់លាភ

៤ - វណ្ណមច្ឆរិយំ សេចក្តីកំណាញ់វណ្ណៈ *(ពណ៌សម្បុរ និងសេចក្តីសរសើរ)*

៥ - ធម្មមច្ឆរិយំ សេចក្តីកំណាញ់ធម៌ *(បរិយត្តិធម៌ និងបដិវេធធម៌)*



# លក្ខណាទិចតុក្កៈរបស់មច្ឆរិយៈ

១ - លទ្ធានំ វា លភិតព្វានំ អត្តនោ សម្បត្តីនំ និគូហណលក្ខណំ មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានហើយ ឬដែលគួរបាន ជាលក្ខណៈ

២ - តាសំយេវ បរេហិ សាធារណភាវអក្ខមនរសំ មានការមិនពេញចិត្ត ក្នុងការឲ្យសម្បត្តិរបស់ខ្លួនទៅជាសាធារណៈដល់ជនដទៃ ជាកិច្ច

៣ - សំកោចនបច្ចុប្បដ្ឋានំ មានការធ្វើមុខក្រញូវ ឬមិនអើពើ ជាអាការប្រាកដ

៤ - អត្តនោ សម្បត្តិបទដ្ឋានំ មានសម្បត្តិរបស់ខ្លួន ជាហេតុជិត។

# ១១ - កុក្កុច្ចចេតសិក (Worry)

កុកតស្ស ភាវោ បវត្តនិមិត្តំ = កុក្កុច្ចំ ភាវៈ គឺនិមិត្ត ជាទីប្រព្រឹត្តទៅនៃកម្មដែលបណ្ឌិតខ្ពើម ឈ្មោះថា កុក្កុច្ចៈ។

កុក្កុច្ចៈ នេះ ជាកង្វល់ចិត្ត ដោយប្រារព្ធកម្ម គឺទុច្ចរិតដែលធ្វើហើយនិង សុចរិតដែលមិនបានធ្វើ ជាកម្មដែលបណ្ឌិតស្អប់។

** គប្បីឃើញកុក្កុច្ចៈនេះ ដូចមនុស្សជាទាសៈ ដែលមិនអាចប្រព្រឹត្តតាមទំនើងចិត្តខ្លួន។*



## លក្ខណាទិចតុក្កៈរបស់កុក្កុច្ចៈ

| | |
|---|---|
| ១ - បច្ចានុតាបនលក្ខណំ | មានការក្តៅក្រហាយចិត្តជាខាងក្រោយ ជាលក្ខណៈ |
| ២ - កតាកតានុសោចនរសំ | មានការសោកសៅរឿយៗក្នុងអំពើបាបដែលធ្វើហើយ និងបុណ្យដែលនៅមិនទាន់បានធ្វើ ជាកិច្ច |
| ៣ - វិប្បដិសារបច្ចុប្បដ្ឋានំ | មានការស្តាយក្រោយ ជាអាការប្រាកដ |
| ៤ - កតាកតបទដ្ឋានំ | មានបាបដែលធ្វើហើយ និងបុណ្យដែលមិនទាន់បានធ្វើ ជាហេតុជិត។ |

មើលវីដេអូ ភាគទី ១២

# ១២ - ថីនចេតសិក (Sloth)

**ថីនតា = ថីនំ** សេចក្ដីរួញរា ឈ្មោះថា ថីនៈ ។

**ថីនៈ** នេះគប្បីឃើញថា ជាធម៌បៀតបៀនចិត្ត ឲ្យថយចាកអារម្មណ៍ ឬជាសភាវធម៌គ្របសង្កត់ចិត្ត ធ្វើឲ្យចិត្តថយកម្លាំង ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## លក្ខណាទិចតុក្កៈរបស់ថីនៈ

| | |
|---|---|
| ១ - អនុស្សាហនលក្ខណំ | មានការមិនឧស្សាហ៍ (ឬមិនអង់អាច) ជាលក្ខណៈ |
| ២ - វីរិយវិនោទនរសំ | មានការកម្ចាត់បង់នូវការព្យាយាម ជាកិច្ច |
| ៣ - សំសីទនបច្ចុប្បដ្ឋានំ | មានការរួញរានៃចិត្ត ជាអាការប្រាកដ |

៤ - អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ
មានអយោនិសោមនសិការៈ ក្នុងការមិនត្រេកអរ និងការរារែក ជាដើម ជាហេតុជិត។

## ១៣ - មិទ្ធចេតសិក (Torpor)

មិជ្ឈនតា = មិទ្ធំ សេចក្ដីងោកងុយ ឈ្មោះថា មិទ្ធៈ។

មិទ្ធៈនេះ ជាសភាវៈធ្វើឲ្យចិត្តស្វាក់ស្ទើរ ខ្ជិល ងងុយដេក ស្វាបជាដើម ។



## លក្ខណាទិចតុក្កៈរបស់មិទ្ធៈ

១ - អកម្មញ្ញតា លក្ខណំ — មានភាពមិនគួរដល់ការងារ (មិនរហ័សរហួន) ជាលក្ខណៈ

២ - ឱនហនរសំ — មានការបិទបាំងសហជាតធម៌ ជាកិច្ច

៣ - លីនតាបច្ចុប្បដ្ឋានំ — មានការរាថយ (រួញរា ងងុយ ងោកងក់) ជាអាការប្រាកដ

៤ - អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ

មានអយោនិសោមនសិការៈ ក្នុងការមិនត្រេកអរ និងការរារែក ជាដើម ជាហេតុជិត។

☛ **ថីនៈ** និង **មិទ្ធៈ** ចេតសិកទាំង ២ នេះ ប្រកបជាមួយនឹងចិត្តដែលជាសសង្ខារិកៈ ៥ ដួង គឺ ក្នុងលោភមូលចិត្ត ៤ និងទោសមូលចិត្ត ១។ ចេតសិកទាំង ២ នេះ កើតរួមគ្នាជានិច្ច ដោយប្រៀប **ថីនៈ** ដូច អណ្តាតភ្លើង **មិទ្ធៈ** ដូច ពន្លឺ បើភ្លើងធំ ពន្លឺក៏ច្បាស់ បើភ្លើងតូច ពន្លឺក៏អន់ថយចុះ។



## ១៤ - វិចិកិច្ឆាចេតសិក (Doubt)

**វិគតា ចិកិច្ឆាតិ = វិចិកិច្ឆា** ឈ្មោះថា វិចិកិច្ឆា ព្រោះអត្ថថា មានសេចក្តីពិតក្នុងចិត្តទៅប្រាសហើយ បានដល់សេចក្តីសង្ស័យ ៨ យ៉ាង គឺ ៖

១ - សង្ស័យក្នុងព្រះពុទ្ធ

២ - សង្ស័យក្នុងព្រះធម៌

៣ - សង្ស័យក្នុងព្រះសង្ឃ

៤ - សង្ស័យក្នុងសិក្ខា

៥ - សង្ស័យក្នុងអតីតធម៌

៦ - សង្ស័យក្នុងអនាគតធម៌

៧ - សង្ស័យក្នុងអតីតធម៌ និងអនាគតធម៌

៨ - សង្ស័យក្នុងបដិច្ចសមុប្បាទ។



## លក្ខណាទិចតុក្កៈវិចិកិច្ឆា

| | |
|---|---|
| ១ - សំសយនលក្ខណា | មានការសង្ស័យ ជាលក្ខណៈ |
| ២ - កម្បនរសា | មានការញាប់ញ័រ (ឃ្លេងឃ្លោង ស្ទាក់ស្ទើរ) ជាកិច្ច |
| ៣ - អវិនិច្ឆយបច្ចុប្បដ្ឋានា | មានការវិនិច្ឆ័យមិនដាច់ ជាអាការប្រាកដ |

អនេកសគាហ បច្ចុប្បដ្ឋានា វា ឬមានការកាន់យកចំណែក តែម្យ៉ាងមិនបាន ជាអាការប្រាកដ

| | |
|---|---|
| ៤ - អយោនិសោមនសិការបទដ្ឋានា | មានអយោនិសោមនសិការៈ ជាហេតុជិត។ |

** គប្បីឃើញថា វិចិកិច្ឆានេះ ជាធម្មជាតិធ្វើនូវសេចក្តីអន្តរាយដល់ការប្រតិបត្តិត្រឹមត្រូវតាមធម៌។*

- **អកុសលចេតសិក ១៤**
  - **មោចតុក្កៈ ៤**
    - មោហចេតសិក ១
    - អហិរិកចេតសិក ១
    - អនោត្តប្បចេតសិក ១
    - ឧទ្ធច្ចចេតសិក ១
  - **លោតិកៈ ៣**
    - លោភចេតសិក ១
    - ទិដ្ឋិចេតសិក ១
    - មានចេតសិក ១
  - **ទោចតុក្កៈ ៤**
    - ទោសចេតសិក ១
    - ឥស្សាចេតសិក ១
    - បច្ឆរិយចេតសិក ១
    - កុក្កុច្ចចេតសិក ១
  - **ថីទុកៈ ២**
    - ថីនចេតសិក ១
    - មិទ្ធចេតសិក ១
  - **ឯកវិចិកិច្ឆា ១**
    - វិចិកិច្ឆាចេតសិក ១



## សរុបអកុសលចេតសិក ១៤ មាន ៥ ន័យ គឺ ៖

១ - មោចតុក្កចេតសិក ៤

២ - លោតិកចេតសិក ៣

៣ - ទោចតុក្កចេតសិក ៤

៤ - ថីទុកចេតសិក ២

៥ - វិចិកិច្ឆាចេតសិក ១

# ចប់ អកុសលចេតសិក

មើលវីដេអូ ភាគទី ១៣

# សោភណចេតសិក ២៥

សោភណចេតសិក ជាចេតសិកផ្នែកល្អ មិនប្រកបជាមួយនឹង អកុសលចិត្ត ១២ និងអហេតុកចិត្ត ១៨ ទេ គឺប្រកបតែជាមួយនឹង ចិត្ត ៥៩ ឬ ៩១ ប៉ុណ្ណោះ។

សោភណចេតសិកចែកចេញជា ៤ ន័យ គឺ៖

១ - សោភណសាធារណចេតសិក ១៩

២ - វិរតិចេតសិក ៣

៣ - អប្បមញ្ញាចេតសិក ២

៤ - បញ្ញាចេតសិក ១

ស្កេនដើម្បីមើលមេរៀន

San Sochea Official



# អធិប្បាយ សោភណសាធារណចេតសិក ១៩

## ១ - សទ្ធាចេតសិក (Well-established confidence)

សទ្ទហតីតិ សទ្ធា ពុទ្ធាទីសុ បសាទោ ធម្មជាតិណា រមែងជឿជាក់ តែងជ្រះថ្លា (ឬទ្រទ្រង់អារម្មណ៍ទុកដោយល្អ) ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សទ្ធា បានដល់សេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធជាដើម។ សទ្ធា បានដល់ការជឿជាក់ ឬសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កម្ម ផលរបស់កម្ម និងសេចក្តីថាសត្វមានកម្មជារបស់ខ្លួន។

# លោកសន្និវាស មានប្រមាណ ៤ ៖

១ - រូបប្បមាណោ — អ្នកកាន់យករូបជាប្រមាណ

២ - ឃោសប្បមាណោ — អ្នកកាន់យកសំឡេងជាប្រមាណ

៣ - លូខប្បមាណោ — អ្នកកាន់យកភាពសៅហ្មងជាប្រមាណ

៤ - ធម្មប្បមាណោ — អ្នកកាន់យកធម៌ជាប្រមាណ។



# លក្ខណាទិចតុក្កៈរបស់សទ្ធា

១ - សទ្ទហនលក្ខណា — មានការជឿជាក់ ជាលក្ខណៈ
ឱកប្បនលក្ខណា វា — ឬមានការជឿមុតមាំ ជាលក្ខណៈ
សម្បក្ខន្ទនលក្ខណា វា — ឬមានការស្ទុះទៅ ជាលក្ខណៈ

២ - សម្បសាទនរសា — មានការធ្វើឲ្យផូរផង់ (ជ្រះថ្លា) ជាកិច្ច ដូចកែវមណីធ្វើទឹកឲ្យថ្លា

៣ - អកាលុស្សិយបច្ចុប្បដ្ឋានា — មានការមិនល្អក់កករ ជាអាការប្រាកដ

៤ - សទ្ធេយ្យវត្ថុបទដ្ឋានា — មានវត្ថុជាទីតាំងនៃសេចក្ដីជឿជាក់ ជាហេតុជិត។

# ចំណាំ

*សទ្ធា ដូចជាដៃ ក្នុងការកាន់យកនូវកុសលទាំងឡាយ ដូចពុទ្ធវចនៈនៅក្នុងមហាវគ្គថា **អបារុតា តេ អមតស្ស ទ្វារា យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ** ទ្វារនៃព្រះនិព្វាននោះបើកហើយ សត្វទាំងឡាយណាមានសោតបសាទ សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ។

*សទ្ធា ដូចជាទ្រព្យ ក្នុងការញ៉ាំងសម្បត្តិទាំងឡាយឲ្យដល់ព្រម ដូចព្រះបរមគ្រូទ្រង់ត្រាស់ថា **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោក។

*សទ្ធា ដូចជាពូជ ក្នុងការបានគ្រាប់កសិផលជាអមតៈ ព្រោះហេតុនោះព្រះបរមគ្រូទ្រង់ត្រាស់ថា **សទ្ធា ពីជំ តបោ វុដ្ឋិ** សទ្ធាដូចគ្រាប់ពូជ តបៈដូចទឹកភ្លៀង។



## សទ្ធា ពីរ យ៉ាង



**ចលសទ្ធា** សទ្ធានៅកម្រើក ឬញាប់ញ័រ (សទ្ធារបស់បុថុជ្ជន)



**អចលសទ្ធា** ឬ **សុបតិដ្ឋិតសទ្ធា** សទ្ធាមិនកម្រើក ឬតាំងមាំស៊ប់ (សទ្ធារបស់ព្រះអរិយៈ)

មើលវីដេអូ ភាគទី ១៤

## ២ - សតិចេតសិក (Mindfulness)

សរណំ = សតិ អសម្មោសោ សេចក្តីរលឹក ឈ្មោះថា សតិ បានដល់សេចក្តីមិនវង្វេងភ្លេច ។

ម្យ៉ាងទៀត សរន្តិ ឯតាយ សយំ វា សរតិ សរណមត្តមេវ វា ឯសាតិ = សតិ បុគ្គលរមែងរលឹកបាន ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សតិ ឬធម្មជាតិនោះ រមែងរលឹកបានខ្លួនឯង ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សតិ ឬថា ធម្មជាតិនោះ ត្រឹមតែជាការរលឹកប៉ុណ្ណោះ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា សតិ គឺ សេចក្តីរលឹកបាន។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



សតិ រលឹកដឹងអំពីពោធិបក្ខិយធម៌ ៣៧ ប្រការតាមសេចក្តីពិត

សតិ មានការពិចារណាការសម្រេចនៃធម៌ដែលជាប្រយោជន៍ និង មិនមែនជាប្រយោជន៍

សតិ ដឹងថា ធម៌មានកាយទុច្ចរិតជាដើម មិនជាប្រយោជន៍ រមែងកាត់បន្ថយនូវធម៌ដែលមិនជាប្រយោជន៍នោះ

សតិ ដឹងថា ធម៌មានកាយសុចរិតជាដើម ជាប្រយោជន៍រមែងចម្រើននូវធម៌ជាប្រយោជន៍នោះ

**សតិ** ប្រៀបដូចនាយបរិនាយកកែវរបស់ស្តេចចក្រពត្តិ ដឹងនូវវត្ថុដែលមិនជាប្រយោជន៍ និងវត្ថុដែលជាប្រយោជន៍ រមែងនាំយកវត្ថុដែលមិនជាប្រយោជន៍ចេញទៅ និងបង្អោននូវវត្ថុដែល ជាប្រយោជន៍ចូលមក។

**សតិ** រមែងរក្សាចិត្តចេញពីអកុសលធម៌ និងញ៉ាំងចិត្តឲ្យប្រកបដោយកុសលធម៌ ប្រៀបដូចមហាអាមាត្យអ្នកធ្វើកិច្ចរបស់ព្រះរាជាឲ្យសម្រេច សមដូចព្រះពុទ្ធវចនៈថា **សតឹ ខ្វាហំ ភិក្ខវេ សព្វត្ថិកំ វទាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតពោល នូវសតិថាមានឧបការច្រើនក្នុងទីទាំងពួង។

**សតិ** គឺជាឈ្មោះនៃ អប្បមាទធម៌។



## លក្ខណាទិចតុក្កៈរបស់សតិ

**១ - អបិលាបនលក្ខណា** មានការរលឹកបាន មិនរវើរវាយ ជាលក្ខណៈ

**២ - អសម្មោសរសា** មានការមិនវង្វេងភ្លេច ជាកិច្ច

**៣ - វិសយាភិមុខភាវបច្ចុប្បដ្ឋានា** មានការប្រាថ្នាចំពោះអារម្មណ៍ (ឬមានការរក្សាទុកនូវអារម្មណ៍មិនឲ្យចេញអំពីចិត្ត) ជាអាការប្រាកដ

**៤ - ថិរសញ្ញាបទដ្ឋានា** មានការចាំប្រាកដ ជាហេតុជិត

**កាយាទិសតិបទដ្ឋានា វា** ឬថា មានសតិប្បដ្ឋាន ដូចជាកាយជាដើម ជាហេតុជិត។

## ៣ - ហិរិចេតសិក [ (Moral) Shame ]

ហិរិយតិ កាយទុច្ចរិតាទីហិ ជិគុច្ឆតីតិ = ហិរិ ធម្មជាតិ ដែលឈ្មោះថា ហិរិ ព្រោះអត្ថថា ខ្មាស គឺ រង្កៀសចំពោះទុច្ចរិត មានកាយទុច្ចរិតជាដើម។ ហិរិ ការខ្មាស ឬខ្ពើមអំពើបាបរបស់ខ្លួនឯង ប្រៀបដូចបុគ្គលមិនចង់ចាប់កាន់ដុំដែក (មិនក្តៅ) ដែលប្រឡាក់ដោយមន្ទិលមានលាមកជាដើម។



## លក្ខណាទិចតុក្កៈរបស់ហិរិ

| | |
|---|---|
| ១ - បាបតោ ជិគុច្ឆនលក្ខណា | មានការរង្កៀសចំពោះបាប ជាលក្ខណៈ |
| ២ - បាបានំ អករណរសា | មានការមិនធ្វើបាប ជាកិច្ច |
| ៣ - បាបតោ សង្កោចនបច្ចុប្បដ្ឋានា | មានការថយចាកពីបាប ជាអាការប្រាកដ |
| ៤ - អត្តគារវបទដ្ឋានា | មានការគោរពខ្លួនឯង ជាហេតុជិត។ |

## ៤ - ឱត្តប្បចេតសិក [ (Moral) Dread ]

តេហិយេវ ឱត្តប្បតីតិ = ឱត្តប្បំ ធម្មជាតិណា រមែងក្រែងខ្លាចចំពោះទុច្ចរិតទាំងនោះឯង ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ឱត្តប្បៈ។

ឱត្តប្បៈ ការខ្លាចចំពោះបាប ប្រៀបដូចបុគ្គលមិនហ៊ានចាប់ កាន់ដុំដែកដែលគេដុតឲ្យក្តៅ។



## លក្ខណាទិចតុក្កៈរបស់ឱត្តប្បៈ

| | |
|---|---|
| ១ - ឧត្តាសលក្ខណំ | មានការតក់ស្លុតចំពោះបាប ជាលក្ខណៈ |
| ២ - បាបានំ អករណរសំ | មានការមិនធ្វើបាប ជាកិច្ច |
| ៣ - បាបតោ សង្កោចនបច្ចុប្បដ្ឋានំ | មានការថយចាកបាប ជាអាការប្រាកដ |
| ៤ - បរគារវបទដ្ឋានំ | មានការគោរពអ្នកដទៃ ជាហេតុជិត។ |

មើលវីដេអូ ភាគទី ១៥

* *ហិរិ មានការគោរពខ្លួន ទើបមិនធ្វើបាប ដោយខ្មាស ដូចស្រីក្រមុំមានត្រកូលល្អរង្កៀស (ខ្ពើម) វត្ថុបដិកូលចំណែក*

* *ឱត្តប្បៈ មានការគោរពអ្នកដទៃ ទើបមិនហ៊ានធ្វើបាប ព្រោះការក្រែងខ្លាច ដូចស្រីពេស្យា មានការក្រែងខ្លាចអ្នកដទៃ។*

* *ហិរិ និង ឱត្តប្បៈ នេះ លោកហៅថា លោកបាលធម៌ (ធម៌តែងរក្សានូវសត្វលោក) ជាធម៌យ៉ាងស្ងប់ មិនរាយមាយ។*

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## ៥ - អលោភចេតសិក (Non-attachment)

លោភបដិបក្ខោ = អលោភោ ធម៌ដែលបដិបក្ខនឹងលោភៈ ឈ្មោះថា អលោភៈ។

*ម្យ៉ាងទៀត* ន លុព្ភន្តិ តេន សយំ វា ន លុព្ភតិ អលុព្ភនមត្តមេវ វា តន្តិ = អលោភោ សត្វទាំងឡាយ មិនលោភដោយធម៌នោះ ហេតុនោះ ធម៌នោះ ឈ្មោះថា អលោភៈ ឬធម៌ណា ខ្លួនឯងមិនលោភ ធម៌នោះ ក៏ឈ្មោះថា អលោភៈ ឬថា ធម៌នោះ ត្រឹមតែមិនលោភប៉ុណ្ណោះ ក៏ឈ្មោះថា អលោភៈ។

# លក្ខណាទិចតុក្កៈរបស់អលោភៈ

១ - អលគ្គភាវលក្ខណោ — មានការមិនជាប់ជំពាក់នឹងអារម្មណ៍ ជាលក្ខណៈ

*ដូចដំណក់ទឹក មិនជាប់នឹងស្លឹកឈូក*

២ - អបរិគ្គហរសោ — មានការមិនហួងហែង ជាកិច្ច

៣ - អនល្លីនភាវបច្ចុប្បដ្ឋានោ — មានការមិនប្រកាន់មាំក្នុងអារម្មណ៍ ជាអាការប្រាកដ

*ដូចអ្នកធ្លាក់ទៅក្នុងរណ្ដៅលាមក*

៤ - យោនិសោមនសិការបទដ្ឋានោ — មានយោនិសោមនសិការៈ ជាហេតុជិត។

120

## ៦ - អទោសចេតសិក (Goodwill)

ទោសបដិបក្ខោ = អទោសោ ធម៌ដែលបដិបក្ខនឹងទោសៈ ឈ្មោះថា អទោសៈ។ សេចក្ដីក្រៅពីនេះ មានការវិនិច្ឆ័យស្រដៀង នឹង អលោភៈ។ មេត្តា ក្នុងព្រហ្មវិហារធម៌ អង្គធម៌គឺ អទោសៈ ហ្នឹងឯង។

## លក្ខណាទិចតុក្កៈរបស់អទោសៈ

១ - អចណ្ឌិក្កលក្ខណោ មានការមិនកាច ជាលក្ខណៈ *ដូចមិត្តអ្នកអនុគ្រោះប្រយោជន៍*

២ - អាឃាតវិនយរសោ មានការកម្ចាត់អាឃាត (ឬមានការមិនចងគំនុំ) ជាកិច្ច

៣ - សោមភាវបច្ចុប្បដ្ឋានោ មានសេចក្តីត្រជាក់ ជាអាការប្រាកដ *ដូចព្រះចន្ទពេញវង់*

៤ - យោនិសោមនសិការបទដ្ឋានោ មានយោនិសោមនសិការ ជាហេតុជិត។



## ៧ - តត្រមជ្ឈត្តតាចេតសិក (Equanimity)

តេសុ តេសុ ធម្មេសុ មជ្ឈត្តតា = តត្រមជ្ឈត្តតា

ភាពជាកណ្តាលក្នុងធម៌នោះៗ ឈ្មោះថា តត្រមជ្ឈត្តតា។

## លក្ខណាទិចតុក្កៈរបស់តត្រមជ្ឈត្តតា

| | |
|---|---|
| ១ - ចិត្តចេតសិកានំ សមវាហិតលក្ខណា | មានការនាំចិត្តនិងចេតសិកទៅដោយស្មើជានិច្ច (ឬមានការទ្រទ្រង់ចិត្តនិងចេតសិកឲ្យស្មើ) ជាលក្ខណៈ |
| ២ - ឩនាធិកតានិវារណរសា | មានការហាមនូវភាពលើសខ្វះគ្នាជាកិច្ច |
| ៣ - មជ្ឈត្តភាវបច្ចុប្បដ្ឋានា | មានភាពជាកណ្តាល ជាអាការប្រាកដ |
| ៤ - សម្បយុត្តបទដ្ឋានា | មានសម្បយុត្តធម៌ ជាហេតុជិត ។ |



*តត្រមជ្ឈត្តតាចេតសិក នេះ មានន័យច្រើន បណ្ឌិតគប្បីឃើញដោយភាពព្រងើយនៃចិត្ត និងចេតសិកទាំងឡាយ ដូចសារថី សម្លឹងមើលព្រងើយៗ នូវសេះអាជានេយ្យដែលរត់ទៅស្មើល្អហើយ ដូច្នោះ។*

មើលវីដេអូ ភាគទី ១៦

# យុគលធម៌ ៦ គូ

## យុគលធម៌គូទី ១ : ៨-កាយបស្សទ្ធិ ៩-ចិត្តបស្សទ្ធិ

**(Tranquility of mental states and Tranquility of mind)**

ពាក្យថា **កាយបស្សទ្ធិ** បានដល់ សេចក្តីស្ងប់នាមខន្ធ ៣ គឺ វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ **ចិត្តបស្សទ្ធិ** បានដល់ ស្ងប់វិញ្ញាណក្ខន្ធ។

**កាយស្ស បស្សម្ភនំ** = **កាយបស្សទ្ធិ** សេចក្តីស្ងប់កាយ (នាមខន្ធ ៣) ឈ្មោះថា កាយបស្សទ្ធិ។ **ចិត្តស្ស បស្សម្ភនំ** = **ចិត្តបស្សទ្ធិ** សេចក្តីស្ងប់ចិត្ត (វិញ្ញាណក្ខន្ធ) ឈ្មោះថា **ចិត្តបស្សទ្ធិ**។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## លក្ខណាទិចតុក្កៈរបស់បស្សទ្ធិ

១ - **កាយចិត្តានំ ទរថវូបសមលក្ខណា** មានការស្ងប់កាយ (នាមខន្ធ ៣) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាលក្ខណៈ

២ - **កាយចិត្តទរថនិម្មទ្ទនរសា** មានការកម្ចាត់បង់ភាពក្តៅក្រហាយរបស់កាយ និងចិត្ត ជាកិច្ច

៣ - **កាយចិត្តានំ អបរិប្ផន្ទនសីតិភាវបច្ចុប្បដ្ឋានា** មានភាពស្ងប់ត្រជាក់មិនក្តៅផ្សាវនៃកាយ និងចិត្ត ជាអាការប្រាកដ

៤ - **កាយចិត្តបទដ្ឋានា** មានកាយ (វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ) និង ចិត្ត (វិញ្ញាណក្ខន្ធ) ជាហេតុជិត ។

*បស្សទ្ធិ ជាបដិបក្ខនឹង ឧទ្ធច្ចៈ។*

## យុគលធម៌គូទី ២ :  ១០ - កាយលហុតា ១១ - ចិត្តលហុតា

(Lightness of mental states and Lightness of mind)

កាយស្ស លហុភាវោ = កាយលហុតា សេចក្តីស្រាលនៃកាយ ឈ្មោះថា កាយលហុតា។

ចិត្តស្ស លហុភាវោ = ចិត្តលហុតា សេចក្តីស្រាលនៃចិត្ត ឈ្មោះថា ចិត្តលហុតា។



## លក្ខណាទិចតុក្កៈរបស់លហុតា

| | |
|---|---|
| ១ - កាយចិត្តគរុភាវវូបសមលក្ខណា | មានការស្ងប់ភាពធ្ងន់របស់កាយនិង ចិត្ត ជាលក្ខណៈ |
| ២ - កាយចិត្តគរុភាវនិម្មទ្ទនរសា | មានការកម្ចាត់បង់ភាពធ្ងន់របស់កាយ និងចិត្ត ជាកិច្ច |
| ៣ - កាយចិត្តានំ អទន្ធតាបច្ចុប្បដ្ឋានា | មានការមិនយឺតយូរ (រហ័សរហួន) របស់កាយ និង ចិត្ត ជាអាការប្រាកដ |
| ៤ - កាយចិត្តបទដ្ឋានា | មានកាយ និងចិត្ត ជាហេតុជិត។ |

*លហុតា ជាបដិបក្ខនឹង ថីនមិទ្ធៈ។*

# យុគលធម៌គូទី ៣ : ១២ - កាយមុទុតា ១៣ - ចិត្តមុទុតា

(Pliancy of mental states and Pliancy of mind)

កាយស្ស មុទុភាវោ = កាយមុទុតា ភាពទន់ភ្លន់នៃកាយ ឈ្មោះថា កាយមុទុតា។

ចិត្តស្ស មុទុភាវោ = ចិត្តមុទុតា ភាពទន់ភ្លន់នៃចិត្ត ឈ្មោះថា ចិត្តមុទុតា។



## លក្ខណាទិចតុក្កៈរបស់មុទុតា

| | |
|---|---|
| ១ - កាយចិត្តថទ្ធភាវរូបសមលក្ខណា | មានការស្ងប់ភាពរឹងត្អឹងរបស់កាយ និង ចិត្ត ជាលក្ខណៈ |
| ២ - កាយចិត្តថទ្ធភាវនិម្មទ្ទនរសា | មានការកម្ចាត់បង់ភាពរឹងត្អឹងរបស់កាយ និងចិត្ត ជាកិច្ច |
| ៣ - អប្បដិឃាតបច្ចុប្បដ្ឋានា | មានភាពមិនជំទាស់ (មិនចង្អៀតចង្អល់) ជាអាការប្រាកដ |
| ៤ - កាយចិត្តបទដ្ឋានា | មានកាយ និងចិត្ត ជាហេតុជិត។ |

*មុទុតា ជាបដិបក្ខនឹង មានៈ។*

## យុគលធម៌គូទី ៤ : ១៤ - កាយកម្មញ្ញតា ១៥ - ចិត្តកម្មញ្ញតា

(Adaptability of mental states and Adaptability of mind)

កាយស្ស កម្មញ្ញភាវោ = កាយកម្មញ្ញតា សេចក្ដីគួរដល់ការងារនៃកាយ ឈ្មោះថា កាយកម្មញ្ញតា។

ចិត្តស្ស កម្មញ្ញភាវោ = ចិត្តកម្មញ្ញតា សេចក្ដីគួរដល់ការងារនៃចិត្តឈ្មោះថា ចិត្តកម្មញ្ញតា។



## លក្ខណាទិចតុក្កៈរបស់កម្មញ្ញតា

១ - កាយចិត្តានំ អកម្មញ្ញភាវវូបសមលក្ខណា មានការរម្ងាប់កាយ និងចិត្ត ដែលមិនគួរដល់ការងារ ជាលក្ខណៈ

២ - កាយចិត្តកម្មញ្ញភាវនិម្មទ្ទនរសា មានការកម្ចាត់បង់នូវភាពមិនគួរដល់ការងាររបស់ កាយនិងចិត្ត ជាកិច្ច

៣ - កាយចិត្តានំ អារម្មណករណសម្បត្តិបច្ចុប្បដ្ឋានា មានការដល់ព្រមក្នុងការធ្វើអារម្មណ៍ឲ្យកាយ និងចិត្ត ជាអាការប្រាកដ

៤ - កាយចិត្តបទដ្ឋានា មានកាយ និងចិត្ត ជាហេតុជិត។

*កម្មញ្ញតា ជាបដិបក្ខនឹង នីវរណៈដែលនៅសល់។*

## យុគលធម៌គូទី ៥ : ១៦ - កាយបាគុញ្ញតា ១៧ - ចិត្តបាគុញ្ញតា

(Proficiency of mental states and Proficiency of mind)

កាយស្ស បាគុញ្ញភាវោ = កាយបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃកាយ ឈ្មោះថា កាយបាគុញ្ញតា។

ចិត្តស្ស បាគុញ្ញភាវោ = ចិត្តបាគុញ្ញតា ការស្ទាត់ជំនាញ (ឈ្លាស) នៃចិត្ត ឈ្មោះថា ចិត្តបាគុញ្ញតា។



## លក្ខណាទិចតុក្កៈរបស់បាគុញ្ញតា

| | |
|---|---|
| ១ - កាយចិត្តានំ គេលញ្ញវូបសមលក្ខណា | មានការស្ងប់នូវអាពាធនៃកាយ និង ចិត្ត ជាលក្ខណៈ |
| ២ - កាយចិត្តគេលញ្ញនិម្មទ្ទនរសា | មានការកម្ចាត់បង់នូវអាពាធនៃកាយ និង ចិត្ត ជាកិច្ច |
| ៣ - និរាទីនវបច្ចុប្បដ្ឋានា | មានការប្រាសចាកទោស ជាអាការប្រាកដ |
| ៤ - កាយចិត្តបទដ្ឋានា | មានកាយ និងចិត្ត ជាហេតុជិត។ |

*បាគុញ្ញតា ជាបដិបក្ខនឹង អស្សទ្ធា (ការមិនមានសទ្ធា) ដែលជាអាពាធនៃចិត្តនិងចេតសិក។*

# យុគលធម៌គូទី ៦ : ១៨ - កាយុជុកតា ១៩ - ចិត្តុជុកតា

(Rectitude of mental states and Rectitude of mind)

កាយស្ស ឧជុកភាវោ = កាយុជុកតា សេចក្តីស្មោះត្រង់នៃកាយ ឈ្មោះថា កាយុជុកតា។

ចិត្តស្ស ឧជុកភាវោ = ចិត្តុជុកតា សេចក្តីស្មោះត្រង់នៃចិត្ត ឈ្មោះថា ចិត្តុជុកតា។



## លក្ខណាទិចតុក្កៈរបស់ឧជុកតា

| | |
|---|---|
| ១ - កាយចិត្តានំ អជ្ជវ លក្ខណា | មានភាពស្មោះត្រង់នៃកាយ និង ចិត្ត ជាលក្ខណៈ |
| ២ - កាយចិត្តកុដិលភាវនិម្មទ្ទនរសា | មានការកម្ចាត់បង់នូវសេចក្តីមិនស្មោះត្រង់នៃកាយ និង ចិត្ត ជាកិច្ច |
| ៣ - អជិម្ហតាបច្ចុប្បដ្ឋានា | មានភាពត្រង់របស់កាយ និង ចិត្ត ជាអាការប្រាកដ |
| ៤ - កាយចិត្តបទដ្ឋានា | មានកាយ និងចិត្ត ជាហេតុជិត។ |

*ឧជុកតា ជាបដិបក្ខនឹង មាយា និង សាថេយ្យៈ។*

មើលវីដេអូ ភាគទី ១៧

# វិរតិចេតសិក ៣ (Abstinences)

១ - សម្មាវាចាចេតសិក បានដល់ វាចាប្រព្រឹត្ត

២ - សម្មាកម្មន្តចេតសិក បានដល់ ការងារប្រព្រឹត្ត

៣ - សម្មាអាជីវចេតសិក បានដល់ អាជីវៈប្រព្រឹត្ត

ស្កេនដើម្បីមើលមេរៀន

San Sochea Official



# ២០ - សម្មាវាចាចេតសិក (Right speech)

សម្មា វទន្តិ ឯតាយាតិ = សម្មាវាចា វចីទុច្ចរិតវិរតិ វិរតិ ឈ្មោះថា សម្មាវាចា ព្រោះអត្ថថា ជាការនិយាយដោយប្រព្រឹត្តនៃបុគ្គល បានដល់ ការវៀរចាកវចីទុច្ចរិត ៤។

# សម្មាវាចា ៤

១ - ចេតនាវៀរចាកការនិយាយកុហក ឆបោក

២ - ចេតនាវៀរចាកការនិយាយញុះញង់ បំបែកបំបាក់

៣ - ចេតនាវៀរចាកការនិយាយពាក្យអាក្រក់ ជេរប្រទេច

៤ - ចេតនាវៀរចាកការនិយាយរោយរាយ ឥតប្រយោជន៍



# លក្ខណាទិចតុក្កៈរបស់សម្មាវាចា

១ - វចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណា មានការមិនកន្លងវត្ថុដែលជាទីតាំងនៃវចីទុច្ចរិត ជាលក្ខណៈ

២ - វចីទុច្ចរិតវត្ថុតោ សង្កោចនរសា មានការថយចាកវត្ថុដែលជាទីតាំងនៃវចីទុច្ចរិត ជាកិច្ច

៣ - តស្ស អក្រិយបច្ចុប្បដ្ឋានា មានការមិនធ្វើនូវវចីទុច្ចរិតនោះជាអាការប្រាកដ

៤ - សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានា មានគុណ គឺសទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិច ជាដើម ជាហេតុជិត។

# ២១ - សម្មាកម្មន្តចេតសិក (Right action)

## សម្មា បវត្តោ កម្មន្តោ = សម្មាកម្មន្តោ កាយទុច្ចរិតវិរតិ

ការងារដែលប្រព្រឹត្តទៅដោយប្រពៃ ឈ្មោះថា សម្មាកម្មន្តៈ បាន ដល់ ចេតនាជាគ្រឿងវៀរចាកកាយទុច្ចរិត។

### សម្មាកម្មន្តៈ ៣

១ - ចេតនាវៀរចាក ការសម្លាប់សត្វ

២ - ចេតនាវៀរចាក ការលួចទ្រព្យគេ

៣ - ចេតនាវៀរចាក ការប្រព្រឹត្តខុសក្នុងកាម



## លក្ខណាទិចតុក្កៈរបស់សម្មាកម្មន្តៈ

១ - កាយទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ

មានការមិនកន្លងវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាលក្ខណៈ

២ - កាយទុច្ចរិតវត្ថុតោ សង្កោចនរសោ

មានការថយចាកវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាកិច្ច

៣ - តស្ស អក្រិយបច្ចុប្បដ្ឋានោ

មានការមិនធ្វើកាយទុច្ចរិតនោះ ជាអាការប្រាកដ

៤ - សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានោ

មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើម ជាហេតុជិត។

## ២២ - សម្មាអាជីវចេតសិក (Right livelihood)

សម្មា អាជីវន្តិ ឯតេនាតិ = សម្មាអាជីវោ មិច្ឆាជីវវិរតិ វិរតិ ឈ្មោះថា សម្មាអាជីវៈ ព្រោះអត្ថថា ជាគ្រឿងចិញ្ចឹមជីវិតដោយប្រពៃនៃសត្វទាំងឡាយ បានដល់ ចេតនាវៀរចាកមិច្ឆាអាជីវៈ។

សម្មាអាជីវៈ មាន ៧ យ៉ាង គឺ វៀរចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ដែលមានអាជីវៈជាហេតុ ឬមានច្រើនយ៉ាង ដោយអំណាចនៃការវៀរចាកការកុហក បោកបញ្ឆោតជាដើម។



## មិច្ឆាជីវៈ (ការចិញ្ចឹមជីវិតខុស) ៥ យ៉ាង ៖

១ - សត្ថវណិជ្ជា ការជួញគ្រឿងសស្ត្រាវុធសម្រាប់ប្រហារ គឺធ្វើគ្រឿងសស្ត្រាវុធដោយខ្លួនឯង ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះៗ។

២ - សត្តវណិជ្ជា ជួញមនុស្ស (សត្វ)។

៣ - មំសវណិជ្ជា ជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយ មានជ្រូកជាដើម លុះសត្វទាំងនោះចម្រើនធំឡើងក៏សម្លាប់យកសាច់លក់។

៤ - មជ្ជវណិជ្ជា ការជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយឲ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ។

៥ - វិស វណិជ្ជា ការជួញថ្នាំពិស គឺចាត់ចែងនូវថ្នាំពិសឲ្យកើតឡើងដោយខ្លួនឯង ឬឲ្យគេផ្សំឲ្យ ឬបានមកដោយហេតុណាមួយ ហើយលក់នូវថ្នាំពិសនោះ។

# លក្ខណាទិចតុក្កៈរបស់សម្មាអាជីវៈ

១ - តិវិធកាយទុច្ចរិតចតុព្វិធវចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ

មានការមិនកន្លងវត្ថុដែលជាទីតាំងនៃ កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាលក្ខណៈ

២ - តេសំ វត្ថុតោ សង្កោចនរសោ

មានការថយចាកវត្ថុដែលជាទីតាំងនៃ កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាកិច្ច

៣ - តេសំ ទុច្ចរិតានំ អក្រិយបច្ចុប្បដ្ឋានោ

មានការមិនធ្វើទុច្ចរិតនោះ ជាអាការប្រាកដ

៤ - សទ្ធាហិរោត្តប្បាទិគុណបទដ្ឋានោ

មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ ជាដើម ជាហេតុជិត។



# អធិប្បាយវិរតិ ៣

ភាវៈនៃការវៀរចាកបាប ឈ្មោះថា វិរតិចេតនា ឬ ហៅថា វិរតិ មាន ៣ ប្រភេទ គឺ ៖

១- សម្បត្តវិរតិ ២-សមាទានវិរតិ ៣-សមុច្ឆេទវិរតិ

សម្បត្តវិរតិ បានដល់ ការវៀរចាកបាប ដោយអធ្យាស្រ័យរបស់ខ្លួនដូចក្នុងខណៈ ដែលកំពុងមានវិរមិតព្វវត្ថុ (វត្ថុត្រូវវៀរ) ប្រាកដចំពោះមុខហើយ ក៏មិនប្រព្រឹត្តកន្លង។

សមាទានវិរតិ បានដល់ ការវៀរចាកបាប ដោយសមាទាន (ការកាន់យក ឬរៀនយក ដោយល្អ) នូវសិក្ខាបទដែលបញ្ញត្តទុក មាននិច្ចសីល និងឧបោសថសីល ជាដើម។

សមុច្ឆេទវិរតិ បានដល់ ការវៀរចាកបាប ដែលកាត់ផ្តាច់ជាសមុច្ឆេទ ដោយអរិយមគ្គ។

មើលវីដេអូ ភាគទី ១៨

# អប្បមញ្ញាចេតសិក ២

## ១ - ករុណាចេតសិក ២ - មុទិតាចេតសិក

អប្បមាណេសុ សត្តេសុ ភវតីតិ = អប្បមញ្ញា ធម្មជាតិឈ្មោះថា អប្បមញ្ញា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងសត្វមិនមានប្រមាណ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## ២៣ - ករុណាចេតសិក (Compassion)

បរទុក្ខេ សតិ សាធូនំ ហទយខេទំ ករោតីតិ = ករុណា ធម្មជាតិណា កាលសត្វដទៃមានទុក្ខ រមែងធ្វើនូវសេចក្តីអាណិតអាសូរដល់សាធុជនទាំងឡាយ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ករុណា។

ករុណា មាន ទុក្ខិតសត្តប្បញ្ញត្តិ (សេចក្តីទុក្ខរបស់សត្វ) ជាអារម្មណ៍។

# លក្ខណាទិចតុក្កៈរបស់ករុណា

| | |
|---|---|
| ១ - បរទុក្ខាបនយកាមតាលក្ខណា | មានសេចក្តីប្រាថ្នាជួយបំបាត់ទុក្ខអ្នកដទៃ (អាណិតអាសូរ) ជាលក្ខណៈ |
| ២ - បរទុក្ខាសហនរសា | មានការអត់ធន់មិនបានចំពោះសេចក្តីទុក្ខអ្នកដទៃ ជាកិច្ច |
| ៣ - អវិហឹសា បច្ចុប្បដ្ឋានា | មានការមិនបៀតបៀន ជាអាការប្រាកដ |
| ៤ - ទុក្ខាភិភូតានំ អានាថភាវទស្សនបទដ្ឋានា | មានការឃើញសត្វដែលទុក្ខគ្របសង្កត់ហើយមិនមានទីពឹង ជាហេតុជិត។ |



## សម្បត្តិ និង វិបត្តិ របស់ករុណា ៖

| | |
|---|---|
| វិហឹសូបសមោ សម្បត្តិ | មានការចូលទៅរម្ងាប់នូវសេចក្តីបៀតបៀន ជាសម្បត្តិ |
| សោកសម្ភវោ វិបត្តិ | មានការកើតឡើង នៃសេចក្តីសោក (ងាយនឹងឲ្យសោកកើតឡើង) ជាវិបត្តិ |
| គេហសិតំ ទោមនស្សំ អាសន្នបច្ចត្ថិកា | មានទោមនស្ស (ការខូចចិត្ត) ដែលអាស្រ័យកាមគុណ ជាសត្រូវជិត |
| វិហឹសា ទូរបច្ចត្ថិកា | មានការបៀតបៀនសត្វ ជាសត្រូវឆ្ងាយ។ |

# ២៤ - មុទិតាចេតសិក

(Appreciative or Sympathetic joy)

**មោទន្តិ ឯតាយាតិ = មុទិតា** បុគ្គលរមែង ត្រេកអរ (ចំពោះសេចក្តីសុខ ឬសម្បត្តិរបស់អ្នកដទៃ) ដោយធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **មុទិតា**។

**មុទិតា** មាន **សុខិតសត្តបញ្ញត្តិ** (សេចក្តីសុខ ឬសម្បត្តិរបស់សត្វ) ជាអារម្មណ៍។



## លក្ខណាទិចតុក្កៈរបស់មុទិតា

| | |
|---|---|
| **១ - បរសម្បត្តិអនុមោទនលក្ខណា** | មានការត្រេកអររីករាយ (សរសើរ) ចំពោះសម្បត្តិរបស់អ្នកដទៃ ជាលក្ខណៈ |
| **២ - អនិស្សាយនរសា** | មានការមិនច្រណែន ជាកិច្ច |
| **៣ - អរតិវិឃាតបច្ចុប្បដ្ឋានា** | មានការកម្ចាត់បង់នូវអរតិ (ការមិនត្រេកអរ) ជាអាការប្រាកដ |
| **៤ - បរសម្បត្តិទស្សនបទដ្ឋានា** | មានការឃើញសម្បត្តិរបស់សត្វដទៃ ជាហេតុជិត។ |

## សម្បត្តិ និង វិបត្តិ របស់ មុទិតា ៖

**អរតិវូបសមោ សម្បត្តិ** មានការចូលទៅរម្ងាប់នូវអរតិ (សេចក្តីមិនត្រេកអរ) ជាសម្បត្តិ

**បហាសសម្ភវោ វិបត្តិ** មានការសើចសប្បាយ (ក្អាកក្អាយ ភ្លើតភ្លើន) ជាវិបត្តិ

**គេហសិតំ សោមនស្សំ អាសន្នបច្ចត្ថិកា** មានសោមនស្សដែលអាស្រ័យនឹងកាមគុណ ជាសត្រូវជិត

**អរតិទូរបច្ចត្ថិកា** មានការមិនត្រេកអរ (នឹងសុខ ឬសម្បត្តិរបស់អ្នកដទៃ) ជាសត្រូវឆ្ងាយ។



## អប្បមញ្ញា (ឬព្រហ្មវិហារ) ៤

**១- មេត្តា** អង្គធម៌ គឺ អទោសចេតសិក

**២- ករុណា** អង្គធម៌ គឺ ករុណាចេតសិក

**៣- មុទិតា** អង្គធម៌ គឺ មុទិតាចេតសិក

**៤- ឧបេក្ខា** អង្គធម៌ គឺ តត្រមជ្ឈត្តតាចេតសិក។

មើលវីដេអូ ភាគទី ១៩

# ២៥ - បញ្ញិន្ទ្រិយចេតសិក ១ (Wisdom)

បជានាតីតិ = បញ្ញា ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងទូទៅ គឺ ដឹងអរិយសច្ចៈជាដើម បញ្ញានុ៎ះឯង ជាឥន្ទ្រិយ (ជាធំក្នុងការដឹងច្បាស់នូវសភាវធម៌) ព្រោះហេតុនោះ ទើបឈ្មោះថា បញ្ញិន្ទ្រិយ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

156

## លក្ខណាទិចតុក្កៈរបស់បញ្ញា

១ - ធម្មសភាវបដិវេធលក្ខណា

មានការចាក់ធ្លុះសភាវៈនៃធម៌ ជាលក្ខណៈ

២ - ធម្មានំ សភាវបដិច្ឆាទកមោហន្ធការវិទ្ធំសនរសា

មានការកម្ចាត់បង់នូវភាពងងឹត គឺមោហៈ ដែលបិទបាំងសភាវធម៌ជាកិច្ច

៣ - អសម្មោហបច្ចុប្បដ្ឋានា

មានការមិនវង្វេង ជាអាការប្រាកដ (ដូចមគ្គុទ្ទេសក៍ដ៏ចំណាន)

៤ - សមាធិបទដ្ឋានា មានសមាធិ ជាហេតុជិត។

# លក្ខណាទិចតុក្កៈរបស់បញ្ញា (ន័យម្យ៉ាងទៀត)

១ - យថាភូតបដិវេធលក្ខណា មានការចាក់ធ្លុះ (ដឹងច្បាស់) នូវធម៌តាមសេចក្ដីពិត ជាលក្ខណៈ

២ - វិសយោភាសនរសា មានការធ្លុះបញ្ចាំងនូវអារម្មណ៍ឲ្យភ្លឺច្បាស់ ជាកិច្ច (ដូចប្រទីប ជាគ្រឿងបំភ្លឺ)

៣ - អសម្មោហបច្ចុប្បដ្ឋានា មានការមិនវង្វេង ជាអាការប្រាកដ

៤ - យោនិសោមនសិការបទដ្ឋានា មានយោនិសោមនសិការៈជាហេតុជិត។

តិហេតុកបដិសន្ធិកតាបទដ្ឋានា វា ឬមានតិហេតុកបដិសន្ធិជាហេតុជិត។



បញ្ញាចេតសិក នេះ កាលកើតឡើង រមែងដឹងទូទៅដល់ធម៌ទាំងដែលជា កុសល អកុសល ធម៌ដែលគួរសេព ធម៌ដែលមិនគួរសេព ដឹងធម៌ដែលអាក្រក់ ធម៌ដែលប្រណីត ធម៌ដែលចូលគ្នាបាន និងធម៌ដែលចូលគ្នាមិនបាន ដូចពេទ្យអ្នកមានជំនាញអាចផ្សំភេសជ្ជៈគឺថ្នាំ ដែលជាទីសប្បាយដល់អ្នកជម្ងឺជាដើម ដូច្នោះ ។

មើលវីដេអូ ភាគទី ២០

# ការរួបរួមចេតសិក ចូលជាមួយនឹងចិត្ត

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## ចិត្តមាន៤ប្រភេទគឺ

១-កាមាវចរចិត្ត ៥៤ ដួង

២-រូបាវចរចិត្ត ១៥ ដួង

៣-អរូបាវចរចិត្ត ១២ ដួង

៤-លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង

សរុបត្រូវជា ៨៩ ដួង ឬ ១២១ ដួង

# កាមាវចរចិត្ត ៥៤ ចែកជា ២ ប្រភេទ

១- អសោភណចិត្តមាន ៣០ ដួង
២- សោភណចិត្តមាន ២៤ ដួង








# លោភមូលចិត្ត ៨ ដួង

## Consciousness Rooted in Attachment

## ១-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

លោភមូលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ(មិច្ឆាទិដ្ឋិទាំងអស់) មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានអ្នកដទៃបបួលដឹកនាំ។

Consciousness, unprompted, accompanied by pleasure, and connected with wrong view.



## ១- សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

មានចេតសិកកើតរួមជាមួយ ១៩ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក: ៤
- លោតិក: ២ គឺ លោភោ និង ទិដ្ឋិ (វៀរមានៈ)



## ២-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

# លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំពីអ្នកដទៃ ។

Consciousness, prompted, accompanied by pleasure, and connected with wrong view.



## ២- សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ




មានចេតសិកកើតរួមជាមួយ ២១ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក្កៈ ៤
- លោតិកៈ ២ (វៀរមានៈ)
- ថីទុកៈ ២ គឺ ថីនៈ មិទ្ធៈ

## ៣- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

Consciousness, unprompted, accompanied by pleasure, and disconnected with wrong view.



## ៣- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

មានចេតសិកកើតរួមជាមួយ ១៩ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក្កៈ ៤
- លោភិកៈ ២ គឺ លោភៈ និង មានៈ ( វៀរទិដ្ឋិ )



## ចំណាំ

**លោភមូលចិត្ត** ប្រការទី ៣ នេះមានចេតសិកប្រកប ជាមួយ ១៩ ប្រភេទ តែក្នុងកាលណាដែលមានមានះ ចេតសិកកើតរួមជាមួយ មានចេតសិកប្រកបជាមួយត្រឹម តែ ១៨ ប្រភេទប៉ុណ្ណោះក្នុងកាលណាដែលមិនមានមានះ ចេតសិកកើតរួមជាមួយ។



## ៤-សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយ មានការបបួលដឹកនាំ។

Consciousness, prompted, accompanied by pleasure, and disconnected with wrong view.

## ៤- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ




មានចេតសិកកើតរួមជាមួយ ២១ ប្រភេទគឺ៖

- អញ្ញសមានាចេតសិក ១៣ គឺ សព្វចិត្តសាធារណចេតសិក ៧ និងបកិណ្ណកចេតសិក ៦
- មោចតុក្កៈ ៤
- លោតិកៈ ២ ( វៀរទិដ្ឋិ )
- ថីទុកៈ ២ គឺ ថីនៈ មិទ្ធៈ



## ចំណាំ

- លោភមូលចិត្តដួងទី ៤ នេះមានចេតសិកប្រកបជាមួយ ២១ ប្រភេទក្នុងកាលណាដែលមានមានៈចេតសិកកើតរួមជាមួយ មានចេតសិកប្រកបជាមួយត្រឹមតែ ២០ ប្រភេទប៉ុណ្ណោះ ក្នុងកាលណាដែលមិនមានមានៈ ចេតសិកកើត រួមជាមួយ។
- មានៈនិងទិដ្ឋិ កើតរួមគ្នាមិនបានទេ ប៉ុន្តែនៅក្នុងកងអកុសលដូចគ្នា។

បើលឺវីដេអូ ភាគទី ២១

# ៥- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តដែលប្រព្រឹត្តទៅមួយអន្លើដោយឧបេក្ខាវេទនា ប្រកបដោយ មិច្ឆាទិដ្ឋិ មិនមានការបបួលដឹកនាំ។

Consciousness, unprompted, accompanied by indifference, and connected with wrong view.

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## ៥- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ

មានចេតសិកប្រកបជាមួយ ១៨ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- មោចតុក្កៈ ៤
- លោតិកៈ ២ (វៀរមានៈ)



## ៦- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តដែលប្រព្រឹត្តទៅមួយអន្លើដោយឧបេក្ខា
វេទនា ប្រកបដោយ មិច្ឆាទិដ្ឋិ មានការបបួលដឹកនាំ។

Consciousness, prompted, accompanied by indifference, and connected with wrong view.



## ៦- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ

មានចេតសិកប្រកបជាមួយ ២០ ប្រភេទគឺ ៖

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-មោចតុក្កៈ ៤

-លោតិកៈ ២ (វៀរមានៈ)

-ថីទុកៈ ២ គឺ ថីនៈ មិទ្ធៈ



## ៧- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

លោភមូលចិត្តដែលប្រព្រឹត្តទៅមួយអន្លើដោយឧបេក្ខាវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មិនមានការបបួលដឹកនាំ។

Consciousness, unprompted, accompanied by indifference, and connected with wrong view.



## ៧- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ

មានចេតសិកប្រកបជាមួយ ១៨ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- មោចតុក្កៈ ៤
- លោតិកៈ  ២ (វៀរ ទិដ្ឋិ)



## ៨- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

លោភមូលចិត្តប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកមិច្ឆាទិដ្ឋិ មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំពីអ្នកដទៃ។

Consciousness, prompted, accompanied by indifference, and connected with wrong view.



## ៨- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ

មានចេតសិកប្រកបជាមួយ ២០ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- មោចតុក្កៈ ៤
- លោតិកៈ ២ (វៀរទិដ្ឋិ)
- ថីទុកៈ ២ គឺ ថីនៈ មិទ្ធៈ



មើលវីដេអូ ភាគទី ២២

# សំណួរ

១- តើលោភមូលចិត្តដួងណាខ្លះ ដែលមានចេតសិកប្រកបជាមួយច្រើនជាងគេ?
២- តើលោភមូលចិត្តដួងណាខ្លះ ដែលមានចេតសិកប្រកបជាមួយតិចជាងគេ?
៣- តើបីតិចេតសិក កើតនៅក្នុងលោភមូលចិត្តដួងណាខ្លះ?
៤- តើទិដ្ឋិចេតសិក កើតនៅក្នុងលោភមូលចិត្តដួងណាខ្លះ?
៥- តើបីតិចេតសិកមាននៅក្នុងលោភមូលចិត្ត ដែលប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនាឬទេ? បើមានព្រោះហេតុអ្វី? បើមិនមានព្រោះអ្វី?
៦- ចំពោះលោភមូលចិត្តដែលមិនមានមិច្ឆាទិដ្ឋិកើតជាមួយ ហេតុអ្វីក៏ចាត់ជាអកុសលចិត្តដែរ? ចូរពន្យល់!
៨- តើលោភមូលចិត្ត និងលោភចេតសិក ដូចគ្នា ឬខុសគ្នា?
៩- តើសោមនស្សវេទនា កើតក្នុងលោភមូលចិត្តប៉ុន្មានដួង?

ស្កេនដើម្បីមើលមេរៀន

San Sochea Official



១០- តើឧបេក្ខាវេទនាដែលកើតក្នុងលោភមូលចិត្ត មានជាតិជាកិរិយា ឬក៏ជាវិបាក?
១១- តើមានៈ អាចកើតក្នុងលោភមូលចិត្តប៉ុន្មានដួង?
១២- តើថីនៈ មិទ្ធៈ កើតក្នុងលោភមូលចិត្តប៉ុន្មានដួង ?
១៣- តើលោភមូលចិត្តមានប៉ុន្មានដួង?
១៤- តើបុថុជ្ជន មានលោភមូលចិត្តប៉ុន្មានដួង?
១៥- តើអរិយបុគ្គលថ្នាក់ក្រោមមានលោភមូលចិត្តប៉ុន្មានដួង?
១៦- តើព្រះអរហន្តមានលោភមូលចិត្តប៉ុន្មានដួង?
១៧- តើសត្វតិរច្ឆានមានលោភមូលចិត្តប៉ុន្មានដួង?
១៨- ក្នុងនិច្ចសីល តើលោភមូលចិត្តជាហេតុឲ្យដាច់សិក្ខាបទណាខ្លះ?

## ចំណាំ

ក្នុងលោភមូលចិត្ត ៨ដួង មានចេតសិកកើតរួមទាំងអស់ ២២ ប្រភេទ គឺ អញ្ញសមានាចេតសិក ១៣ មោចតុក្កចេតសិក ៤ លោភតិកចេតសិក ៣ ថីទុកចេតសិក ២។ ប៉ុន្តែចេតសិកដែលកើតទៀងទាត់ក្នុងលោភ-មូលចិត្តទាំង ៨ ដួង មានត្រឹមតែ ១៧ ប៉ុណ្ណោះគឺ៖

- អញ្ញសមានាចេតសិក ១២ (វៀរ បីតិ)
- មោចតុក្កៈ ៤
- លោភចេតសិក ១ (វៀរ ទិដ្ឋិ មានៈ ថីនៈ មិទ្ធៈ)។



មើលវីដេអូ ភាគទី ២៣

## ហេតុនាំឱ្យកើតលោភមូលចិត្តមាន ៤ យ៉ាងគឺ ៖

| | |
|---|---|
| ១- លោភបរិវារកម្មបដិសន្ធិកតា | បដិសន្ធិដោយកម្មដែលមានលោភៈជាបរិវារ |
| ២- លោភឧស្សន្នភវតោចវនតា | ចុតិចាកភពដែលសម្បូរដោយលោភៈ ឬ សេចក្តីសប្បាយ |
| ៣- ឥដ្ឋារម្មណសមាយោគោ | មានការជួបប្រសព្វនឹងឥដ្ឋារម្មណ៍ |
| ៤- អស្សាទទស្សនំ | មានការឃើញនូវវត្ថុជាទីពេញចិត្ត ឬជាទីសប្បាយចិត្ត |

ស្កេនដើម្បីមើលមេរៀន
San Sochea Official

## ការចែកលោភមូលចិត្ត ៨ ដួងដោយន័យផ្សេងៗ

១- ដោយជាតិ ជាអកុសលជាតិ

២- ដោយភូមិ ជាកាមាវចរភូមិ (កើតបាន ៣០ ភូមិ)

៣- ដោយវេទនា ជាសោមនស្សវេទនា ៤ ដួង និង ជាឧបេក្ខាវេទនា ៤ដួង

៤- ដោយហេតុ ជានហេតុ និង ជាទ្វិហេតុកចិត្ត

៥- ដោយសង្ខារ ជាអសង្ខារិក ៤ ដួង និង ជាសសង្ខារិក ៤ ដួង

៦- ដោយសម្បយុត្ត ជាទិដ្ឋិគតសម្បយុត្ត ៤ ដួង និង ទិដ្ឋិគតវិប្បយុត្ត ៤ ដួង



៧- ដោយសោភណៈ ជាអសោភណចិត្ត

៨- ដោយឈាន ជាអកុសលឈាន

៩- ដោយលោកិយ ជាលោកិយចិត្ត

១០- ដោយកិច្ច ធ្វើជវនកិច្ចតែម្យ៉ាង

១១- ដោយអារម្មណ៍ ដឹងអារម្មណ៍ទាំង ៦

១២- ដោយទ្វារ ប្រព្រឹត្តទៅតាមទ្វារទាំង ៦

១៣- ដោយវត្ថុ អាស្រ័យនឹងហទយវត្ថុ (ក្នុងភពដែលមានខន្ធ៥)។

១៤- ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ។

មើលវីដេអូ ភាគទី ២៤

## ផលរបស់លោភមូលចិត្ត

បច្ចុប្បន្ន កាលណាសត្វលោភច្រើនទៅដោយលោភចិត្តនឹងកើតទុរ្ភិក្សច្រើនប្រការ។

អនាគតជាតិ លោភមូលចិត្តច្រើននាំសត្វទៅកើតជាប្រេត។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## សរុបលោភមូលចិត្ត ៨ ដួង សម្រាប់ស្វាធ្យាយ

| | | |
|---|---|---|
| ១- សោមនស្សសហគតំ | ទិដ្ឋិគតសម្បយុត្តំ | អសង្ខារិកំ |
| ២- សោមនស្សសហគតំ | ទិដ្ឋិគតសម្បយុត្តំ | សសង្ខារិកំ |
| ៣- សោមនស្សសហគតំ | ទិដ្ឋិគតវិប្បយុត្តំ | អសង្ខារិកំ |
| ៤- សោមនស្សសហគតំ | ទិដ្ឋិគតវិប្បយុត្តំ | សសង្ខារិកំ |
| ៥- ឧបេក្ខាសហគតំ | ទិដ្ឋិគតសម្បយុត្តំ | អសង្ខារិកំ |
| ៦- ឧបេក្ខាសហគតំ | ទិដ្ឋិគតសម្បយុត្តំ | សសង្ខារិកំ |
| ៧- ឧបេក្ខាសហគតំ | ទិដ្ឋិគតវិប្បយុត្តំ | អសង្ខារិកំ |
| ៨- ឧបេក្ខាសហគតំ | ទិដ្ឋិគតវិប្បយុត្តំ | សសង្ខារិកំ |

## ពាក្យគន្លឹះងាយចាំ ក្នុងលោភមូលចិត្តទាំង៨ដួង






# ទោសមូលចិត្ត ២ ដួង

Consciousness Rooted in Ill-will or Aversion

## ១- ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ

ចិត្តដែលប្រព្រឹត្តទៅមួយអន្លើដោយទោមនស្សវេទនា ប្រកបដោយបដិឃៈ (សេចក្ដីថ្នាំងថ្នាក់) មិនមានការបបួលដឹកនាំ។

Consciousness, unprompted, accompanied by displeasure, and connected with ill-will.

## ១- ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ




មានចេតសិកប្រកបជាមួយ ២០ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- មោចតុក្កៈ ៤
- ទោចតុក្កៈ ៤



## ២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

ចិត្តដែលប្រព្រឹត្តទៅមួយអន្លើដោយទោមនស្សវេទនា ប្រកបដោយបដិឃៈ (សេចក្តីថ្នាំងថ្នាក់) មានការបបួលដឹកនាំ។

Consciousness, prompted, accompanied by displeasure, and connected with ill-will.

មើលវីដេអូ ភាគទី ២៥

## ២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

មានចេតសិកប្រកបជាមួយ ២២ ប្រភេទគឺៈ

-អញ្ញសមានាចេតសិក ១២ (វៀរបីតិ)

-មោចតុក្កៈ ៤

-ទោចតុក្កៈ ៤

-ថីទុកៈ ២




ស្កេនដើម្បីមើលមេរៀន

San Sochea Official



## សរុបទោសមូលចិត្ត ២ ដួង

១- ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ

២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ

**ពាក្យគន្លឹះងាយចាំ ក្នុងទោសមូលចិត្ត ២ ដួង**






## ហេតុនាំឱ្យកើតទោសមូលចិត្តមាន ៤ យ៉ាង គឺ ៖

១- ទោសជ្ឈាសយតា ភាពជាអ្នកចងនូវសេចក្ដីក្រោធទុក។
២- អគម្ភីរបកតិតា ជាអ្នកមិនមានភាពល្អិតសុខុម ជាប្រក្រតី។
៣- អប្បសុតតា ជាអ្នកស្ដាប់ព្រះសទ្ធម្មតិចតួច។
៤- អនិដ្ឋារម្មណសមាយោគោ ជួបប្រសព្វនឹងអនិដ្ឋារម្មណ៍។



## ធម៌ជាហេតុលះទោសមូលចិត្តមាន ៦ យ៉ាងគឺ ៖

១- មេត្តានិមិត្តស្ស ឧគ្គហោ ការរៀនយកនូវមេត្តានិមិត្ត។
២- មេត្តាភាវនានុយោគោ ការបំពេញព្យាយាមក្នុងមេត្តាភាវនា។
៣-កម្មស្សកតាបច្ចវេក្ខណា ពិចារណាឃើញថា សត្វមានកម្មជារបស់ខ្លួន។
៤- បដិសង្ខានពហុលីកតា ភាពជាអ្នកពិចារណាច្រើន។
៥- កល្យាណមិត្តតា ជាអ្នកមានកល្យាណមិត្ត។
៦- សប្បាយកថា មានកថាជាទីសប្បាយ។

## ការចែកទោសមូលចិត្ត ២ ដួងដោយន័យផ្សេងៗ

១- ដោយជាតិ ជាអកុសលជាតិ។
២- ដោយភូមិ កើតក្នុងកាមាវចរភូមិ ១១ ជាន់។
៣- ដោយវេទនា ជាទោមនស្សវេទនាទាំង ២ ដួង។
៤- ដោយហេតុ ជានហេតុ និង ជាទ្វិហេតុកចិត្ត។
៥- ដោយសង្ខារ ជាអសង្ខារិក ១ សសង្ខារិក ១។
៦- ដោយសម្បយុត្ត ជាបដិឃសម្បយុត្តទាំង ២ ដួង។



៧- ដោយសោភណៈ ជាអសោភណចិត្ត។
៨- ដោយឈាន ជាអកុសលឈាន។
៩- ដោយលោកិយៈ ជាលោកិយចិត្ត។
១០- ដោយកិច្ច ធ្វើជវនកិច្ច។
១១- ដោយអារម្មណ៍ ដឹងអារម្មណ៍ទាំង ៦។
១២- ដោយទ្វារ កើតតាមទ្វារទាំង ៦។
១៣- ដោយវត្ថុ អាស្រ័យតែហទយវត្ថុប៉ុណ្ណោះ។
១៤- ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ។

មើលវីដេអូ ភាគទី ២៦

# ផលនៃទោសមូលចិត្ត

ក្នុងបច្ចុប្បន្ន បើសត្វលោកច្រើនដោយទោសមូលចិត្ត នឹងកើតមានសត្ថន្តរាយ (អន្តរាយកើតពីសស្ត្រាវុធ គឺចម្បាំងរាំងជល់) ក្នុងអនាគតជាតិច្រើនបដិសន្ធិក្នុងនរក។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



មើលវីដេអូ ភាគទី ២៧

# មោហមូលចិត្ត ២ ដួង

**១- ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ** មោហមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបជាមួយវិចិកិច្ឆា (សេចក្តីសង្ស័យ)។

Consciousness, accompanied by indifference, and connected with doubts.

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## ១- ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ

មានចេតសិកប្រកបជាមួយ ១៥ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១០ (វៀរលែងបីតិ អធិមោក្ខៈ ឆន្ទៈ)
- មោចតុក្កៈ ៤
- វិចិកិច្ឆា ១






## ២- ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ

មោហមូលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបជាមួយឧទ្ធច្ចៈ (រវើរវាយ)។

Consciousness, accompanied by indifference, and connected with restlessness.

## ២- ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ

មានចេតសិកប្រកបជាមួយ ១៥ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១១ (វៀរលែង បីតិ ឆន្ទៈ)
- មោចតុក្កៈ ៤






មើលវីដេអូ ភាគទី ២៨

## សេចក្តីសង្ស័យក្នុងព្រះអភិធម្ម ៨ យ៉ាងគឺ ៖

១- ពុទ្ធេ កង្ខតិ — សង្ស័យក្នុងព្រះពុទ្ធ គឺ ពុទ្ធគុណទាំង១០ មានពាក្យថា អរហំ ជាដើម ថាមានពិតឬហ្ន៎!

២- ធម្មេ កង្ខតិ — សង្ស័យក្នុងព្រះធម៌ គឺ ក្នុងធម្មគុណទាំង ៦ មានពាក្យថា ស្វាក្ខាតោ ជាដើម ថាមានពិតឬហ្ន៎!

៣- សង្ឃេ កង្ខតិ — សង្ស័យក្នុងព្រះសង្ឃ គឺក្នុងសង្ឃគុណទាំង ៩ មានពាក្យថា សុប្បដិបន្នោ ជាដើម ថាមានពិតឬហ្ន៎!

៤- សិក្ខាយ កង្ខតិ — សង្ស័យក្នុងសិក្ខាបទ គឺសិក្ខាបទទាក់ទង សីល សមាធិ និង បញ្ញា។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

៥- បុព្វន្តេ កង្ខតិ — សង្ស័យក្នុងខន្ធ៥ ដែលជាអតីត ថាធ្លាប់កើតមានដែរឬទេហ្ន៎!

៦- អបរន្តេ កង្ខតិ — សង្ស័យក្នុងខន្ធ ៥ ជាអនាគត ថានឹងកើតមានទៀតឬហ្ន៎!

៧- បុព្វន្តាបរន្តេ កង្ខតិ — សង្ស័យក្នុងខន្ធ ៥ ដែលជាអតីតនិង អនាគត ថាធ្លាប់កើតក្នុងអតីត ហើយនឹងកើតក្នុងអនាគតទៀតឬហ្ន៎!

៨- បដិច្ចសមុប្បាទេ កង្ខតិ — សង្ស័យក្នុងបដិច្ចសមុប្បាទធម៌ថា អវិជ្ជាជាដើម ជាបច្ច័យឱ្យកើតបាប និង បុណ្យ ឬឱ្យកើតផលបាប ឬបុណ្យ តើពិតមែន ឬហ្ន៎!



# សេចក្តីសង្ស័យក្នុងព្រះសូត្រមាន ១៦ យ៉ាង

## សង្ស័យក្នុងខន្ធ៥ ដែលជាចំណែកអតីត ៥ គឺ ៖

១- អហោសឹ នុ ខោ អហំ អតីតមទ្ធានំ — យើងធ្លាប់កើតមកក្នុងអតីតកាលដែរឬហ្ន៎!

២- ន នុ ខោ អហោសឹ អតីតមទ្ធានំ — យើងមិនធ្លាប់កើតមកក្នុងអតីតកាលទេដឹងហ្ន៎!

៣- កឹ នុ ខោ អហោសឹ អតីតមទ្ធានំ — យើងធ្លាប់កើតក្នុងអតីតជាអ្វីហ្ន៎!

៤- កថំ នុ ខោ អហោសឹ អតីតមទ្ធានំ — ក្នុងអតីតយើងមានរូបរាងសណ្ឋានដូចម្តេចហ្ន៎!

៥- កឹ ហុត្វា កឹ អហោសឹ នុ ខោ អហំ អតីតមទ្ធានំ អំពីអតីតកាល អាត្មាអញកើតជាជាតិអ្វី? ឬ មួយអាត្មាអញ មានសណ្ឋានទ្រង់ទ្រាយដូចម្តេច!

## សេចក្ដីសង្ស័យក្នុងខន្ធ ៥ ដែលជាចំណែកអនាគត៥ គឺ ៖

១ - ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ — យើងនឹងកើតក្នុងកាលអនាគតឬទេហ្ន៎!

២ - ន នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ — យើងនឹងមិនកើតក្នុងកាលអនាគតទេដឹងហ្ន៎!

៣ - កឹ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ — យើងនឹងកើតក្នុងកាលអនាគតជាអ្វីហ្ន៎!

៤ - កថំ នុ ខោ ភវិស្សាមិ អនាគតមទ្ធានំ — ក្នុងអនាគតយើង នឹងមានរូបរាងសណ្ឋានយ៉ាងណាហ្ន៎!

៥ - កឹ ហុត្វា កឹ ភវិស្សាមិ នុ ខោ អហំ អនាគតមទ្ធានំ — យើងនឹងកើតជាអ្វី! ហើយតទៅនឹងកើតជាអ្វីទៀតហ្ន៎!



## សង្ស័យក្នុងខន្ធ ៥ ដែលជាចំណែកបច្ចុប្បន្ន ៦ គឺ ៖

១- អហំ នុ ខោស្មិ — ឥឡូវនេះជាយើងឬហ្ន៎!

២- នោ នុ ខោស្មិ — ឥឡូវនេះមិនមែនជាយើងឬហ្ន៎!

៣- កឹ នុ ខោស្មិ — ឥឡូវនេះយើងជាអ្វីហ្ន៎!

៤- កថំ នុ ខោស្មិ — ឥឡូវនេះយើងមានរូបរាងសណ្ឋានយ៉ាងណាហ្ន៎!

៥- អយំ នុ ខោ សត្តោ កុតោ អាគតោ — សត្វនេះមកពីណាហ្ន៎!

៦- សោ កុហឹ គាមី ភវិស្សតិ — សត្វនោះនឹងទៅកើតទីណាហ្ន៎!

# ចែកមោហមូលចិត្តដោយន័យផ្សេង ៗ

| | |
|---|---|
| ១ - ដោយជាតិ | ជាអកុសលជាតិ |
| ២ - ដោយភូមិ | ជាកាមាវចរភូមិ (កើតក្នុងភូមិទាំងអស់ វៀរអសញ្ញសត្តា)។ |
| ៣ - ដោយវេទនា | ជាឧបេក្ខាវេទនាទាំង ២ ដួង |
| ៤ - ដោយហេតុ | ជានហេតុ និង ជាឯកហេតុកចិត្ត |
| ៥ - ដោយសង្ខារ | ជាសង្ខារវិមុត្ត (ជាអសង្ខារិកៈក៏មិនមែន ជាសសង្ខារិកៈក៏មិនមែន) |
| ៦ - ដោយសម្បយុត្ត | ជាវិចិកិច្ឆាសម្បយុត្ត ១ និង ឧទ្ធច្ចសម្បយុត្ត ១ |



| | |
|---|---|
| ៧- ដោយសោភណ | ជាអសោភណចិត្ត |
| ៨- ដោយឈាន | ជាអឈានចិត្ត |
| ៩- ដោយលោកិយ | ជាលោកិយចិត្ត |
| ១០- ដោយកិច្ច | ធ្វើជវនកិច្ច |
| ១១- ដោយអារម្មណ៍ | ដឹងអារម្មណ៍ ៦ |
| ១២- ដោយទ្វារ | កើតតាមទ្វារទាំង ៦ |
| ១៣- ដោយវត្ថុ | កើតក្នុងហទយវត្ថុ ក្នុងភពដែលមានខន្ធ ៥ (ក្នុងភូមិ ២៦)។ |
| ១៤- ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ |

# ផលរបស់មោហមូលចិត្ត

- ក្នុងបច្ចុប្បន្ន — កាលណាសត្វលោកច្រើនទៅដោយមោហៈគឺ សេចក្ដីល្ងង់ សេចក្ដីវង្វេង ក្នុងកាលនោះ ច្រើនមានសេចក្ដីអន្តរាយដោយរោគបៀតបៀន។

- ក្នុងអនាគតជាតិ — ព្រោះតែមោហៈជាហេតុ សត្វលោកច្រើនបដិសន្ធិក្នុងកំណើតតិរច្ឆាន ដែលមានតែសេចក្ដីវង្វេងជានិច្ច។



# សម្បយោគន័យ

## ក្នុងអកុសលចិត្ត ១២ ដួង

ក្នុងអកុសលចិត្ត ១២ ដួង មានចេតសិកកើតរួមសរុប ២៧ គឺ អញ្ញសមានាចេតសិក ១៣ និង អកុសលចេតសិក ១៤។

## ១ - ចេតសិកដែលកើតនៅក្នុងអកុសលចិត្តគ្រប់ទាំង ១២ ដួង មានត្រឹមតែ ១៤ ប្រភេទប៉ុណ្ណោះ គឺ ៖

- សព្វចិត្តសាធារណចេតសិក ៧ គឺ ផស្សៈ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយៈ មនសិការ

- បកិណ្ណកចេតសិក ៣ គឺ វិតក្កៈ វិចារៈ វីរិយៈ *(វៀរលែង អធិមោក្ខៈ បីតិ ឆន្ទៈ)*

- មោចតុក្កៈ ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ។



ចេតសិកទាំង ១៤ ខាងលើនេះ អាចហៅថា សព្វាកុសលយោគីចេតសិក។

សព្វាកុសលយោគីចេតសិក មកពី

សព្វ + អកុសល + យោគី + ចេតសិក ចេតសិក ដែលកើតនៅក្នុងអកុសលចិត្តគ្រប់ទាំង ១២ ដួង ។

២ - អធិមោក្ខៈ កើតនៅក្នុងអកុសលចិត្ត ១១ ប៉ុណ្ណោះ (វៀរ វិចិកិច្ឆាសម្បយុត្តចិត្ត១)។

៣ - បីតិ កើតនៅក្នុងលោភមូលចិត្ត ដែលប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ៤ ដួងប៉ុណ្ណោះ។

៤- ឆន្ទៈ កើតនៅក្នុងអកុសលចិត្ត ១០ ដួងប៉ុណ្ណោះ (វៀរមោហមូលចិត្ត ២ ដួង) ។

៥- លោភៈ កើតនៅក្នុងលោភមូលចិត្ត ៨ ដួងប៉ុណ្ណោះ។



៦ - ទិដ្ឋិ កើតនៅក្នុងលោភមូលចិត្ត ដែលជាទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួងប៉ុណ្ណោះ។

៧ - មានោ កើតនៅក្នុងលោភមូលចិត្តដែលជាទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួងប៉ុណ្ណោះ។

៨ - ទោចតុក្កៈ ៤ គឺ ទោសៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ កើតតែក្នុងទោសមូលចិត្ត ២ ដួង។

៩ - ថីទុកៈ ២ គឺ ថីនៈ មិទ្ធៈ កើតនៅក្នុងសសង្ខារិកចិត្ត ៥ ដួង។

១០ - វិចិកិច្ឆា កើតនៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង។

មើលវីដេអូ ភាគទី ២៩

# អកុសលកម្មបថ ១០

### ១ - កាយកម្ម ៣ គឺ ៖

- *បាណាតិបាត* ការសម្លាប់សត្វ
- *អទិន្នាទាន* ការលួចទ្រព្យអ្នកដទៃ
- *កាមេសុមិច្ឆាចារ* ការប្រព្រឹត្តខុសក្នុងកាម

### ២ - វចីកម្ម ៤ គឺ ៖

- *មុសាវាទ* ការនិយាយពាក្យកុហក
- *បិសុណាវាទ* ការនិយាយពាក្យញុះញង់
- *ផរុសវាទ* ការនិយាយពាក្យគ្រោតគ្រាត
- *សម្ផប្បលាប* ការនិយាយឥតប្រយោជន៍

### ៣ - មនោកម្ម ៣ គឺ ៖

- *អភិជ្ឈា* ការសម្លឹងរំពៃចង់បានទ្រព្យគេ
- *ព្យាបាទ* ការចងអាឃាតព្យាបាទ
- *មិច្ឆាទិដ្ឋិ* ការយល់ខុស

ស្កេនដើម្បីមើលមេរៀន

San Sochea Official





# វិនិច្ឆ័យអកុសលកម្មបថ ១០ ដោយអាការ ៥

១- ដោយមូល

២- ដោយកម្ម

៣- ដោយទ្វារ

៤- ដោយទោស

៥- ដោយអង្គ



## វិនិច្ឆ័យបាណាតិបាត ដោយអាការ៥

*ទោសមូលចិត្ត*




*១- ដោយមូល* ការសម្លាប់សត្វ គិតដោយមូល មានមូល២ គឺ ៖ មោហមូល និងទោសមូល ដែលកើតក្នុងទោសមូលចិត្ត ២ ដួង

## ចិត្តជាហេតុឲ្យដាច់បាណាតិបាត គឺទោសមូលចិត្ត២ដួង






បាណាតិបាត

ពោលដោយកម្ម

គឺជាកាយកម្ម



ទ្វារនៃកម្មបថមាន៣ គឺ កាយទ្វារ វចីទ្វារ និងមនោទ្វារ



សម្លាប់ ដោយខ្លួនឯង

បាណាតិបាត ពោលដោយទ្វារ កើតតាមទ្វារ ២ គឺ

- កាយទ្វារ
- និងវចីទ្វារ



ប្រើគេ ឲ្យសម្លាប់





សម្លាប់ ដោយខ្លួនឯង

បាណាតិបាត ចាត់ជាកាយកម្ម និងមានទ្វារ ២

កាយកម្ម កាយទ្វារ

កាយកម្ម វចីទ្វារ



ប្រើគេ ឲ្យសម្លាប់

២ - ដោយកម្ម ជាកាយកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ២ គឺ កាយទ្វារ និងវចីទ្វារ

៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ

- សម្លាប់សត្វដែលមានសេចក្ដីល្អច្រើន មានទោសច្រើន
- សម្លាប់សត្វដែលមានសេចក្ដីល្អតិច មានទោសតិច
- កិលេសនិងការព្យាយាមខ្លាំង មានទោសច្រើន
- កិលេសនិងការព្យាយាមខ្សោយ មានទោសតិច



៥- ដោយអង្គ បាណាតិបាត មានអង្គ៥ គឺ ៖

- បាណោ សត្វមានជីវិត
- បាណសញ្ញិតា សេចក្ដីដឹងថា សត្វមានជីវិត
- វធកចិត្តំ គិតនឹងសម្លាប់
- ឧបក្កមោ ព្យាយាមនឹងសម្លាប់
- តេន មរណំ សត្វស្លាប់ដោយការព្យាយាមនោះ។

** កាលណាគ្រប់អង្គទាំង៥ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*

មើលវីដេអូ ភាគទី ៣០

# វិនិច្ឆ័យអនិដ្ឋារម្មណ៍ដោយអាការ ៥

១ - ដោយមូល មានមូល ៣ គឺ លោភមូល ទោសមូល និងមោហមូលទាំង ៣ មិនអាចកើតព្រមគ្នាក្នុងចិត្តុប្បាទជាមួយគ្នាបានឡើយ កើតម្តងបានតែ២ប៉ុណ្ណោះ គឺ ៖

- បើលួចដើម្បីបានជារបស់ខ្លួន មានលោភៈ និងមោហៈ ជាមូល កើតក្នុងលោភមូលចិត្ត៨ដួង។
- បើលួចដើម្បីបំផ្លាញអ្នកដទៃឲ្យខូចប្រយោជន៍ ដូចជា លួចដុតផ្ទះ លួចបង្ហូរទឹកស្រែគេចោល ជាដើម មានទោសៈ និងមោហៈ ជាមូល កើតនៅក្នុងទោសមូលចិត្ត២ដួង។

** ដូច្នេះអនិដ្ឋារម្មណ៍ ដាច់ដោយអកុសលចិត្ត១០ ដួង (វៀរមោហមូលចិត្ត២ដួង)*

ស្កេនដើម្បីមើលមេរៀន

San Sochea Official



បើកើតដោយលោភមូលចិត្ត ៨ ដួង ក្នុងចិត្តនីមួយៗ មានមូល២ គឺ ៖ មោហមូល និងលោភមូល




បើកើតដោយទោសមូលចិត្ត២ដួង ក្នុងចិត្តនីមួយៗ មានមូល២ គឺ ៖ មោហមូល និងទោសមូល



២ - ដោយកម្ម ជាកាយកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ២ គឺ កាយទ្វារ និងវចីទ្វារ



លួចដោយខ្លួនឯង
ជាកាយកម្ម កាយទ្វារ



ប្រើគេឲ្យលួច
ជាកាយកម្ម វចីទ្វារ



## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ ៖

| | |
|---|---|
| - លួចរបស់ដែលនាំឲ្យម្ចាស់ទ្រព្យខូចប្រយោជន៍ច្រើន | មានទោសច្រើន |
| - លួចរបស់ដែលនាំឲ្យម្ចាស់ទ្រព្យខូចប្រយោជន៍តិច | មានទោសតិច |
| - កិលេសនិងការព្យាយាមខ្លាំង | មានទោសច្រើន |
| - កិលេសនិងការព្យាយាមខ្សោយ | មានទោសតិច |

## ៥ - ដោយអង្គ អទិន្នាទានមានអង្គ៥ គឺ ៖

- បរបរិគ្គហិតំ ទ្រព្យមានម្ចាស់ហួងហែងរក្សា
- បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថាទ្រព្យមានម្ចាស់ហួងហែងរក្សា
- ថេយ្យចិត្តំ គិតនឹងលួច
- ឧបក្កមោ ព្យាយាមនឹងលួច
- តេន ហរណំ លួចបានដោយការព្យាយាមនោះ។

** កាលណាគ្រប់អង្គទាំង៥ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*



មើលវីដេអូ ភាគទី ៣១

## វិនិច្ឆ័យកាមេសុមិច្ឆាចារដោយអាការ ៥ ៖

១ - ដោយមូល មានមូល២ គឺ លោភមូល និងមោហមូល

២ - ដោយកម្ម ជាកាយកម្ម

៣ - ដោយទ្វារ កើតតាមកាយទ្វារ

៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ ៖

- ប្រព្រឹត្តលើអ្នកដែលមិនមានឆន្ទៈរួមគ្នា មានទោសច្រើន
- ប្រព្រឹត្តលើអ្នកដែលមានឆន្ទៈរួមគ្នា មានទោសតិច
- កិលេសនិងការព្យាយាមខ្លាំង មានទោសច្រើន
- កិលេសនិងការព្យាយាមខ្សោយ មានទោសតិច

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## ៥ - ដោយអង្គ កាមេសុមិច្ឆាចារមានអង្គ៤ គឺ ៖

| | |
|---|---|
| - អគមនីយវត្ថុ | វត្ថុមិនគួរទាក់ទង (បានដល់ស្ត្រីដែលមានអ្នកហួងហែងរក្សា) |
| - តស្មឹ សេវនចិត្តំ | មានចិត្តគិតនឹងសេពនូវវត្ថុមិនគួរនោះ |
| - សេវនប្បយោគោ | ព្យាយាមក្នុងការសេព |
| - មគ្គេន មគ្គប្បដិបាទនំ | ញុំាងមគ្គនិងមគ្គឲ្យដល់គ្នា។ |

** កាលណាគ្រប់អង្គទាំង៤ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*



# វិនិច្ឆ័យមុសាវាទដោយអាការ ៥ ៖

| | |
|---|---|
| ១- ដោយមូល | មានមូល៣ គឺ លោភមូល ទោសមូល និងមោហមូល |
| ២- ដោយកម្ម | ជាវចីកម្ម |
| ៣- ដោយទ្វារ | សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ |

## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះគឺ ៖

- កុហកនាំឲ្យអ្នកដទៃខូចប្រយោជន៍ច្រើន មានទោសច្រើន
- កុហកនាំឲ្យអ្នកដទៃខូចប្រយោជន៍តិច មានទោសតិច
- កិលេសនិងការព្យាយាមខ្លាំង មានទោសច្រើន
- កិលេសនិងការព្យាយាមខ្សោយ មានទោសតិច



## ៥ - ដោយអង្គ មុសាវាទមានអង្គ ៤ គឺ ៖

- អតថំ វត្ថុ វត្ថុ ឬរឿងមិនពិត
- វិសំវាទនចិត្តំ គិតនឹងពោលឲ្យខុស
- តជ្ជោ វាយាមោ ព្យាយាមនឹងពោលឲ្យខុស
- បរស្ស តទត្ថវិជាននំ ញុំាងអ្នកដទៃឲ្យដឹងច្បាស់ នូវសេចក្តីនោះ ។

មើលវីដេអូ ភាគទី ៣២

## វិនិច្ឆ័យបិសុណាវាទ (ពាក្យញុះញង់) ដោយអាការ ៥ ៖

| | |
|---|---|
| ១ - ដោយមូល | មានមូល៣ គឺ លោភមូល ទោសមូល និងមោហមូល |
| ២ - ដោយកម្ម | ជាវចីកម្ម |
| ៣ - ដោយទ្វារ | សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ |

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ គឺ ៖

| | |
|---|---|
| - ញុះញង់ឲ្យអ្នកដទៃខូចប្រយោជន៍ច្រើន | មានទោសច្រើន |
| - ញុះញង់ឲ្យអ្នកដទៃខូចប្រយោជន៍តិច | មានទោសតិច |
| - អ្នកដទៃបែកគ្នាដោយការញុះញង់នោះ | មានទោសច្រើន |
| - បើគេមិនបែកគ្នាដោយការញុះញង់នោះ | មានទោសតិច |
| - កិលេសនិងការព្យាយាមខ្លាំង | មានទោសច្រើន |
| - កិលេសនិងការព្យាយាមខ្សោយ | មានទោសតិច |

## ៥ - ដោយអង្គ បិសុណាវាទ មានអង្គ ៤ គឺ ៖

- ភិន្ទិតព្វោ បរោ — មានអ្នកដទៃដែលខ្លួនគប្បីញុះញង់បំបែក
- ភេទបុរេក្ខារតា — គិតនឹងញុះញង់បំបែកអ្នកដទៃនោះ
- តជ្ជោ វាយាមោ — ព្យាយាមបំបែកអ្នកដទៃនោះ
- តស្ស តទត្ថវិជាននំ — ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវរឿង ដែលខ្លួនញុះញង់នោះ។

* *កាលណាគ្រប់អង្គទាំង៤ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*



## វិនិច្ឆ័យផរុសវាទ (ពាក្យសំដីអាក្រក់) ដោយអាការ៥ ៖

១ - ដោយមូល មានមូល២ គឺទោសមូល និងមោហមូល

២ - ដោយកម្ម ជាវចីកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ

## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ គឺ ៖

- ជេរមនុស្សល្អ មានទោសច្រើន
- ជេរមនុស្សអាក្រក់ មានទោសតិច
- កិលេសនិងការព្យាយាមខ្លាំង មានទោសច្រើន
- កិលេសនិងការព្យាយាមខ្សោយ មានទោសតិច



## ៥ - ដោយអង្គ ផរុសវាទមានអង្គ៣ គឺ ៖

- អក្កោសិតព្វោ បរោ មានអ្នកដទៃដែលខ្លួនគប្បីជេរ
- កុបិតចិត្តំ មានចិត្តខឹងក្រោធ
- អក្កោសនា បានជេរប្រទេច

** កាលណាគ្រប់អង្គទាំង ៣ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*

## វិនិច្ឆ័យសម្ផប្បលាបវាទ (ពាក្យសម្ដីឥតប្រយោជន៍)
## ដោយអាការ៥ ៖

១ - ដោយមូល មានមូល៣ គឺលោភមូល ទោសមូល និង មោហមូល

២ - ដោយកម្ម ជាវចីកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ



## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ គឺ ៖

- និយាយច្រើន មានទោសច្រើន
- និយាយតិច មានទោសតិច
- អ្នកដទៃកាន់យកនូវរឿងឥតប្រយោជន៍នោះ មានទោសច្រើន
- អ្នកដទៃមិនកាន់យកនូវរឿងឥតប្រយោជន៍នោះ មានទោសតិច

## ៥ - សម្ផប្បលាបវាទ មានអង្គ២ គឺ ៖

- និរត្ថកថា បុរេក្ខារតា ចិត្តចង់និយាយរឿងឥតប្រយោជន៍
- តថារូបីកថា កថនំ បាននិយាយនូវរឿងឥតប្រយោជន៍ មានភាពដូច្នោះ។

** កាលណាគ្រប់អង្គទាំង២ ឈ្មោះថាដាច់កម្មបថ  បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*



## * ចំណាំ

ការនិយាយដោយបំណងឲ្យអ្នកដទៃដឹងនូវរឿងឥតប្រយោជន៍ប៉ុណ្ណោះ ទើបចាត់ជាអកុសលកម្មបថ បើមិនមានបំណងឲ្យគេដឹងរឿងឥតប្រយោជន៍ទេ មិនចាត់ជាអកុសលកម្មបថឡើយ ប៉ុន្តែជាទ្វារនៃអកុសលចិត្ត។

មើលវីដេអូ ភាគទី ៣៣

# វិនិច្ឆ័យអភិជ្ឈា (ការសម្លឹងរំពៃចង់បាននូវភណ្ឌៈរបស់អ្នកដទៃ) ដោយអាការ ៥ ៖

| | |
|---|---|
| ១ - ដោយមូល | មានមូល២ គឺលោភមូល និងមោហមូល |
| ២ - ដោយកម្ម | ជាមនោកម្ម |
| ៣ - ដោយទ្វារ | សម្រេចតាមទ្វារ ៣ គឺកាយទ្វារ វចីទ្វារ និងមនោទ្វារ |

ស្កេនដើម្បីមើលមេរៀន

San Sochea Official






តាមមនោទ្វារ ខណៈពេលដែលគិតប៉ងយកទ្រព្យរបស់គេមកជារបស់ខ្លួន ដោយ ទុច្ចរិតកម្មផ្សេងៗ។



តាមវចីទ្វារ ខណៈពេលដែលគិតប៉ងយកទ្រព្យរបស់គេមកជារបស់ខ្លួន ដោយ ទុច្ចរិតកម្មផ្សេងៗ ក៏និយាយចេញមក។



តាមកាយទ្វារ ខណៈពេលដែលគិតប៉ងយកទ្រព្យរបស់គេមកជារបស់ខ្លួន ដោយ ទុច្ចរិតកម្មផ្សេងៗ ក៏ធ្វើតាមគំនិតនោះ។



៤ - ដោយទោស មានទំនងដូចអទិន្នាទាន

៥ - ដោយអង្គ អភិជ្ឈា មានអង្គ២ គឺ ៖

- បរភណ្ឌំ ទ្រព្យរបស់អ្នកដទៃ
- អត្តនោ បរិណាមនំ បង្អោនមកជារបស់ខ្លួន (ដោយបំណងអាក្រក់)។



## វិនិច្ឆ័យព្យាបាទ (បំណងចង់ឲ្យគេវិនាស) ដោយអាការ ៥ ៖

១- ដោយមូល មានមូល ២ គឺ ទោសមូល និងមោហមូល

២- ដោយកម្ម ជាមនោកម្ម

៣- ដោយទ្វារ សម្រេចតាមទ្វារ ៣ គឺកាយទ្វារ វចីទ្វារ និងមនោទ្វារ

## ព្យាបាទ កើតតាម ទ្វារ៣



តាមមនោទ្វារ   ខណៈដែលមានសេចក្ដី ខឹងក្រោធខ្លាំង ក៏គិតចង់ឲ្យគេវិនាស ដោយ ទុច្ចរិតកម្មផ្សេងៗ ។



តាមវចីទ្វារ  ខណៈដែលមានសេចក្ដី ខឹងក្រោធខ្លាំង រហូតគិតចង់ឲ្យគេវិនាស រួចក៏និយាយចេញមកតាមគំនិតនោះ។



តាមកាយទ្វារ   ខណៈដែលមានសេចក្ដី ខឹងក្រោធខ្លាំង រហូតគិតចង់ឲ្យគេវិនាស រួចក៏ធ្វើសកម្មភាពតាមគំនិតនោះ។



| | |
|---|---|
| ៤- ដោយទោស | មានទំនងដូចផរុសវាទ |
| ៥- ដោយអង្គ | ព្យាបាទ មានអង្គ ២ គឺ ៖ |
| - បរសត្តោ | សត្វដទៃ |
| - តស្ស ច វិនាសចិត្តោ | គិតឲ្យសត្វដទៃនោះវិនាស ។ |

## វិនិច្ឆ័យមិច្ឆាទិដ្ឋិ (ការឃើញខុសចាកសេចក្ដីពិត) ដោយអាការ ៥ ៖

| | |
|---|---|
| ១ - ដោយមូល | មានមូល ២ គឺលោភមូល និងមោហមូល |
| ២ - ដោយកម្ម | ជាមនោកម្ម |
| ៣ - ដោយទ្វារ | សម្រេចតាមទ្វារ ៣ គឺកាយទ្វារ វចីទ្វារ និងមនោទ្វារ |



## ៤ - ដោយទោស

| | |
|---|---|
| - សេពច្រើន | មានទោសច្រើន |
| - សេពតិច | មានទោសតិច |
| - យល់ខុសស៊ប់ | មានទោសច្រើន |
| - យល់ខុសមិនស៊ប់ | មានទោសតិច |

៥ - ដោយអង្គ     មិច្ឆាទិដ្ឋិ មានអង្គ២ គឺ ៖

- វត្ថុនោ ច គហិតាការវិបរិតតា     ចិត្តប្រែប្រួលដោយសភាព ខុសចាកអាការគួរកាន់យក មានព្រះរតនត្រៃជាដើម។

- យថា ច តំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ  ការប្រកាន់នូវរឿង មិនពិតនោះក៏ប្រាកដ។



# សង្គហគាថា

*អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា*

*មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ។*

អកុសលចិត្ត ១២ គឺ លោភមូលចិត្ត ៨ ទោសមូលចិត្ត ២ មោហមូលចិត្ត ២។

មើលវីដេអូ ភាគទី ៣៤




ស្កេនដើម្បីមើលមេរៀន

San Sochea Official



# មហាកុសលចិត្ត ៨ ដួង

## Eight Types of Moral Consciousness

**១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

Moral Consciousness, unprompted, accompanied by pleasure, associated with knowledge (wisdom).

## ១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៨ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណចេតសិក ២៥






## ២. សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយកើតឡើងដោយមានការបបួលដឹកនាំ។

Moral Consciousness, prompted, accompanied by pleasure, associated with knowledge (wisdom).

** មានចេតសិកប្រកបជាមួយ ៣៨ ប្រភេទ ដូចដួងទី ១ ដែរ ។*

## ៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

Moral Consciousness, unprompted, accompanied by pleasure, dissociated with knowledge (wisdom).



## ៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៧ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណចេតសិក ២៤ (វៀរបញ្ញា)



## ៤. សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្តប្រព្រឹត្តទៅជាមួយ សោមនស្សវេទនា ប្រាសចាកបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

Moral Consciousness, prompted, accompanied by pleasure, dissociated with knowledge (wisdom).

** មានចេតសិកកើតរួមជាមួយ ៣៧ ដូចដួងទី ៣។*



មើលវីដេអូ ភាគទី ៣៥

## ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

Moral Consciousness, unprompted, accompanied by indifference, associated with knowledge (wisdom).

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៧ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- សោភណចេតសិក ២៥






## ៦. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។ Moral Consciousness, prompted, accompanied by indifference, associated with knowledge (wisdom).

** មានចេតសិកកើតរួមជាមួយ ៣៧ ដូចដួងទី ៥។*

# ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាក បញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួល ដឹកនាំ។

Moral Consciousness, unprompted, accompanied by indifference, dissociated with knowledge (wisdom).



# ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ




មានចេតសិកកើតរួមជាមួយ ៣៦ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- សោភណចេតសិក ២៤ (វៀរបញ្ញា)

## ៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ

មហាកុសលចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាក បញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

Moral Consciousness, prompted, accompanied by indifference, dissociated with knowledge (wisdom).

** មានចេតសិកកើតរួមជាមួយ ៣៦ ដូចដួងទី ៧។*



## អត្ថរបស់កុសល ៥ យ៉ាង

១. អរោគ្យត្ថ ដោយអត្ថថាមិនមានរោគ (រាគៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ ឥស្សា មច្ឆរិយៈ ជាដើម ឈ្មោះថា រោគ ព្រោះជាគ្រឿងចាក់ដោតញាំញីនូវសន្តានចិត្តឱ្យញាប់ញ័រក្តៅក្រហាយ)។

២. សុន្ទរត្ថ ដោយអត្ថថា ស្អាតបរិសុទ្ធល្អ។

៣. ឆេកត្ថ ដោយអត្ថថា ឆ្លាតវៃ ឬ មុតស្រួច ក្នុងការកំចាត់បង់នូវភាពសៅហ្មងរបស់ចិត្ត។

៤. អនវជ្ជត្ថ ដោយអត្ថថា មិនមានទោស។

៥. សុខវិបាកត្ថ ដោយអត្ថថា មានវិបាកជាសុខ។

មើលវីដេអូ ភាគទី ៣៦

## លក្ខណាទិចតុក្កៈរបស់កុសល

១. អនវជ្ជសុខវិបាកលក្ខណំ មានវិបាកជាសុខដែលមិនមានទោស ជាលក្ខណៈ។

២. អកុសលវិទ្ធំសនរសំ មានការកម្ចាត់បង់នូវអកុសលជាកិច្ច។

៣. វោទានបច្ចុប្បដ្ឋានំ មានសភាពស្អាតផូរផង់ជាអាការប្រាកដ។

៤. យោនិសោមនសិការបទដ្ឋានំ មានការធ្វើទុកក្នុងចិត្តតាមទំនងហេតុផល ជាហេតុជិត។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## លក្ខណាទិចតុក្កៈរបស់កុសលន័យម៉្យាងទៀត

១. អនវជ្ជលក្ខណំ មានការមិនមានទោសជាលក្ខណៈ។

២. វោទានភាវរសំ មានសភាពស្អាតផូរផង់នៃចិត្តជាកិច្ច។

៣. ឥដ្ឋវិបាកបច្ចុប្បដ្ឋានំ មានវិបាកដែលជាទីប្រាថ្នា ជាផល ឬជាអាការប្រាកដ។

៤. យោនិសោមនសិការបទដ្ឋានំ មានការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ជាហេតុជិត។

# បុញ្ញកិរិយាវត្ថុ ១០

១. ទានមយ បុណ្យសម្រេចដោយការឱ្យទាន។
២. សីលមយ បុណ្យសម្រេចដោយការរក្សាសីល។
៣. ភាវនាមយ បុណ្យសម្រេចដោយការចម្រើនឱ្យចិត្តស្ងប់ (ឧបចារសមាធិ)។
៤. អបចាយនមយ បុណ្យសម្រេចដោយការគោរពឱនលំទោន។
៥. វេយ្យាវច្ចមយ បុណ្យសម្រេចដោយការជួយខ្នះខ្នែង ។
៦. បត្តិទានមយ បុណ្យសម្រេចដោយការចែកចំណែកបុណ្យឱ្យដល់អ្នកដទៃ។
៧. បត្តានុមោទនាមយ បុណ្យសម្រេចដោយការអនុមោទនាត្រេកអរនឹងបុណ្យអ្នកដទៃ កុសលរបស់អ្នកដទៃ។
៨. ធម្មទេសនាមយ បុណ្យសម្រេចដោយការសម្ដែងធម៌។
៩. ធម្មស្សវនមយ បុណ្យសម្រេចដោយការស្ដាប់ព្រះធម៌។
១០.ទិដ្ឋុជុកម្មមយ បុណ្យសម្រេចដោយការយល់ត្រង់ត្រឹមត្រូវតាមហេតុផល។



- បុញ្ញកិរិយាវត្ថុចាប់តាំងពីទី ១ ដល់ទី ៩ សម្រេចដោយមហាកុសល ៨ដួង ណានីមួយគ្រប់កាលទាំង ៣។

- ចំពោះទិដ្ឋុជុកម្ម អាចប្រព្រឹត្តទៅក្នុងមហាកុសល ៨ ដួង ណានីមួយតែមុនកាលនឹងធ្វើ និង កាលនឹងធ្វើជាខាងក្រោយ ប៉ុន្តែខណៈដែលកំពុងយល់ត្រូវអាចសម្រេចដោយមហាកុសលញាណសម្បយុត្ត ៤ ដួង ប៉ុណ្ណោះ។

## សង្ខេបបុញ្ញកិរិយាវត្ថុ ១០

បុញ្ញកិរិយាវត្ថុទាំង ១០ នេះបើបំព្រួញមកសល់ត្រឹមតែ ៣ ប៉ុណ្ណោះគឺ ៖

- ទានមយ បត្តិទានមយ និង បត្តានុមោទនាមយ ទាំង៣ នេះ សង្គ្រោះចូលក្នុងទាន។
- សីលមយ អបចាយនមយ និង វេយ្យាវច្ចមយ ទាំង ៣ នេះសង្គ្រោះចូលក្នុងសីល។
- ភាវនាមយ ធម្មទេសនាមយ និង ធម្មសវនមយ ទាំង ៣ នេះសង្គ្រោះចូលក្នុងភាវនា។

* ចំពោះ ទិដ្ឋុជុកម្ម សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ គឺក្នុងទានក៏បានក្នុងសីលក៏បាន ក្នុងភាវនាក៏បាន ។

* បុញ្ញកិរិយាវត្ថុទាំងអស់ (ក្រៅពីទិដ្ឋុជុកម្ម) បើមិនមានទិដ្ឋុជុកម្មទេ ក៏រមែងមិនសម្បូរឡើយ ។



## សម័យនៃមហាកុសល ៥ យ៉ាង ៖

១. ដោយការព្រមព្រៀង (នៃបច្ច័យច្រើន)

២. ដោយខណៈ

៣. ដោយកាល

៤. ដោយការប្រជុំ

៥. ដោយហេតុ

# ចក្កធម៌ ៤

| | |
|---|---|
| ១. បដិរូបទេសវាសោ | កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ (ជាពិសេសគឺកន្លែងដែលមានព្រះធម៌)។ |
| ២. សប្បុរិសូបនិស្សយោ | បានចូលទៅអាស្រ័យជាមួយសប្បុរស។ |
| ៣. អត្តសម្មាបណិធិ | តម្កល់ខ្លួនដោយប្រពៃ (បានដល់ភាពជាបុគ្គលដែលសប្បុរសប្រដៅបានងាយ)។ |
| ៤. បុព្វេកតបុញ្ញតា | ភាពជាបុគ្គលធ្វើបុណ្យទុកហើយក្នុងកាលមុន។ |



# វត្ថុជាទីសប្បាយនៃមហាកុសល

| | |
|---|---|
| ១. អាវាសជាទីសប្បាយ | ដូចជាផ្ទះសម្បែងឬវត្តអារាមជាដើមដែលរៀបរយបានល្អ។ |
| ២. ឥរិយាបថជាទីសប្បាយ | ការប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ស្មើល្អ។ |
| ៣. បុគ្គលជាទីសប្បាយ | បុគ្គលល្អទាំងរូបសម្បត្តិ គុណសម្បត្តិ និង បញ្ញាសម្បត្តិជាដើម។ |
| ៤. គោចរជាទីសប្បាយ | ផ្លូវធ្វើដំណើររាបស្មើល្អមិនរលាក់ មិនហុយជាដើម។ |
| ៥. កថាវត្ថុជាទីសប្បាយ | ការពោលវាចាជាកុសល មានទានកថា សីលកថា ជាដើម។ |
| ៦. ឧតុជាទីសប្បាយ | អាកាសធាតុមិនក្តៅពេក មិនត្រជាក់ពេក។ |
| ៧. ភោជនជាទីសប្បាយ | អាហារមានរសជាតិល្អ និង មានអនាម័យជាដើម។ |

# ការចែកមហាកុសលចិត្តដោយឧក្កដ្ឋៈ និង ឱមកៈ ដោយញាណសម្បយុត្តមាន៤ន័យ

មើលវីដេអូ ភាគទី ៣៧

## ន័យទី ១

**តិហេតុកឧក្កដ្ឋុក្កដ្ឋៈ**

| | |
|---|---|
| បុព្វចេតនា | (ល្អ) |
| មុញ្ចនចេតនា | (ល្អ) |
| អបរចេតនា | (ល្អ) |
| អបរាបរចេតនា | (ល្អ) |

ពាក្យថា ឧក្កដ្ឋុក្កដ្ឋៈ= ឧក្កដ្ឋៈ(ឧក្រិដ្ឋ) + ឧក្កដ្ឋៈ(ឧក្រិដ្ឋ)
ឧក្រិដ្ឋ = (ប្រណិតក្រៃលែង)។

ស្កេនដើម្បីមើលមេរៀន
San Sochea Official



## ន័យទី ២

**តិហេតុកឧក្កដ្ឋោមកៈ**

| | |
|---|---|
| បុព្វចេតនា | (ល្អ) |
| មុញ្ចនចេតនា | (ល្អ) |
| អបរចេតនា | (ល្អ) |
| អបរាបរចេតនា | (មិនល្អ) |

- ពាក្យថា ឧក្កដ្ឋោមកៈ = ឧក្កដ្ឋ (ឧក្រិដ្ឋ) + ឱមកៈ(មិនល្អ ឬមិនសូវល្អ)។
- ពាក្យ បុព្វចេតនា គឺមុនពេលធ្វើ, មុញ្ចនចេតនា គឺពេលកំពុងធ្វើ។

### ន័យទី ៣

| | | |
|---|---|---|
| តិហេតុកឱមកុក្កដ្ឋៈ | បុព្វចេតនា | (ល្អ) |
| | មុញ្ចនចេតនា | (ល្អ) |
| | អបរចេតនា | (មិនល្អ) |
| | អបរាបរចេតនា | (ល្អ) |

### ន័យទី ៤

| | | |
|---|---|---|
| តិហេតុកឱមកោមកៈ | បុព្វចេតនា | (ល្អ) |
| | មុញ្ចនចេតនា | (ល្អ) |
| | អបរចេតនា | (មិនល្អ) |
| | អបរាបរចេតនា | (មិនល្អ) |



## ដោយញាណវិប្បយុត្តមាន ៤ ន័យ

### ន័យទី ១

| | | |
|---|---|---|
| ទុហេតុកឧក្កដ្ឋុក្កដ្ឋៈ | បុព្វចេតនា | (ល្អ) |
| | មុញ្ចនចេតនា | (ល្អ) |
| | អបរចេតនា | (ល្អ) |
| | អបរាបរចេតនា | (ល្អ) |

ពាក្យ អបរចេតនា គឺក្រោយពេលធ្វើហើយភ្លាម ៗ  អបរាបរចេតនា គឺក្រោយពេលធ្វើហើយយូរៗ។

### ន័យទី ២

| | | |
|---|---|---|
| ទុហេតុកឧក្កដ្ឋោមកៈ | បុព្វចេតនា | (ល្អ) |
| | មុញ្ចនចេតនា | (ល្អ) |
| | អបរចេតនា | (ល្អ) |
| | អបរាបរចេតនា | (មិនល្អ) |

### ន័យទី ៣

**ទុហេតុកឱមកុក្កុដ្ឋះ**

- បុព្វចេតនា (ល្អ)
- មុញ្ចនចេតនា (ល្អ)
- អបរចេតនា (មិនល្អ)
- អបរាបរចេតនា (ល្អ)

### ន័យទី ៤

**ទុហេតុកឱមកោមកះ**

- បុព្វចេតនា (ល្អ)
- មុញ្ចនចេតនា (ល្អ)
- អបរចេតនា (មិនល្អ)
- អបរាបរចេតនា (មិនល្អ)

284

# អហេតុកចិត្ត ១៨ ដួង

## ក្នុងអហេតុកចិត្ត ១៨ ចែកចេញជា ៣ ប្រភេទគឺ ៖

ក - អកុសលវិបាកចិត្ត ៧ ដួង

ខ - អហេតុកកុសលវិបាកចិត្ត ៨ ដួង

គ - អហេតុកកិរិយាចិត្ត ៣ ដួង

## អកុសលវិបាកចិត្ត ៧ ដួង
## (Immoral Resultant Consciousness without Roots)

អកុសលវិបាកចិត្ត គឺចិត្តដែលជាវិបាករបស់អកុសលចិត្ត ឬថាជាផល របស់អកុសលកម្ម មាន ៧ ដួងគឺ ៖



### ១ - ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណអកុសលវិបាកចិត្តំ

ចក្ខុវិញ្ញាណ ជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា (ឃើញរូបមិនល្អ)។

Immoral resultant eye-consciousness, accompanied by indifference.





ចក្ខុវិញ្ញាណ កើតត្រង់ចក្ខុបសាទរូប ធ្វើ ទស្សនកិច្ច

**វចនត្ថៈ** របស់ចក្ខុវិញ្ញាណ **ចក្ខុំ និស្សិតំ វិញ្ញាណន្តិ** > **ចក្ខុវិញ្ញាណំ** ប្រែថា វិញ្ញាណអាស្រ័យចក្ខុបសាទកើតឡើង ឈ្មោះថា **ចក្ខុវិញ្ញាណ**។ ចក្ខុវិញ្ញាណនេះ ជាវិញ្ញាណម៉្យាងដែលអាស្រ័យនឹងចក្ខុវត្ថុ (ភ្នែក) កើតឡើងដើម្បីដឹងនូវរូបារម្មណ៍ជាលក្ខណៈ ដូចមានពាក្យបាលីថា **ចក្ខុនិស្សិតរូបវិជាននលក្ខណំ ចក្ខុវិញ្ញាណំ**។



## ហេតុនាំឱ្យកើតចក្ខុវិញ្ញាណមាន ៤ យ៉ាង គឺ ៖

- **អសម្ភិន្នត្តា ចក្ខុស្ស** ព្រោះចក្ខុបសាទមិនទាន់បែកធ្លាយ
- **អាបាថគតត្តា រូបានំ** ព្រោះរូបមកកាន់គន្លងនៃចក្ខុបសាទ
- **អាលោកសន្និស្សិតំ** អាស្រ័យនឹងពន្លឺ
- **មនសិការហេតុកំ** មានមនសិការជាហេតុជិត

## ២ - ឧបេក្ខាសហគតំ សោតវិញ្ញាណអកុសលវិបាកចិត្តំ

សោតវិញ្ញាណ ជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា (ឮសំឡេងមិនល្អ)។

Immoral resultant ear-consciousness, accompanied by indifference.



សោតវិញ្ញាណ កើតត្រង់សោតបសាទរូប ធ្វើសវនកិច្ច



វចនត្ថៈ របស់សោតវិញ្ញាណ សោតំ និស្សិតំ វិញ្ញាណន្តិ > សោត-វិញ្ញាណំ  វិញ្ញាណដែលអាស្រ័យនឹងសោតវត្ថុកើតឡើងឈ្មោះថា សោតវិញ្ញាណ ។ សោតវិញ្ញាណ នេះជាវិញ្ញាណម៉្យាងដែល អាស្រ័យនឹងសោតវត្ថុ (ត្រចៀក) កើតឡើងដើម្បីដឹងសំឡេងជា លក្ខណៈ ដូចមានបាលីថា សោតនិស្សិតសទ្ទវិជាននលក្ខណំ សោតវិញ្ញាណំ។

## ហេតុនាំឱ្យកើតសោតវិញ្ញាណមាន ៤ យ៉ាង គឺ ៖

| | |
|---|---|
| - អសម្ភិន្នត្តា សោតស្ស | ព្រោះសោតបសាទមិនទាន់បែកធ្លាយ |
| - អាបាថគតត្តា សទ្ទានំ | ព្រោះសំឡេងមកកាន់គន្លងនៃសោតបសាទ |
| - អាកាសសន្និស្សិតំ | អាស្រ័យនឹងអាកាស |
| - មនសិការហេតុកំ | មានមនសិការៈជាហេតុជិត |



## ៣ - ឧបេក្ខាសហគតំ ឃានវិញ្ញាណអកុសលវិបាកចិត្តំ

ឃានវិញ្ញាណ ជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយ ឧបេក្ខាវេទនា (ធុំក្លិនមិនល្អ)។

Immoral resultant nose-consciousness, accompanied by indifference.



ឃានវិញ្ញាណ កើតត្រង់ឃានបសាទរូប ធ្វើឃាយនកិច្ច

វចនត្ថៈ របស់ឃានវិញ្ញាណ ឃានំ និស្សិតំ វិញ្ញាណន្តិ > ឃាន-វិញ្ញាណំ វិញ្ញាណដែលអាស្រ័យនឹងឃានវត្ថុកើតឡើងឈ្មោះថា ឃានវិញ្ញាណ។ ឃានវិញ្ញាណនេះជាវិញ្ញាណម៉្យាងដែលអាស្រ័យនឹងឃានវត្ថុ (ច្រមុះ) កើតឡើងដើម្បីធុំក្លិនជាលក្ខណៈ ដូចមានបាលីថា ឃាននិស្សិតគន្ធវិជាននលក្ខណំ ឃានវិញ្ញាណំ។



## ហេតុនាំឱ្យកើតឃានវិញ្ញាណមាន ៤ យ៉ាង គឺ ៖

- អសម្ភិន្នត្តា ឃានស្ស ព្រោះឃានបសាទមិនទាន់បែកធ្លាយ
- អាបាថគតត្តា គន្ធានំ ព្រោះក្លិនមកកាន់គន្លងនៃឃានបសាទ
- វាយោសន្និស្សិតំ អាស្រ័យនឹងវាយោ (ខ្យល់)
- មនសិការហេតុកំ មានមនសិការជាហេតុជិត

## ៤ - ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណអកុសលវិបាកចិត្តំ



ជិវ្ហាវិញ្ញាណ ជាអកុសលវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា (ដឹងរសមិនល្អ)។

Immoral resultant, tongue-consciousness, accompanied by indifference.



ជិវ្ហាវិញ្ញាណ កើតត្រង់ជិវ្ហាបសាទរូប ធ្វើសាយនកិច្ច



វចនត្ថៈ របស់ជិវ្ហាវិញ្ញាណ ជិវ្ហំ និស្សិតំ វិញ្ញាណន្តិ > ជិវ្ហាវិញ្ញាណំ វិញ្ញាណដែលអាស្រ័យនឹងជិវ្ហាវត្ថុកើតឡើងឈ្មោះថា ជិវ្ហាវិញ្ញាណ។ ជិវ្ហាវិញ្ញាណនេះ ជាវិញ្ញាណម៉្យាងដែលអាស្រ័យនឹងជិវ្ហាវត្ថុ (អណ្ដាត) កើតឡើងដើម្បីដឹងរសជាលក្ខណៈ ដូចមានបាលីថា ជិវ្ហានិស្សិតរសវិជាននលក្ខណំ ជិវ្ហាវិញ្ញាណំ ។

## ហេតុនាំឱ្យកើតជិវ្ហាវិញ្ញាណមាន ៤ យ៉ាង គឺ ៖

- អសម្ភិន្នត្តា ជិវ្ហាយ — ព្រោះជិវ្ហាបសាទមិនទាន់បែកធ្លាយ
- អាបាថគតត្តា រសានំ — ព្រោះរសមកកាន់គន្លងនៃជិវ្ហាបសាទ
- អាបោសន្និស្សិតំ — អាស្រ័យនឹងអាបោ គឺ ទឹក
- មនសិការហេតុកំ — មានមនសិការជាហេតុជិត



មើលវីដេអូ ភាគទី ៣៨



## ៥ - ទុក្ខសហគតំ កាយវិញ្ញាណ អកុសលវិបាកចិត្តំ

កាយវិញ្ញាណ ជាអកុសលវិបាកចិត្ត កើតឡើងព្រមដោយ ទុក្ខវេទនា (ដឹងផោដ្ឋព្វៈមិនល្អ)។

Immoral resultant, Body-consciousness, accompanied by pain.

កាយវិញ្ញាណ កើតត្រង់កាយបសាទរូប ធ្វើផុសនកិច្ច
(គឺកិច្ចដឹង រឹង ទន់ ក្ដៅ ត្រជាក់ តឹង កម្រើក)

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## ហេតុនាំឱ្យកើតកាយវិញ្ញាណមាន ៤ យ៉ាង ៖

១ - អសម្ភិន្នត្តា កាយស្ស ព្រោះកាយបសាទមិនទាន់បែកធ្លាយ

២ - អាបាថគតត្តា ផោដ្ឋព្វានំ ព្រោះផោដ្ឋព្វៈ មកកាន់គន្លងនៃកាយបសាទ (សំដៅដល់មហាភូតរូប ៣ ដែលគួរដល់ការប៉ះខ្ទប់ និង កាយបសាទ គឺ (បឋវីធាតុ = រឹង ទន់)

(តេជោធាតុ = ក្តៅ ត្រជាក់)

(វាយោធាតុ កម្រើក តឹង ញ័រ)។

៣ - បឋវីសន្និស្សិតំ អាស្រ័យបឋវី

៤ - មនសិការហេតុកំ មានមនសិការៈជាហេតុផិត។



## ចេតសិកសម្បយុត្តំ

ចាប់ពីដួងទី១ ដល់ ទី៥ (ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណ) ក្នុងដួងនីមួយៗ មានចេតសិកកើតរួម ៧ ហៅថា សព្វចិត្តសាធារណចេតសិក



មើលវីដេអូ ភាគទី ៣៩



## ៦ - ឧបេក្ខាសហគតំ មនោធាតុ អកុសលវិបាកចិត្តំ (ឬ ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ)

មនោធាតុ ជាអកុសលវិបាកចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ។

Receiving consciousness, accompanied by indifference.

កើតត្រង់ហទយវត្ថុរូប ធ្វើ សម្បដិច្ឆន្នកិច្ច
(គឺកិច្ចទទួលដឹងអារម្មណ៍តាមទ្វារ ៥)

ស្កេនដើម្បីមើលមេរៀន

San Sochea Official

302

## ៦ - ឧបេក្ខាសហគតំ មនោធាតុ អកុសលវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ ១០ ប្រភេទ គឺ អញ្ញសមានាចេតសិក ១០ (វៀរ បីតិ វីរិយៈ ឆន្ទៈ)។



# ហេតុនាំឱ្យកើតមនោធាតុ ៤ យ៉ាង ៖

- អសម្ភិន្នត្តា បសាទស្ស ព្រោះបសាទរូបមិនទាន់បែកធ្លាយ
- អាបាថគតត្តា បញ្ចារម្មណានំ មានអារម្មណ៍ ៥ មកកាន់គន្លង
- ហទយសន្និស្សិតំ អាស្រ័យហទយវត្ថុ
- មនសិការហេតុកំ មានមនសិការៈជាហេតុជិត





**៧ - ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អកុសលវិបាកចិត្តំ (ឬ ឧបេក្ខាសហគតំ សន្តីរណចិត្តំ)**

មនោវិញ្ញាណធាតុ ជាអកុសលវិបាកចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា។

Investigating consciousness, accompanied by indifference.

កើតត្រង់ហទយវត្ថុរូប ធ្វើកិច្ច ៥

កិច្ច ២ នៅក្នុងទ្វារគឺ សន្តីរណកិច្ច និង តទាលម្ពណកិច្ច

កិច្ច ៣ នៅក្រៅទ្វារគឺ បដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច (ក្នុងអបាយភូមិ ៤)។

## ហេតុនាំឱ្យកើតមនោវិញ្ញាណធាតុ ៤ យ៉ាង ៖

- អសម្ភិន្នត្តា មនស្ស ព្រោះមនោមិនទាន់បែកធ្លាយ
- អាបាថគតត្តា ធម្មារម្មណានំ ព្រោះមានធម្មារម្មណ៍មកកាន់គន្លង
- ហទយសន្និស្សិតំ អាស្រ័យហទយវត្ថុ
- មនសិការហេតុកំ មានមនសិការៈជាហេតុជិត



# ចេតសិកសម្បយុត្ត

ដួងទី ៦ និងដួងទី ៧ ដួងនីមួយៗ មានចេតសិកកើតរួមជាមួយ ១០ ប្រភេទ គឺ អញ្ញសមានាចេតសិក ១០ (វៀរ បីតិ វិរិយៈ ឆន្ទៈ)។



# អាយុរូបមួយ (អារម្មណ៍) ស្មើ ១៧ ខណៈចិត្ត

មើលវីដេអូ ភាគទី ៤០







ស្កេនដើម្បីមើលមេរៀន

San Sochea Official



មើលវីដេអូ ភាគទី ៤១

## អហេតុកកុសលវិបាកចិត្ត ៨ ដួង
## (Moral Resultant Consciousness without Roots)

អហេតុកកុសលវិបាកចិត្ត គឺចិត្តដែលជាវិបាករបស់មហាកុសលចិត្ត ៨ ដួង ឬថាជាផលរបស់កុសលកម្ម មាន ៨ ដួងគឺ ៖

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## ១ - ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណ កុសលវិបាកចិត្តំ

ចក្ខុវិញ្ញាណ ជាកុសលវិបាកចិត្ត កើតឡើង
ព្រមដោយ ឧបេក្ខាវេទនា (ឃើញរូបល្អ)។

Moral resultant eye-consciousness, accompanied by indifference.



ចក្ខុវិញ្ញាណ កើតត្រង់ចក្ខុបសាទរូប ធ្វើទស្សនកិច្ច



## ២ - ឧបេក្ខាសហគតំ សោតវិញ្ញាណ កុសលវិបាកចិត្តំ

សោតវិញ្ញាណ ជាកុសលវិបាកចិត្ត កើតឡើង
ព្រមដោយ ឧបេក្ខាវេទនា (ឮសំឡេងល្អ)។

Moral resultant ear-consciousness, accompanied by indifference.



សោតវិញ្ញាណ កើតត្រង់សោតបសាទរូប ធ្វើសវនកិច្ច

## ៣ - ឧបេក្ខាសហគតំ ឃានវិញ្ញាណ កុសលវិបាកចិត្តំ



ឃានវិញ្ញាណ ជាកុសលវិបាកចិត្ត កើតឡើង

ព្រមដោយ ឧបេក្ខាវេទនា (ធុំក្លិនល្អ)។

Moral resultant nose-consciousness, accompanied by indifference.



ឃានវិញ្ញាណ កើតត្រង់ឃានបសាទរូប ធ្វើឃាយនកិច្ច



## ៤ - ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណ កុសលវិបាកចិត្តំ




ជិវ្ហាវិញ្ញាណ ជាកុសលវិបាកចិត្ត កើតឡើង

ព្រមដោយ ឧបេក្ខាវេទនា (ដឹងរសល្អ)។

Moral resultant, tongue-consciousness, accompanied by indifference.



ជិវ្ហាវិញ្ញាណ កើតត្រង់ជិវ្ហាបសាទរូប ធ្វើសាយនកិច្ច



៥ - សុខសហគតំ កាយវិញ្ញាណ កុសលវិបាកចិត្តំ

កាយវិញ្ញាណ ជាកុសលវិបាកចិត្ត កើតឡើង

ព្រមដោយ សុខវេទនា (ដឹងផោដ្ឋព្វៈល្អ)។

Moral resultant, Body-consciousness,

accompanied by happiness.

កាយវិញ្ញាណ កើតត្រង់កាយបសាទរូប ធ្វើផុសនកិច្ច

(គឺកិច្ចដឹង រឹង ទន់ ក្តៅ ត្រជាក់ តឹង កម្រើក)





៥ - សុខសហគតំ កាយវិញ្ញាណ កុសលវិបាកចិត្តំ

កាយវិញ្ញាណ ជាកុសលវិបាកចិត្ត កើតឡើង

ព្រមដោយ សុខវេទនា (ដឹងផោដ្ឋព្វៈល្អ)។

Moral resultant, Body-consciousness,

accompanied by happiness.

កាយវិញ្ញាណ កើតត្រង់កាយបសាទរូប ធ្វើផុសនកិច្ច

(គឺកិច្ចដឹង រឹង ទន់ ក្តៅ ត្រជាក់ តឹង កម្រើក)

# ចេតសិកសម្បយុត្តំ

ចាប់ពីដួងទី ១ ដល់ ទី ៥ (ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណ) ក្នុងដួងនីមួយៗ មានចេតសិកកើតរួម ៧ ហៅថា សព្វចិត្តសាធារណចេតសិក








## ៦ - ឧបេក្ខាសហគតំ មនោធាតុ កុសលវិបាកចិត្តំ (ឬ ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ)

មនោធាតុ ជាកុសលវិបាកចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ។

Receiving consciousness, accompanied by indifference.

កើតត្រង់ហទយវត្ថុរូប ធ្វើ សម្បដិច្ឆន្នកិច្ច (គឺកិច្ចទទួលដឹងអារម្មណ៍តាមទ្វារ ៥)

# ៦ - ឧបេក្ខាសហគតំ មនោធាតុ កុសលវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ ១០ ប្រភេទ គឺ អញ្ញសមានាចេតសិក ១០ (វៀរ បីតិ វីរិយៈ ឆន្ទៈ)។









សម្បដិច្ឆន្នកិច្ច

កិច្ចទទួលយកនូវអារម្មណ៍ បន្ទាប់អំពីទ្វិបញ្ចវិញ្ញាណ ។



## ៧ - សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ
## (ឬ សោមនស្សសហគតំ សន្តីរណចិត្តំ)

មនោវិញ្ញាណធាតុ ជាអហេតុកកុសលវិបាកចិត្ត
កើតឡើងព្រមដោយសោមនស្សវេទនា។

Investigating consciousness, accompanied by pleasure.

កើតត្រង់ហទយវត្ថុរូប
ធ្វើកិច្ច ២ គឺ សន្តីរណកិច្ច និង តទាលម្ពណកិច្ច ។



## ៧ - សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ
១១ប្រភេទ គឺ
អញ្ញសមានាចេតសិក ១១
(វៀរ វិរិយៈ ឆន្ទៈ)។






សន្តីរណកិច្ច កិច្ចពិចារណានូវអារម្មណ៍
តាមទ្វារ ៥ ។

តទាលម្ពណកិច្ច កិច្ចតោងយកនូវអារម្មណ៍
តាមទ្វារទាំង ៦។





## ៨ - ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុក កុសលវិបាកចិត្តំ (ឬ ឧបេក្ខាសហគតំ សន្តីរណចិត្តំ)

មនោវិញ្ញាណធាតុ ជាអហេតុកកុសលវិបាកចិត្ត
កើតឡើងព្រមដោយឧបេក្ខាវេទនា ។

Investigating consciousness, accompanied by indifference.

កើតត្រង់ហទយវត្ថុរូប ធ្វើកិច្ច ៥
កិច្ច ២ នៅក្នុងទ្វារគឺ សន្តីរណកិច្ច និង តទាលម្ពណកិច្ច
កិច្ច ៣ នៅក្រៅទ្វារគឺ បដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច
(ក្នុងសុគតិដែលខ្វះបុណ្យ)។

## ៨ - ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុក-កុសលវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ ១០ប្រភេទ គឺ អញ្ញសមានាចេតសិក ១០ (វៀរ បីតិ វីរិយៈ ឆន្ទៈ)។













# អារម្មណ៍ ២ យ៉ាង

១ - អនិដ្ឋារម្មណ៍ អារម្មណ៍មិនល្អ ឬអារម្មណ៍មិនជាទីប្រាថ្នា

២ - ឥដ្ឋារម្មណ៍ អារម្មណ៍ជាទីប្រាថ្នា
- មជ្ឈត្តឥដ្ឋារម្មណ៍ អារម្មណ៍ល្អថ្នាក់កណ្តាល
- អតិឥដ្ឋារម្មណ៍ អារម្មណ៍ល្អក្រៃលែង

អកុសលវិបាកចិត្ត ៧ ដួង ប្រកបដោយវេទនា ២ គឺ ទុក្ខវេទនា និងឧបេក្ខាវេទនា តែងដឹងអនិដ្ឋារម្មណ៍។ ដួងទី ៥ (កាយវិញ្ញាណ) ប្រកបដោយទុក្ខវេទនា ក្រៅពីនេះ ប្រកបដោយឧបេក្ខាវេទនាទាំងអស់ ។

អហេតុកកុសលវិបាកចិត្ត ៨ ដួង ប្រកបដោយវេទនា ៣ គឺ សុខវេទនា សោមនស្សវេទនា និងឧបេក្ខា-វេទនា តែងដឹងនូវឥដ្ឋារម្មណ៍ ។ ដួងទី ៥ (កាយវិញ្ញាណ) ប្រកបដោយសុខវេទនា, ដួងទី ៧ (សោមនស្សសន្តីរណៈ) ប្រកបដោយសោមនស្ស -វេទនា ក្រៅពីនេះ ប្រកបដោយឧបេក្ខាវេទនាទាំងអស់។

## ប្រៀបធៀបអកុសលវិបាកនិងអហេតុកកុសលវិបាក

**អកុសលវិបាកចិត្ត៧ ដួង ដឹងអនិដ្ឋារម្មណ៍តែម្យ៉ាង**

១- ចក្ខុវិញ្ញាណ
២- សោតវិញ្ញាណ
៣- ឃានវិញ្ញាណ
៤- ជិវ្ហាវិញ្ញាណ
៥- កាយវិញ្ញាណ
៦- សម្បដិច្ឆន្នចិត្ត (ឬវិបាកមនោធាតុ)
៧- ឧបេក្ខាសន្តីរណចិត្ត (អកុសលវិបាក-មនោវិញ្ញាណធាតុ)

} តែងដឹង អនិដ្ឋារម្មណ៍ តែប៉ុណ្ណោះ

**អហេតុកកុសលវិបាកចិត្ត ៨ ដួង ដឹងឥដ្ឋារម្មណ៍ ២ យ៉ាង**

១- ចក្ខុវិញ្ញាណ
២- សោតវិញ្ញាណ
៣- ឃានវិញ្ញាណ
៤- ជិវ្ហាវិញ្ញាណ
៥- កាយវិញ្ញាណ
៦- សម្បដិច្ឆន្នចិត្ត (ឬវិបាកមនោធាតុ)

→ តែងដឹង មជ្ឈត្តឥដ្ឋារម្មណ៍

៧- សោមនស្សសន្តីរណចិត្ត → ដឹងចំពោះតែ អតិឥដ្ឋារម្មណ៍
៨- ឧបេក្ខាសន្តីរណចិត្ត → (តែងដឹង មជ្ឈត្តឥដ្ឋារម្មណ៍)



មើលវីដេអូ ភាគទី ៤២



កើតត្រង់ហទយវត្ថុរូប
ធ្វើ អាវជ្ជនកិច្ច
(កិច្ចពិចារណាកអារម្មណ៍តាមបញ្ចទ្វារ)។

# អហេតុកកិរិយាចិត្ត ៣ ដួង

**Functional Consciousness without Roots**

## ១ - ឧបេក្ខាសហគតំ មនោធាតុ កិរិយាចិត្តំ (បញ្ចទ្វារាវជ្ជនចិត្ត ឬ កិរិយាមនោធាតុ)

មនោធាតុ ជាកិរិយាចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ។

Five Sense-door adverting consciousness, accompanied by indifference.

ស្កេនដើម្បីមើលមេរៀន
San Sochea Official

# ១ - ឧបេក្ខាសហគតំ មនោធាតុ កិរិយាចិត្តំ

មានចេតសិកកើតរួមជាមួយ ១០ប្រភេទ គឺ អញ្ញសមានាចេតសិក ១០ (វៀរ បីតិ វិរិយៈ ឆន្ទៈ)។










## ២ - ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ (មនោទ្វារាវជ្ជនចិត្តំ)

មនោវិញ្ញាណធាតុ ជាអហេតុកកិរិយាចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ។

Mind-door adverting consciousness, accompanied by indifference.

កើតត្រង់ហទយវត្ថុរូប ធ្វើកិច្ចពីរគឺ

- វោដ្ឋវនកិច្ច (កិច្ចកំណត់ ឬកាត់ក្តីអារម្មណ៍តាមបញ្ចទ្វារ)
- មនោទ្វារាវជ្ជនកិច្ច (កិច្ចរាវរកអារម្មណ៍តាមមនោទ្វារ)



## ២ - ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ

មានចេតសិកកើតរួមជាមួយ ១១ប្រភេទ គឺ អញ្ញសមានាចេតសិក ១១ (វៀរ បីតិ ឆន្ទៈ)។




អាវជ្ជនកិច្ច កិច្ចរាវរកអារម្មណ៍តាមបញ្ចទ្វារ
ឬហៅថា បញ្ចទ្វារាវជ្ជនកិច្ច
តាមបញ្ចទ្វារ
ចក្ខុ
សោ
អ ច ទ អា ឃា ស តី វ ជ ជ ជ ជ ជ ជ ជ ទា ទា ភ ភ
ជិ
កា
វោដ្ឋវនកិច្ច កិច្ចកំណត់ ឬកាត់ក្តីអារម្មណ៍តាមបញ្ចទ្វារ
មនោទ្វារាវជ្ជនកិច្ច (កិច្ចរាវរកអារម្មណ៍តាមមនោទ្វារ)
តាមមនោទ្វារ
ភ ច ទ ម ជ ជ ជ ជ ជ ជ ជ ទា ទា ភ ភ




វិថីបដិបាទកមនសិការ ជាបាទ ឬជាគ្រឿងទ្រនៃវិថីចិត្ត
តាមបញ្ចទ្វារ
ចក្ខុ
សោ
អ ច ទ អា ឃា ស តី វ ជ ជ ជ ជ ជ ជ ជ ទា ទា ភ ភ
ជិ
កា
ជវនបដិបាទកមនសិការ ជាបាទ ឬជាគ្រឿងទ្រនៃជវន
តាមមនោទ្វារ
ភ ច ទ ម ជ ជ ជ ជ ជ ជ ជ ទា ទា ភ ភ

មើលវីដេអូ ភាគទី ៤៣



## ៣ - សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ (ហសិតុប្បាទចិត្ត)

មនោវិញ្ញាណធាតុ ជាអហេតុកកិរិយាចិត្ត កើតឡើងព្រមដោយសោមនស្សវេទនា (ជាចិត្តញុំាងការញញឹមរបស់ព្រះអរហន្ត ឲ្យប្រាកដឡើង ពេលជួបហេតុណាមួយដែលប្លែក) ។

Smile-producing consciousness, accompanied by pleasure.

កើតត្រង់ហទយវត្ថុរូប ធ្វើ ជវនកិច្ច

ស្កេនដើម្បីមើលមេរៀន

San Sochea Official





## ៣ - សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ (ហសិតុប្បាទចិត្ត)

មនោវិញ្ញាណធាតុ ជាអហេតុកកិរិយាចិត្ត កើតឡើងព្រមដោយសោមនស្សវេទនា (ជាចិត្តញុំាងការញញឹមរបស់ព្រះអរហន្ត ឲ្យប្រាកដឡើង ពេលជួបហេតុណាមួយដែលប្លែក)។

Smile-producing consciousness, accompanied by pleasure.

កើតត្រង់ហទយវត្ថុរូប ធ្វើ ជវនកិច្ច

# ៣ - សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ

មានចេតសិកកើតរួមជាមួយ ១២ប្រភេទ គឺ អញ្ញសមានាចេតសិក ១២ (វៀរឆន្ទៈ)។









ជវនកិច្ច កិច្ចសោយនូវអារម្មណ៍ ឬស្ទុះទៅកាន់អារម្មណ៍

# សង្គហន័យនៃអហេតុកចិត្ត ១៨ មាន ៤ ន័យគឺ ៖

ន័យទី១ ហសិតុប្បាទចិត្ត (អហេតុកកិរិយាដួងទី ៣) ១ ដួង មានចេតសិកកើតរួមជាមួយ ១២ ប្រភេទ គឺអញ្ញសមានាចេតសិក ១២ (វៀរឆន្ទៈ)

ន័យទី២ មនោទ្វារាវជ្ជនចិត្ត (អហេតុកកិរិយាចិត្តដួងទី ២) ១ ដួង មានចេតសិកកើតរួម ១១ ប្រភេទគឺ អញ្ញសមានាចេតសិក ១១ (វៀរបីតិ ឆន្ទៈ) សោមនស្សសន្តីរណចិត្ត ១ ដួង មានចេតសិកកើតរួម ១១ ប្រភេទគឺ អញ្ញសមានាចេតសិក ១១ (វៀរ វីរិយ ឆន្ទៈ)។



ន័យទី៣ បញ្ចទ្វារាវជ្ជនចិត្ត (អហេតុកកិរិយាចិត្តដួងទី ១) ១ ដួង សម្បដិច្ឆន្នចិត្ត (វិបាកមនោធាតុ) ២ ដួង ឧបេក្ខាសន្តីរណចិត្ត ២ ដួង (គឺអកុសលវិបាកចិត្តដួងទី ៧ និង អហេតុកកុសលវិបាកចិត្ត ដួងទី ៨) ដួងនីមួយៗមានចេតសិកកើតរួមជាមួយ ១០ប្រភេទ គឺ អញ្ញសមានា-ចេតសិក ១០ (វៀរ បីតិ វីរិយៈ ឆន្ទៈ)។

ន័យទី៤ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ (គឺចក្ខុវិញ្ញាណចិត្ត ២ សោតវិញ្ញាណចិត្ត ២ ឃានវិញ្ញាណចិត្ត ២ ជិវ្ហាវិញ្ញាណចិត្ត ២ និង កាយវិញ្ញាណចិត្ត ២) ក្នុងដួងនីមួយៗ មានចេតសិកកើតរួម ៧ ហៅថា សព្វចិត្តសាធារណចេតសិក ។

# ការចែកអសោភណចិត្ត៣០ ដោយន័យផ្សេង ៗ

១ - ដោយជាតិ មានជាតិ ៣ គឺ ៖

- អកុសលចិត្ត ១២ ជាអកុសលជាតិ
- អហេតុកវិបាកចិត្ត ១៥ ជាវិបាកជាតិ
- អហេតុកកិរិយាចិត្ត ៣ ជាកិរិយាជាតិ

២ - ដោយភូមិ ជាកាមាវចរភូមិ

៣ - ដោយសោភណ ជាអសោភណចិត្ត

ព្រោះមិនមានសោភណចេតសិកណាមួយ ដូចជា សទ្ធា សតិ ហិរិ ជាដើម កើតរួមជាមួយឡើយ។

៤ - ដោយខន្ធ ជាវិញ្ញាណខន្ធ។



៥ - ដោយលោកិយ ជាលោកិយចិត្ត ព្រោះជាប់ក្នុងលោក។

៦ - ដោយអាយតនៈ ជាមនាយតនៈ។

៧ - ដោយធាតុ ជាវិញ្ញាណធាតុ ៧។

៨ - ដោយសច្ចៈ ជាទុក្ខសច្ចៈ។

៩ - ដោយឥន្ទ្រិយ ជាមនិន្ទ្រិយ។

១០ - ដោយវេទនា មានវេទនា ៥។

១១ - ដោយហេតុ ចិត្តទាំង ៣០ ដួងនេះសុទ្ធតែជា នហេតុ (មិនមែនតួហេតុ ) ទាំងអស់។

១២ - ដោយកិច្ច កិច្ចរបស់ចិត្តទាំងអស់មាន ១៤។

## អសោភណចិត្ត ៣០ ដួងនេះធ្វើកិច្ចផ្សេង ៗ គ្នាយ៉ាងនេះ ៖

១. អកុសលចិត្ត ១២ និង ហសិតុប្បាទចិត្ត ១, ១៣ ដួង នេះ ធ្វើជវនកិច្ច តាមទ្វារទាំង ៦។

| | |
|---|---|
| ២. ចក្ខុវិញ្ញាណចិត្ត | ២ ដួង ធ្វើ ទស្សនកិច្ច |
| ៣. សោតវិញ្ញាណចិត្ត | ២ ដួង ធ្វើ សវនកិច្ច |
| ៤. ឃានវិញ្ញាណចិត្ត | ២ ដួង ធ្វើ ឃាយនកិច្ច |
| ៥. ជិវ្ហាវិញ្ញាណចិត្ត | ២ ដួង ធ្វើ សាយនកិច្ច |
| ៦. កាយវិញ្ញាណចិត្ត | ២ ដួង ធ្វើ ផុស្សនកិច្ច |



៧. វិបាកមនោធាតុ ២ ដួង ធ្វើ សម្បដិច្ឆន្នកិច្ច

៨. អហេតុកអកុសលវិបាកដួងទី ៧ ធ្វើកិច្ច ៥ យ៉ាងគឺ ៖ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច (ក្នុងអបាយភូមិ) និង សន្តីរណកិច្ច តទាលម្ពណកិច្ច។

៩. អហេតុកកុសលវិបាកដួងទី ៧ ប្រកបដោយសោមនស្សវេទនា ធ្វើកិច្ច ២ គឺ សន្តីរណកិច្ច និង តទាលម្ពណកិច្ច។

១០. អហេតុកកុសលវិបាកដួងទី ៨ ធ្វើកិច្ច ៥ យ៉ាង គឺ ៖ បដិសន្ធិ ភវង្គ ចុតិ (ក្នុងមនុស្សនិងទេវតាថ្នាក់ទាប មានសភាពជាអ្នកខ្វះបុណ្យ ដូចជា មនុស្សគ ថ្លង់ ឆ្កួត ជាដើមតាំងពីកំណើត ) សន្តីរណកិច្ច និង តទាលម្ពណកិច្ច។

១១. កិរិយាមនោធាតុ ធ្វើអាវជ្ជនកិច្ចតាមបញ្ចទ្វារ ឬ ហៅថា បញ្ចទ្វារាវជ្ជនកិច្ច។

១២. អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខាវេទនា ធ្វើកិច្ច ២ គឺ ៖

- វោដ្ឋព្វនកិច្ច តាមបញ្ចទ្វារ។
- មនោទ្វារាវជ្ជនកិច្ច តាមមនោទ្វារ។



## គាថាសង្គហអហេតុកចិត្ត

មើលវីដេអូ ភាគទី ៤៤

សត្តាកុសលបាកានិ　　បុញ្ញបាកានិ អដ្ឋធា
ក្រិយាចិត្តានិ តីណីតិ　　អដ្ឋារស អហេតុកា

អហេតុកចិត្តមាន ១៨ ដួង គឺ អកុសលវិបាកចិត្ត ៧ ដួង អហេតុកកុសល វិបាកចិត្ត ៨ ដួង អហេតុកកិរិយាចិត្ត ៣ ដួង។

បាបាហេតុកមុត្តានិ　　សោភណានីតិ វុច្ចរេ
ឯកូនសដ្ឋី ចិត្តានិ　　អថេកនវុតីបិ វា

ចិត្ត ៥៩ ដួង ឬ ៩១ ដួង ដែលផុតចាកអំពីអកុសលចិត្ត និង អហេតុកចិត្ត បណ្ឌិតហៅថា សោភណចិត្ត។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# សោភណចិត្ត ៥៩ ឬ ៩១ ដួង
# សោភណចិត្ត ៤ ប្រភេទ ៖

ក្នុងបណ្ដាសោភណចិត្តទាំងអស់ចែកចេញជា ៤ ប្រភេទ ៖

១. កាមាវចរសោភណចិត្ត ២៤ ដួង

២. រូបាវចរសោភណចិត្ត ១៥ ដួង

៣. អរូបាវចរសោភណចិត្ត ១២ ដួង

៤. លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង



## ១. កាមាវចរសោភណចិត្ត ២៤ ដួង

ក. កាមាវចរកុសលចិត្ត ៨ ដួង (ឬមហាកុសលចិត្ត)

ខ. កាមាវចរវិបាកចិត្ត ៨ ដួង (ឬមហាវិបាកចិត្ត )

គ. កាមាវចរកិរិយាចិត្ត ៨ ដួង (ឬមហាកិរិយាចិត្ត )

# ក. មហាកុសលចិត្ត ៨ ដួង

| | | | |
|---|---|---|---|
| ១- សោមនស្សសហគតំ | ញាណសម្បយុត្តំ | អសង្ខារិកំ | មហាកុសលចិត្តំ |
| ២. សោមនស្សសហគតំ | ញាណសម្បយុត្តំ | សសង្ខារិកំ | មហាកុសលចិត្តំ |
| ៣. សោមនស្សសហគតំ | ញាណវិប្បយុត្តំ | អសង្ខារិកំ | មហាកុសលចិត្តំ |
| ៤. សោមនស្សសហគតំ | ញាណវិប្បយុត្តំ | សសង្ខារិកំ | មហាកុសលចិត្តំ |
| ៥. ឧបេក្ខាសហគតំ | ញាណសម្បយុត្តំ | អសង្ខារិកំ | មហាកុសលចិត្តំ |
| ៦. ឧបេក្ខាសហគតំ | ញាណសម្បយុត្តំ | សសង្ខារិកំ | មហាកុសលចិត្តំ |
| ៧. ឧបេក្ខាសហគតំ | ញាណវិប្បយុត្តំ | អសង្ខារិកំ | មហាកុសលចិត្តំ |
| ៨. ឧបេក្ខាសហគតំ | ញាណវិប្បយុត្តំ | សសង្ខារិកំ | មហាកុសលចិត្តំ |



# ការចែកមហាកុសលចិត្ត ៨ ដួងដោយន័យផ្សេង ៗ

| | |
|---|---|
| ១. ដោយជាតិ | ជាកុសលជាតិ។ |
| ២. ដោយភូមិ | ជាកាមាវចរភូមិ (កើតបាន ៣០ ភូមិ)។ |
| ៣. ដោយវេទនា | ជាសោមនស្សវេទនា ៤ ដួង ជាឧបេក្ខាវេទនា ៤ ដួង។ |
| ៤. ដោយហេតុ | ជានហេតុ និង ជាសហេតុកចិត្ត។ |
| ៥. ដោយសម្បយុត្ត | ជាញាណសម្បយុត្ត ៤ ដួង ជាញាណវិប្បយុត្ត៤ |
| ៦. ដោយសង្ខារ | ជាអសង្ខារិក ៤ ដួង ជាសសង្ខារិក ៤ ដួង។ |

| | |
|---|---|
| ៧. ដោយសោភណៈ | ជាកាមាវចរសោភណចិត្ត។ |
| ៨. ដោយឈាន | ជាអឈានចិត្ត។ |
| ៩. ដោយលោកិយ | ជាលោកិយចិត្ត។ |
| ១០. ដោយកិច្ច | ធ្វើជវនកិច្ចតែម្យ៉ាង។ |
| ១១. ដោយអារម្មណ៍ | ដឹងអារម្មណ៍ទាំង៦។ |
| ១២. ដោយទ្វារ | កើតតាមទ្វារទាំង៦។ |
| ១៣. ដោយវត្ថុ | កើតត្រង់ហទយវត្ថុ។ |
| ១៤. ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ។ |



មើលវីដេអូ ភាគទី ៤៥

## ខ. មហាវិបាកចិត្ត ៨ ដួង

### ១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញាជាអសង្ខារិក។

One consciousness, unprompted, accompanied by pleasure, associated with knowledge.

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# ១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណចេតសិក ២០

(វៀរវិរតិ ៣ និង អប្បមញ្ញា ២)






# ២. សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្ស-វេទនា ប្រកបដោយបញ្ញាជាសសង្ខារិក។

One consciousness, prompted, accompanied by pleasure, associated with knowledge.

** មានចេតសិកប្រកបជាមួយ ៣៣ ប្រភេទ ដូចដួងទី ១ ដែរ។*

## ៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកបញ្ញា ជាអសង្ខារិក។

One consciousness, unprompted, accompanied by pleasure, dissociated with knowledge.



## ៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ ៣២ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណចេតសិក ១៩ (វៀរវិរតិ ៣ និង អប្បមញ្ញា ២ និងបញ្ញា ១)



## ៤. សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកបញ្ញា ជាសសង្ខារិក។

One consciousness, prompted, accompanied by pleasure, dissociated with knowledge.

** មានចេតសិកប្រកបជាមួយ ៣២ ប្រភេទ ដូចដួងទី ៣ ដែរ។*



## ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញាជា អសង្ខារិក។

One consciousness, unprompted, accompanied by indifference, associated with knowledge.

## ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ ៣២ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរ បីតិ)
- សោភណចេតសិក ១៩ (វៀរវិរតិ ៣ និង អប្បមញ្ញា ២)






## ៦. ឧបេក្ខាសហគតំ  ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញាជាសសង្ខារិក។

One consciousness, prompted, accompanied by indifference, associated with knowledge.

** មានចេតសិកប្រកបជាមួយ ៣២ ប្រភេទ ដូចដួងទី ៥ ដែរ។*

## ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាក បញ្ញាជាអសង្ខារិក។

One consciousness, unprompted, accompanied by indifference, dissociated with knowledge.



## ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ

មានចេតសិកកើតរួមជាមួយ ៣១ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរ បីតិ)
- សោភណចេតសិក ១៩ (វៀរវិរតិ ៣ និង អប្បមញ្ញា ២ បញ្ញា ១)



## ៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ

មហាវិបាកចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញា ជាសសង្ខារិក។

One consciousness, prompted, accompanied by indifference, dissociated with knowledge.

** មានចេតសិកប្រកបជាមួយ ៣១ ប្រភេទ ដូចដួងទី ៧ ដែរ។*



## អានិសង្សរបស់តិហេតុកកុសល

- **ន័យទី១** (តិហេតុកឧក្កដ្ឋុក្កដ្ឋ:) ឱ្យនូវវិបាក ១៦ ដួង គឺមហាវិបាកចិត្ត ៨ ដួង អហេតុកកុសលវិបាកចិត្ត ៨ ដួង ហើយមានអានិសង្សខ្ពស់បំផុតអាចឱ្យកើតក្នុងមនុស្ស និង ទេវតាដែលសម្បូរបុណ្យបរិបូរណ៌ដោយមនុស្សសម្បត្តិ សួគ៌សម្បត្តិ។ ម៉្យាងទៀត រមែងជាអ្នកមានបញ្ញា អាចសម្រេចមគ្គផលនិព្វាន និង ឈានសមាបត្តិបានក្នុងជាតិដែលខ្លួនកើតហើយនោះ តាមសមគួរដល់ឧបនិស្ស័យ ចាត់ជាបុគ្គលប្រណីតក្រៃលែង មានសេចក្តីសុខតាំងពីក្មេងដល់ចាស់។

- **ន័យទី២** (តិហេតុកឧក្កដ្ឋោមកៈ) ការឱ្យនូវផលក៏ដូចនឹងន័យទី ១ ដែរ ប៉ុន្តែមិនល្អរហូតទេ តែងមិនល្អក្នុងពេលជាខាងក្រោយ។



- **ន័យទី៣** (តិហេតុកឱមកុក្កដ្ឋៈ) នាំឱ្យវិបាកបដិសន្ធិជាទុហេតុកបុគ្គល និងនាំឱ្យមានវិបាកក្នុងបវត្តិកាល ១២ ដួងគឺៈ មហាវិបាកញាណវិប្បយុត្ត ៤ ដួង និង អហេតុកកុសលវិបាកចិត្ត ៨ ដួង។ ក្នុងជីវិតរស់នៅមានសេចក្ដីសុខខ្លះ ៗ ជាអន្លើ ៗ ឡើងចុះៗ វ័យក្មេងមិនល្អ ពេញវ័យល្អ និង វ័យចាស់មិនល្អ ហើយប្រកបការងារអ្វីៗ មិនសូវឆ្លាតវៃ និងមិនអាចសម្រេចមគ្គផល ឬឈានសមាបត្តិបានឡើយ ព្រោះអាស្រ័យវិបាកបដិសន្ធិដែលមិនប្រកបដោយបញ្ញា។

- **ន័យទី៤** (តិហេតុកឱមកោមកៈ) នាំឱ្យមានវិបាកដូចគ្នានឹងន័យ ទី ៣ ដែរ គ្រាន់តែក្នុងបវត្តិកាលមិនសូវមានសេចក្តីសុខជាប់តគ្នា គឺថាក្នុងវ័យក្មេងមិនល្អ ពេលពេញវ័យល្អ វ័យកណ្តាលមិនល្អ វ័យចាស់មិនល្អ។



## អានិសង្សរបស់ទុហេតុកកុសល

មើលវីដេអូ ភាគទី ៤៦

- **ន័យទី ១** (ទុហេតុកឧក្កដ្ឋក្កដ្ឋៈ) នាំឱ្យមានវិបាកបដិសន្ធិ ជាមនុស្ស ឬទេវតាជាទុហេតុកបុគ្គល។

**ក្នុងបវត្តិកាល នាំឱ្យមានវិបាកចិត្ត ១២ ដួងគឺ ៖**

មហាវិបាកញាណវិប្បយុត្តចិត្ត ៤ ដួង និង អហេតុកកុសលវិបាកចិត្ត៨ដួង។ ជីវិតរស់នៅក្នុងអត្តភាពនោះៗ ជាអ្នកបរិបូរណ៍ដោយសម្បត្តិ មានសេចក្តីសុខតាំងពីក្មេងដល់ចាស់ ប៉ុន្តែមិនអាចសម្រេចគុណធម៌ជាន់ខ្ពស់ណាមួយបានឡើយ ព្រោះខ្វះឧបនិស្ស័យនៃបញ្ញា។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

- ន័យទី ២ (ទុហេតុកឧក្កដ្ឋោមកៈ) មានសេចក្ដីដូចន័យទី ១ ដែរ គ្រាន់តែមានសេចក្ដីសុខមិនជាប់តគ្នារហូត គឺ ល្អពីក្មេង ដល់ពេលចាស់មិនសូវល្អ។

- ន័យទី ៣ (ទុហេតុកឱមកុក្កដ្ឋៈ) នាំឱ្យមានបដិសន្ធិជាមនុស្ស ឬទេវតាជាន់ទាបៗ ដោយអហេតុកកុសលវិបាក (ដួងទី ៨)។ ក្នុងបវត្តិកាលមានត្រឹមតែអហេតុកកុសលវិបាក ៨ ដួងប៉ុណ្ណោះ ហើយមានសេចក្ដីសុខតិចជាងន័យទី២ និងមិនអាចសម្រេចគុណវិសេសណាមួយបានឡើយ។



- ន័យទី៤ (ទុហេតុកឱមកោមកៈ) មានការឱ្យផលដូចន័យទី ៣ ដែរ គ្រាន់តែសេចក្ដីសុខកាន់តែអន់ទន់ទាបទៅអាចថាជាបុគ្គលមានសតិមិនបរិបូរណ៍ ឆ្កួត ល្ងីល្ងើ គ ថ្លង់ ខ្វាក់ខ្វិន ពិការ តាំងពីកំណើត។

មហាវិបាកទាំង ៨ មិនមែនជាកុសល មិនមែនជាអកុសល មិនមែនជាកម្មបថ មិនមែនជាបុញ្ញកិរិយាវត្ថុ ព្រោះមិនអាចញ៉ាំងវិញ្ញត្តិរូបឱ្យកើតឡើងបាន និង មិនអាចនាំឱ្យមានវិបាកឡើយ ព្រោះជាវិបាកនៃកម្មប៉ុណ្ណោះ។



## កុសលឱ្យផលផ្សេង ៗ គ្នា ៧ យ៉ាងគឺ ៖

| | |
|---|---|
| ១. មានអាយុវែង | ព្រោះមិនសម្លាប់សត្វ។ |
| ២. មិនមានរោគ | ព្រោះមិនបៀតបៀនសត្វ។ |
| ៣. មានសម្បុរស្រស់ថ្លា | ព្រោះមិនមានសេចក្តីក្រោធ។ |
| ៤. មានសក្តិធំ | ព្រោះមិនច្រណែនមិនប្រទូស។ |
| ៥. មានភោគសម្បត្តិច្រើន | ព្រោះឱ្យទាន មានបាយ ទឹក សំពត់ ស្លៀកដណ្តប់ ទីជម្រកជាដើម។ |
| ៦. កើតក្នុងត្រកូលខ្ពង់ខ្ពស់ | ព្រោះមិនរឹងត្អឹង មិនមើលងាយគេ មានតែការគោរពរាប់អាន។ |
| ៧. មានបញ្ញាច្រើន | ព្រោះចូលទៅរកសមណៈជាពហុស្សូត អ្នកស្ងប់រម្ងាប់ស្តាប់និងសិក្សាធម៌។ |

# ការចែកមហាវិបាកចិត្ត ៨ ដួងដោយន័យផ្សេង ៗ

| | |
|---|---|
| ១. ដោយជាតិ | ជាវិបាកជាតិ។ |
| ២. ដោយភូមិ | ជាកាមាវចរភូមិ (កើតនៅសុគតិភូមិ ៧ ជាន់)។ |
| ៣.ដោយវេទនា | ជាសោមនស្សវេទនា ៤ ដួង និង ជាឧបេក្ខាវេទនា ៤ ដួង។ |
| ៤.ដោយហេតុ | ជានហេតុ និង ជាសហេតុកចិត្ត។ |
| ៥.ដោយសម្បយុត្ត | ជាញាណសម្បយុត្ត ៤ ដួង ជាញាណវិប្បយុត្ត ៤ ដួង។ |
| ៦.ដោយសង្ខារ | ជាអសង្ខារិក ៤ ដួង ជាសសង្ខារិក ៤ ដួង។ |



| | |
|---|---|
| ៧. ដោយសោភណៈ | ជាកាមាវចរសោភណចិត្ត។ |
| ៨. ដោយឈាន | ជាអឈានចិត្ត។ |
| ៩. ដោយលោកិយ | ជាលោកិយចិត្ត។ |
| ១០. ដោយកិច្ច | មហាវិបាកចិត្តធ្វើកិច្ច ៤ យ៉ាងគឺ៖ បដិសន្ធិ ភវង្គ ចុតិ និង តទាលម្ពណកិច្ច។ |
| ១១. ដោយអារម្មណ៍ | ជាចិត្តដឹងអារម្មណ៍ទាំង៦។ |
| ១២. ដោយទ្វារ | កើតតាមទ្វារទាំង ៦ (ណាមួយ) និង ជាទ្វារវិមុត្តិ។ |
| ១៣. ដោយវត្ថុ | កើតត្រង់ហទយវត្ថុ។ |
| ១៤. ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ។ |

## មហាវិបាកចិត្ត ៨ ដួងនេះមានឈ្មោះហៅច្រើនយ៉ាង៖

១. កាមាវចរវិបាកចិត្ត ព្រោះកើតតែក្នុងកាមភូមិប៉ុណ្ណោះ។

២. កាមសោភណវិបាក ព្រោះមានសោភណចេតសិកកើតរួមជាមួយ និងជាកាមាវចរសោភណចិត្តផង។

៣. សហេតុកវិបាក ព្រោះប្រកបដោយហេតុ គឺ អលោភៈ អទោសៈ អមោហៈ (បញ្ញា)។

៤. មហាវិបាក ព្រោះវិបាកដែលកើតបានច្រើនអនេកតាមចំនួននៃមហាកុសលចិត្តដែលគុណទុកហើយនោះ។



## កាមាវចរវិបាកចិត្តទាំងអស់មាន ២៣ ដួង គឺ៖

១. អកុសលវិបាកចិត្ត ៧ ដួង

២. អហេតុកកុសលវិបាកចិត្ត ៨ ដួង

៣. មហាវិបាកចិត្ត ៨ ដួង

មើលវីដេអូ ភាគទី ៤៧

# គ. មហាកិរិយាចិត្ត ៨ ដួង

**(Functional Consciousness)**

## ១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនាប្រកប ដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំ។

One consciousness, unprompted, accompanied by pleasure, associated with knowledge.

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## ១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៥ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២
- បញ្ញា ១ (វៀរវិរតិ ៣)



## ២. សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

One consciousness, prompted, accompanied by pleasure, associated with knowledge.

** មានចេតសិកប្រកបជាមួយ ៣៥ ប្រភេទ ដូចដួងទី ១ ដែរ។*



## ៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាក បញ្ញាមានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំ។

One consciousness, unprompted, accompanied by pleasure, dissociated with knowledge.

## ៣. សោមនស្សសហគតំ ញាណវិប្បយុត្ត អសង្ខារិកំ មហាកិរិយាចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២ (វៀរវិរតិ ៣ និង បញ្ញា ១)






## ៤. សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយសោមនស្សវេទនា ប្រាសចាកបញ្ញាមានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

One consciousness, prompted, accompanied by pleasure, associated with knowledge.

** មានចេតសិកប្រកបជាមួយ ៣៤ ប្រភេទ ដូចដួងទី ៣ ដែរ។*

# ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានកម្លាំងខ្លាំងក្លា កើតឡើងដោយឥតមានការបបួលដឹកនាំ។

One consciousness, unprompted, accompanied by indifference, dissociated with knowledge.



## ៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ




មានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២
- បញ្ញា ១ (វៀរវិរតិ ៣)

## ៦. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយា-ចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនាប្រកបដោយបញ្ញា មានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

One consciousness, prompted accompanied by indifference, associated with knowledge.

** មានចេតសិកប្រកបជាមួយ ៣៤ ប្រភេទ ដូចដួងទី ៥ ដែរ។*



## ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញាមានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានការបបួលដឹកនាំ។

One consciousness, unprompted, accompanied by indifference, dissociated with knowledge.

## ៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្ត អសង្ខារិកំ មហាកិរិយាចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ)
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២ (វៀរវិរតិ ៣ និងបញ្ញា ១)






## ៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ

មហាកិរិយាចិត្ត ប្រព្រឹត្តទៅជាមួយឧបេក្ខាវេទនា ប្រាសចាកបញ្ញាមានកម្លាំងខ្សោយ កើតឡើងដោយមានការបបួលដឹកនាំ។

One consciousness, prompted, accompanied by indifference, dissociated with knowledge.

** មានចេតសិកប្រកបជាមួយ ៣៣ ប្រភេទ ដូចដួងទី ៧ ដែរ។*

## មហាកិរិយាចិត្ត ៨ ដួងនេះមានឈ្មោះហៅច្រើនយ៉ាង ៖

១. កាមាវចរកិរិយាចិត្ត ព្រោះបង្អោនទៅដឹងកាមារម្មណ៍ (មានបញ្ចកាមគុណជាអារម្មណ៍)។

២. កាមសោភណកិរិយាចិត្ត ព្រោះមានសោភណចេតសិក កើតរួមជាមួយផង។

៣. សហេតុកកិរិយាចិត្ត ព្រោះប្រកបដោយហេតុ។

៤. មហាកិរិយាចិត្ត ព្រោះច្រើនទៅដោយអារម្មណ៍ និងទ្វារដូចមហាកុសលចិត្តដែរ។



## ការចែកមហាកិរិយាចិត្ត ៨ ដួងដោយន័យផ្សេងៗ

១. ដោយជាតិ ជាកិរិយាជាតិ។

២. ដោយភូមិ ជាកាមភូមិ កើតបាន ២៦ភូមិ(វៀរអបាយភូមិ៤ និង អសញ្ញសត្តាភូមិ)។

៣. ដោយវេទនា ជាសោមនស្សវេទនា ៤ ដួង ជាឧបេក្ខាវេទនា ៤ ដួង។

៤. ដោយហេតុ ជានហេតុ និង ជាសហេតុកចិត្ត។

៥. ដោយសម្បយុត្ត ជាញាណសម្បយុត្ត ៤ ដួង ជាញាណវិប្បយុត្ត ៤ដួង។

៦. ដោយសង្ខារ ជាអសង្ខារិក ៤ ដួង និង ជាសសង្ខារិក ៤ ដួង។

| | |
|---|---|
| ៧. ដោយសោភណៈ | ជាកាមាវចរសោភណចិត្ត។ |
| ៨. ដោយឈាន | ជាអឈានចិត្ត។ |
| ៩. ដោយលោកិយ | ជាលោកិយចិត្ត។ |
| ១០. ដោយកិច្ច | មហាកិរិយាចិត្តធ្វើជវនកិច្ចតែម្យ៉ាង។ |
| ១១. ដោយអារម្មណ៍ | មានអារម្មណ៍ទាំង ៦។ |
| ១២. ដោយទ្វារ | កើតតាមទ្វារទាំង ៦។ |
| ១៣. ដោយវត្ថុ | កើតត្រង់ហទយវត្ថុ<br>មិនអាស្រ័យវត្ថុ ក្នុងអរូបព្រហ្ម៤ |
| ១៤. ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ។ |



## សរុបកាមាវចរចិត្ត ៥៤ ដួង

- អសោភណចិត្ត ៣០
  - អកុសលចិត្ត ១២
    - លោភមូលចិត្ត ៨
    - ទោសមូលចិត្ត ២
    - មោហមូលចិត្ត ២
  - អហេតុកចិត្ត ១៨
    - អកុសលវិបាកចិត្ត ៧
    - អហេតុកកុសលវិបាកចិត្ត ៨
    - អហេតុកកិរិយាចិត្ត ៣
- កាមាវចរសោភណចិត្ត ២៤
  - មហាកុសលចិត្ត ៨
  - មហាវិបាកចិត្ត ៨
  - មហាកិរិយាចិត្ត ៨

មើលវីដេអូ ភាគទី ៤៨

# ២. រូបាវចរឈានចិត្ត ១៥ ដួង

(Form-Sphere Consciousness)

ពាក្យថា **ឈាន** សំដៅដល់សេចក្ដីពីរយ៉ាងគឺ៖

១. សំដៅដល់ការសម្លឹងពិចារណាដុតកម្ដៅសភាវធម៌ដែលជាបដិបក្ខ ដូចជានីវរណធម៌ជាដើមឱ្យអស់ទៅ។

២. សំដៅដល់ចិត្តដែលចុះតាំងណែនក្នុងអារម្មណ៍នៃកម្មដ្ឋាន មានបឋវីកសិណជាដើម ដោយអំណាចនៃអប្បនាសមាធិនោះឯង ទើបហៅថា ឈាន។

ស្កេនដើម្បីមើលមេរៀន
San Sochea Official



ពាក្យថា **រូបជ្ឈាន** មានន័យថា ឈានដែលបានមកអំពីការសម្លឹងនូវបឋវីកសិណជាដើម ដូចនេះហើយទើបហៅថា រូបជ្ឈាន ឬរូបាវចរឈាន។

រូបជ្ឈាន ដែលជាកុសល ហៅថា **រូបាវចរកុសលចិត្ត**។

រូបជ្ឈាន ដែលជាវិបាក ហៅថា **រូបាវចរវិបាកចិត្ត**។

រូបជ្ឈាន ដែលជាកិរិយា ហៅថា **រូបាវចរកិរិយាចិត្ត**។

រូបាវចរចិត្តនោះក្នុងព្រះអភិធម្មបានកំណត់ថាមាន ១៥ ដួង ដែលចែកជាកុសល ៥ ដួង ជាវិបាក ៥ ដួង ជាកិរិយា ៥ ដួង រួមទាំងអស់ ១៥ដួង ដែលនឹងសម្ដែងដូចតទៅនេះ ៖

# ក. រូបាវចរកុសលចិត្ត ៥ ដួង

**(Form-Sphere Moral Consciousness)**

## ១. វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ

បឋមជ្ឈានកុសលចិត្ត ប្រកបព្រមដោយ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

First Jhāna moral consciousness together with initial application, sustained application, joy, happiness, and one-pointedness.



## ១. វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៥ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២
- បញ្ញា ១ (វៀរវិរតិ ៣)



* សួរថា បើចេតសិកកើតរួមក្នុងចិត្តនោះដល់ទៅ ៣៥ ប្រភេទឯណោះ ហេតុដូចម្ដេចទើបព្រះអង្គសម្ដែងតែធម៌ ៥ នេះ ថាជាអង្គឈាន?



* ឆ្លើយថា ព្រោះធម៌ ៥ នេះ មានកិច្ច (គឺតួនាទី) សម្លឹងពិចារណាអារម្មណ៍ និង បដិបក្ខដោយត្រង់ចំពោះ កាមឆន្ទនីវរណៈ ជាដើម គឺ ៖

| | | |
|---|---|---|
| ១. ឯកគ្គតា | ជាបដិបក្ខនឹង | កាមឆន្ទៈ |
| ២. បីតិ | ជាបដិបក្ខនឹង | ព្យាបាទៈ |
| ៣. វិតក្កៈ | ជាបដិបក្ខនឹង | ថីនៈ មិទ្ធៈ |
| ៤. សុខៈ | ជាបដិបក្ខនឹង | ឧទ្ធច្ចកុក្កុច្ចៈ |
| ៥. វិចារៈ | ជាបដិបក្ខនឹង | វិចិកិច្ឆា។ |

មើលវីដេអូ ភាគទី ៤៩

# ២. វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ

ទុតិយជ្ឈានកុសលចិត្ត ប្រកបព្រមដោយ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

Second Jhāna moral consciousness together with sustained application, joy, happiness, and one-pointedness.

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## ២. វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៤ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១២ (វៀរ វិតក្កៈ)
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២
- បញ្ញា ១ (វៀរវិរតិ ៣)



# ៣. បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកុសលចិត្តំ

តតិយជ្ឈានកុសលចិត្ត ប្រកបព្រមដោយ បីតិ សុខៈ ឯកគ្គតា ។

Third Jhāna moral consciousness together with joy,

happiness, and one-pointedness.



## ៣. បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣៣ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១១ (វៀរ វិតក្កៈ វិចារៈ)
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២
- បញ្ញា ១ (វៀរវិរតិ ៣)



# ៤. សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសលចិត្តំ

ចតុត្ថជ្ឈានកុសលចិត្ត ប្រកបព្រមដោយ សុខៈ ឯកគ្គតា។

Fourth Jhāna moral consciousness together with happiness

and one-pointedness.



## ៤. សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣២ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)
- សោភណសាធារណចេតសិក ១៩
- អប្បមញ្ញា ២
- បញ្ញា ១ (វៀរវិរតិ ៣)



# ៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តំ

បញ្ចមជ្ឈានកុសលចិត្ត ប្រកបព្រមដោយ ឧបេក្ខា និង ឯកគ្គតា។

Fifth Jhāna moral consciousness together with

equanimity and one-pointedness.



## ៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តំ

មានចេតសិកកើតរួមជាមួយ ៣០ ប្រភេទគឺ ៖

- អញ្ញសមានាចេតសិក ១០ (វៀរ វិតក្កៈ វិចារៈ បីតិ)
- សោភណសាធារណចេតសិក ១៩
- បញ្ញា ១ (វៀរវិរតិ ៣ អប្បមញ្ញា ២)



## ➢ បឋមជ្ឈានកុសលចិត្តកាលកើតឡើងនឹងមានវិថីចិត្ត យ៉ាងនេះគឺ ៖

១. ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត។
២. ភវង្គចលនៈ ជាមហាវិបាកញាណសម្បយុត្ត។
៣. ភវង្គុបច្ឆេទៈ ជាមហាវិបាកញាណសម្បយុត្ត។
៤. មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយាចិត្ត។
៥. បរិកម្ម ជាមហាកុសលញាណសម្បយុត្ត។



៦. ឧបចារៈ ជាមហាកុសលញាណសម្បយុត្ត។
៧. អនុលោម ជាមហាកុសលញាណសម្បយុត្ត។
៨. គោត្រភូ ជាមហាកុសលញាណសម្បយុត្ត។
៩. បឋមជ្ឈានកុសលចិត្ត ជារូបាវចរកុសលចិត្ត។
១០. ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត។

## បឋមជ្ឈានកុសលចិត្តកាលកើតឡើងនឹងមានវិថីចិត្តយ៉ាងនេះគឺ ៖






## ➢ ទុតិយជ្ឈានកុសលចិត្ត នឹងប្រាកដឡើងយ៉ាងនេះ

កាលព្រះយោគាវចរ ដែលមានធម៌ហ្វឹកហាត់ព្យាយាមចូល បឋមជ្ឈានរហូតស្ទាត់ជំនាញល្អ ដល់ព្រមដោយវសីទាំង ៥ គឺៈ

**១. អាវជ្ជនវសី** ជំនាញក្នុងការនឹករក គឺថាព្រះយោគាវចរចូលឈាន និងចេញចាកឈានរហូតស្ទាត់ជំនាញ ហើយហ្វឹកហាត់ដោយពិចារណាថា នឹករកអ្វីហ្ន៎ ទើបឈានអាចកើតឡើងបានឆាប់រហ័សហ្វឹកហាត់ដោយវិធីយ៉ាងនេះរឿយៗ រហូតទាល់តែស្ទាត់ជំនាញ។

២. សមាបជ្ជនវសី ជំនាញក្នុងការចូលកាន់ឈាន គឺឱ្យឈានចិត្ត កើតបានក្នុងស្ថានទី និង ខណៈតាមដែលខ្លួនប្រាថ្នា។

៣. អធិដ្ឋានវសី ជំនាញក្នុងការឱ្យឈានតាំងនៅមាំ គឺជំនាញ ក្នុងការឱ្យឈានកើតរលត់បន្តគ្នាមិនឱ្យមានភវង្គ គឺថាឱ្យ ឈានតាំងនៅមាំយូរ ៗ ឬ ឆាប់ តិច ឬ ច្រើន ក្នុងស្ថានទី និង ខណៈតាមដែលខ្លួនប្រាថ្នា។

៤. វុដ្ឋានវសី ជំនាញក្នុងការចេញចាកឈាន គឺថាបើចង់ចេញ ចាកឈានក្នុងវេលាណា ក៏ចេញបានក្នុងវេលានោះ មិនយឺត យូរឡើយ។



៥. បច្ចវេក្ខណវសី ជំនាញក្នុងការពិចារណាអង្គឈាន គឺកាលបើ ចេញចាកអំពីឈានហើយ ពិចារណាដើម្បីលះនូវអង្គឈាន ដែលគ្រោតគ្រាតចេញ ដើម្បីឱ្យអប្បនាសមាធិតាំងនៅមាំ ក្រៃលែងឡើង។ រមែងពិចារណាឃើញថា វិតក្កៈនេះជាអង្គ ឈានដែលគ្រោតគ្រាតជាងវិចារៈព្រោះកៀកកិត នឹងកាមា-រម្មណ៍ ។ ដូច្នេះកាលនឹងឡើងកាន់ទុតិយជ្ឈាន ទើបលោក សម្លឹងបដិភាគនិមិត្ត ដើម្បីឱ្យចិត្តជាអប្បនាសមាធិដោយមិន មានវិតក្កៈតទៅ ក៏ព្យាយាមឧស្សាហ៍រហូតដល់ឈានចិត្ត ដែលមិនមានវិតក្កៈកើតឡើង ប៉ុន្តែគង់នៅមាន វិចារៈ បីតិ សុខៈ និង ឯកគ្គតា។

## ទុតិយជ្ឈានកុសលចិត្តកាលកើតឡើងនឹងមានវិថីចិត្តយ៉ាងនេះគឺ ៖






## ➢ តតិយជ្ឈានកុសលចិត្ត នឹងប្រាកដឡើងយ៉ាងនេះ

កាលដែលព្រះយោគាវចរ ជំនាញក្នុងទុតិយជ្ឈានបានល្អប្រកប ដោយវសី ៥ ហើយ ក៏សម្លឹងនូវបដិភាគនិមិត្តឡើងកាន់ឈានទី ៣ ដោយពិចារណាឃើញវិចារៈ ជាអង្គឈានគ្រោតគ្រាតកៀក កិតនឹងវិតក្កៈ ដែលធ្វើឱ្យវិនាសឈានដោយងាយ ។ កាល ឃើញទោសនៃវិចារៈហើយ ក៏ចូលឈាន សម្លឹងបដិភាគនិមិត្ត ដើម្បីឱ្យអប្បនាសមាធិកើតឡើងដោយមិនមានវិចារៈរហូតដល់ តតិយជ្ឈានកើតមានទំនងដូចឈានមុនៗ ដែរ។

**តតិយជ្ឈានកុសលចិត្តកាលកើតឡើងនឹងមានវិថីចិត្តយ៉ាងនេះគឺ ៖**




កាលតតិយជ្ឈានចិត្តកើតឡើង ក៏ត្រូវមានវិថីដូចគ្នានឹងបឋមជ្ឈានចិត្តដែរ។



## ➢ ចតុត្ថជ្ឈានកុសលចិត្ត នឹងប្រារព្ធឡើងយ៉ាងនេះ

កាលដែលយោគាវចរ ជំនាញក្នុងតតិយជ្ឈានបានល្អប្រកបដោយវសី ៥ ហើយក៏សម្លឹងបដិភាគនិមិត្តឡើងកាន់ឈានទី ៤ ដោយពិចារណាឃើញបីតិជាអង្គឈានគ្រោតគ្រាត។ ដើម្បីឱ្យចិត្តប្រណិតក្រៃលែងឡើង ទើបសម្លឹងបដិភាគនិមិត្តដើម្បីចម្រើនអប្បនាសមាធិរហូតដល់មិនមានបីតិកើតរួមជាមួយ។ វិថីចិត្តដែលមុនចតុត្ថជ្ឈានកើតឡើងមានទំនងដូចឈានមុនៗ ដែរ។

## ចតុត្ថជ្ឈានកុសលចិត្តកាលកើតឡើងនឹងមានវិថីចិត្តយ៉ាងនេះគឺ ៖




កាលចតុត្ថជ្ឈានចិត្តកើតឡើង ក៏ត្រូវមានវិថីដូចគ្នានឹងបឋមជ្ឈានចិត្តដែរ។



## ➢ បញ្ចមជ្ឈានកុសលចិត្ត នឹងប្រាកដឡើងយ៉ាងនេះ

កាលព្រះយោគាវចរ ជំនាញក្នុងចតុត្ថជ្ឈានបានល្អព្រមដោយវសី ៥ ហើយ ក៏ពិចារណាឃើញទោសរបស់សុខថា មានសភាពគ្រោតគ្រាតជាងឧបេក្ខា ព្រោះសុខនោះញាប់ញ័រ មិនតាំងមាំដូចឧបេក្ខាវេទនាទេ ទើបសម្លឹងបដិភាគនិមិត្តចម្រើនអប្បនាសមាធិដើម្បីលះសុខ រហូតដល់បញ្ចមជ្ឈានកើតឡើងប្រកបដោយអង្គ ២ គឺ ឧបេក្ខា និង ឯកគ្គតា។

## បញ្ចមជ្ឈានកុសលចិត្តកាលកើតឡើងនឹងមានវិថីចិត្តយ៉ាងនេះគឺ ៖




កាលបញ្ចមជ្ឈានចិត្តកើតឡើង ក៏ត្រូវមានវិថីដូចគ្នានឹងបឋមជ្ឈានចិត្តដែរ។



* មហាកុសលញាណសម្បយុត្តដែលធ្វើបរិកម្ម ឧបចារៈ អនុលោម និង គោត្រភូ ដែលកើតមុនបញ្ចមជ្ឈាននោះកើតព្រម នឹងឧបេក្ខាវេទនា ព្រោះឈានទី៥នេះ មានឧបេក្ខា និង ឯកគ្គតា ជាអង្គឈាន។ ចំណែកឈាន៤ខាងដើម មហាកុសលនោះ កើតព្រមនឹងសោមនស្សវេទនា។ ម្យ៉ាងទៀតមហាកុសល ញាណសម្បយុត្តចិត្ត ដែលកើតក្នុងរវាងការចម្រើនសមថភាវនា នោះ ពេលខ្លះក៏កើតនឹងសោមនស្សវេទនា ពេលខ្លះក៏កើតព្រម នឹងឧបេក្ខាវេទនា។

# ប្រៀបធៀបបីតិ និង សុខ

បីតិ ប្រៀបដូចបុគ្គលនឿយហត់ព្រោះដំណើរផ្លូវឆ្ងាយ បានឃើញ ឬបាន ឮសំឡេងទឹកហូរក្នុងព្រៃអំពីចម្ងាយ ក៏ត្រេកអរសប្បាយចិត្ត ដោយគិតថា អញនឹងបានងូត ឬផឹកនូវទឹកនោះ រីឯសុខៈ ប្រៀបដូច ពេលបុគ្គលនោះ បានផឹក ឬងូតនូវទឹកយ៉ាងសប្បាយ។



ព្រោះតែបីតិនិងសុខៈ មានភាពស្រដៀងគ្នា គប្បីកំណត់ដឹងនូវសេចក្ដី ផ្សេងគ្នាយ៉ាងនេះ គឺ ៖

| | |
|---|---|
| បីតិ | អង្គធម៌គឺ បីតិចេតសិក |
| សុខៈ | អង្គធម៌គឺ វេទនាចេតសិក (សោមនស្សវេទនា) |
| បីតិ | បានដល់ សេចក្ដីត្រេកអរក្នុងឥដ្ឋារម្មណ៍ |
| សុខៈ | បានដល់ ការបានសោយនូវរសនៃឥដ្ឋារម្មណ៍ |
| បីតិ | មានក្នុងទីណា សុខៈតែងតែមាននៅក្នុងទីនោះ |
| សុខៈ | មានក្នុងទីណា បីតិមិនប្រាកដថាត្រូវតែមានក្នុងទីនោះទេ |
| បីតិ | សង្គ្រោះចូលក្នុងសង្ខារក្ខន្ធ |
| សុខៈ | សង្គ្រោះចូលក្នុងវេទនាខន្ធ |

## សមាធិ ៣ យ៉ាង

១. ខណិកសមាធិ  បានដល់ ចិត្តតាំងមាំនៅក្នុងអារម្មណ៍ បានរយៈពេលខ្លី

២. ឧបចារសមាធិ  បានដល់ ចិត្តតាំងមាំនៅក្នុងអារម្មណ៍ជិតឈានចិត្ត

៣. អប្បនាសមាធិ  បានដល់ ចិត្តតាំងមាំស៊ប់ក្នុងអារម្មណ៍ដែលបានកំណត់ទុក កិលេសមិនអាចរំខានបាន។
ឈានចិត្ត រាប់ចូលក្នុងអប្បនាសមាធិ។



## ការចែករូបាវចរកុសលចិត្ត ៥ ដួងដោយន័យផ្សេងៗ

១. ដោយជាតិ  ជាកុសលជាតិ។

២. ដោយភូមិ  ជារូបាវចរភូមិ កើតបាន ២២ ភូមិ
(វៀរអបាយភូមិ ៤ អសញ្ញសត្តាភូមិ ១ អរូបភូមិ ៤)។

៣. ដោយវេទនា  ជាសោមនស្សវេទនា ៤ដួង
(បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន)
ជាឧបេក្ខាវេទនា ១ (បញ្ចមជ្ឈាន)។

៤. ដោយហេតុ  ជានហេតុ និង ជាតិហេតុកចិត្ត។

៥. ដោយសម្បយុត្ត  ជាញាណសម្បយុត្ត។

៦. ដោយសង្ខារ ជាសសង្ខារិក។
៧. ដោយសោភណៈ ជារូបាវចរសោភណចិត្ត។
៨. ដោយឈាន ជារូបាវចរឈាន។
៩. ដោយលោកិយ ជាលោកិយចិត្ត។
១០. ដោយកិច្ច ធ្វើជវនកិច្ច។
១១. ដោយអារម្មណ៍ មានធម្មារម្មណ៍ជាអារម្មណ៍។
១២. ដោយទ្វារ ដឹងអារម្មណ៍តាមមនោទ្វារ។
១៣. ដោយវត្ថុ អាស្រ័យហទយវត្ថុ។
១៤. ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ។



មើលវីដេអូ ភាគទី ៥០

## ខ. រូបាវចរវិបាកចិត្ត ៥ ដួង

**(Form-Sphere Resultant Consciousness)**

### ១. វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានវិបាកចិត្តំ

បឋមជ្ឈានវិបាកចិត្ត ប្រកបព្រមដោយ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា។

First Jhāna Resultant consciousness together with initial application, sustained application, joy, happiness, and one-pointedness.

ស្កេនដើម្បីមើលមេរៀន
San Sochea Official

## ២. វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាកចិត្តំ

ទុតិយជ្ឈានវិបាកចិត្ត ប្រកបព្រមដោយ វិចារៈ បីតិ សុខៈ ឯកគ្គតា។

Second Jhāna Resultant consciousness together with sustained application, joy, happiness, and one-pointedness.



## ៣. បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានវិបាកចិត្តំ

តតិយជ្ឈានវិបាកចិត្ត ប្រកបព្រមដោយ បីតិ សុខៈ ឯកគ្គតា។

Third Jhāna Resultant consciousness together with joy, happiness, and one-pointedness.

## ៤. សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ

ចតុត្ថជ្ឈានវិបាកចិត្ត ប្រកបព្រមដោយ សុខៈ ឯកគ្គតា។

Fourth Jhāna Resultant consciousness together with happiness and one-pointedness.



## ៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តំ

បញ្ចមជ្ឈានវិបាកចិត្ត ប្រកបព្រមដោយ ឧបេក្ខា និង ឯកគ្គតា ។

Fifth Jhāna Resultant consciousness together with equanimity and one-pointedness.

បាលី និង ពាក្យប្រែ នៃរូបាវចរវិបាកចិត្តទាំង ៥ ដូងនេះ មាន
សភាពដូចគ្នានឹងរូបាវចរកុសលចិត្តទាំងអស់ គ្រាន់តែប្ដូរពី
ពាក្យ «កុសលចិត្តំ» មកជា «វិបាកចិត្តំ» ប៉ុណ្ណោះ។

ម្យ៉ាងទៀត ចេតសិកកើតរួមជាមួយក៏ដូចគ្នានឹងរូបាវចរ
កុសលចិត្តទាំងអស់ដែរ។



## អធិប្បាយ

កាមាវចរវិបាកតែងដូចគ្នាខ្លះ មិនដូចគ្នាខ្លះ នឹងកុសលចិត្តនៃខ្លួន ។ ដូច្នេះហើយទើបវិបាកនៃកាមាវចរកុសលចិត្តនោះ លោកមិនបានចែកវិបាកឱ្យស្របគ្នា នឹងកុសលរបស់ខ្លួនឡើយ។

ចំណែករូបាវចរវិបាកចិត្តនេះ តែងស្របគ្នានឹងកុសលរបស់ខ្លួន ប្រៀបដូចជាស្រមោលទាំងឡាយមានស្រមោល ដំរី សេះ និង ដើមឈើជាដើម ព្រោះហេតុនោះទើបលោកចែករូបាវចរវិបាកនេះឱ្យស្របតាមកុសលរបស់ខ្លួន។

ម្យ៉ាងទៀតកាមាវចរកុសលតែងឱ្យវិបាកក្នុងកាលខ្លះក៏បាន គ្រាសម័យខ្លះក៏បាន ។ ចំណែករូបាវចរកុសល តែងឱ្យវិបាកក្នុងភពទី ២ តែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនេះហើយទើបលោកចែកឱ្យស្របគ្នានឹងកុសលរបស់ខ្លួនគឺ៖

| | |
|---|---|
| ១ - បឋមជ្ឈានកុសលចិត្ត | ឱ្យផលជាបឋមជ្ឈានវិបាកចិត្ត បដិសន្ធិក្នុងបឋមជ្ឈានភូមិ។ |
| ២ - ទុតិយជ្ឈានកុសលចិត្ត | ឱ្យផលជាទុតិយជ្ឈានវិបាកចិត្ត បដិសន្ធិក្នុងទុតិយជ្ឈានភូមិ។ |
| ៣ - តតិយជ្ឈានកុសលចិត្ត | ឱ្យផលជាតតិយជ្ឈានវិបាកចិត្ត បដិសន្ធិនៅទុតិយជ្ឈានភូមិ។ |
| ៤ - ចតុត្ថជ្ឈានកុសលចិត្ត | ឱ្យផលជាចតុត្ថជ្ឈានវិបាកចិត្ត បដិសន្ធិនៅតតិយជ្ឈានភូមិ។ |
| ៥ - បញ្ចមជ្ឈានកុសលចិត្ត | ឱ្យផលជាបញ្ចមជ្ឈានវិបាកចិត្ត បដិសន្ធិនៅចតុត្ថជ្ឈានភូមិ។ |



* បុគ្គលដែលបដិសន្ធិ ក្នុងរូបាវចរភូមិ គឺបដិសន្ធិដោយរូបាវចរវិបាកចិត្ត ជារូបព្រហ្ម ។ រូបព្រហ្មបុគ្គលនោះតែងមានចក្ខុបសាទ និង សោតបសាទល្អតែមិនមានឃានបសាទ ជិវ្ហាបសាទ និង កាយបសាទទេ ។ គប្បីជ្រាបថា ការកើតឡើងនៃចក្ខុវិញ្ញាណ និង សោតវិញ្ញាណរបស់ព្រហ្មនោះ មិនមែនជាវិបាកនៃរូបាវចរកុសល ៥ ដួងទេ គឺជាវិបាករបស់មហាកុសលចិត្ត និង អកុសលចិត្តប៉ុណ្ណោះ។

រូបាវចរវិបាកចិត្ត ៥ដួងនេះ ធ្វើកិច្ចបដិសន្ធិនៅក្នុងរូបព្រហ្មទាំង១៥ (វៀរអសញ្ញសត្តាភូមិ) គឺ៖

១ - បារិសជ្ជាភូមិ

២ - បុរោហិតាភូមិ

៣ - មហាព្រហ្មាភូមិ

} បដិសន្ធិដោយបឋមជ្ឈានវិបាក ។

៤ - បរិត្តាភាភូមិ

៥ - អប្បមាណាភាភូមិ

៦ - អភស្សរាភូមិ

} បដិសន្ធិដោយទុតិយជ្ឈានវិបាក (ចតុក្កន័យ) ឬដោយទុតិយជ្ឈានវិបាក និងតតិយជ្ឈានវិបាក(បញ្ចកន័យ)។



៧ - បរិត្តសុភាភូមិ

៨ - អប្បមាណសុភាភូមិ

៩ - សុភកិណ្ហាភូមិ

} បដិសន្ធិដោយតតិយជ្ឈានវិបាក (ចតុក្កន័យ) ឬដោយចតុត្ថជ្ឈានវិបាក (បញ្ចកន័យ)។

១០ - វេហប្ផលាភូមិ → បដិសន្ធិដោយចតុត្ថជ្ឈានវិបាក (ចតុក្កន័យ)ឬដោយបញ្ចមជ្ឈានវិបាក (បញ្ចកន័យ)។

១១ - អវិហាភូមិ
១២ - អតប្បាភូមិ
១៣ - សុទស្សាភូមិ
១៤ - សុទស្សីភូមិ
១៥ - អកនិដ្ឋាភូមិ

ទាំង ៥ ភូមិនេះជាព្រហ្មសុទ្ធាវាស នៃព្រះអនាគាមី បដិសន្ធិដោយ ចតុត្ថជ្ឈានវិបាក(ចតុក្កន័យ) ឬ បញ្ចមជ្ឈានវិបាក(បញ្ចកន័យ)។

ចំពោះ អសញ្ញីសត្តាព្រហ្ម ខណៈបដិសន្ធិ មានត្រឹមតែរូបក្ខន្ធ ប៉ុណ្ណោះ មិនមាន វិបាកនាមខន្ធទេ ទើបមិនរាប់ចូលក្នុងទីនេះ។



## បញ្ចកន័យ

បឋមជ្ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា

ទុតិយជ្ឈានមានអង្គ ៤ គឺ វិចារៈ បីតិ សុខៈ ឯកគ្គតា

តតិយជ្ឈានមានអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា

ចតុត្ថជ្ឈានមានអង្គ ២ គឺ សុខៈ ឯកគ្គតា

បញ្ចមជ្ឈានមានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា

## ចតុក្កន័យ

បឋមជ្ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា

ទុតិយជ្ឈានមានអង្គ ៣ គឺ បីតិ សុខៈ ឯកគ្គតា

តតិយជ្ឈានមានអង្គ ២ គឺ សុខៈ ឯកគ្គតា

ចតុត្ថជ្ឈានមានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា

# ការចែករូបាវចរវិបាកចិត្ត ៥ ដួងដោយន័យផ្សេងៗ

| | |
|---|---|
| ១ - ដោយជាតិ | ជាវិបាកជាតិ |
| ២ - ដោយភូមិ | ជារូបភូមិ |
| ៣ - ដោយវេទនា | ៤ ដួងខាងដើម (បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន) ជាសោមនស្សវេទនា ១ ដួងខាងចុង (បញ្ចមជ្ឈាន) ជាឧបេក្ខាវេទនា |
| ៤ - ដោយហេតុ | ជានហេតុ និង តិហេតុកចិត្ត |
| ៥ - ដោយសម្បយុត្ត | ជាញាណសម្បយុត្ត |
| ៦ - ដោយសង្ខារ | ជាសសង្ខារិកចិត្ត |



| | |
|---|---|
| ៧ - ដោយសោភណៈ | ជារូបាវចរសោភណចិត្ត។ |
| ៨ - ដោយឈាន | ជាផលនៃកុសលឈាន។ |
| ៩ - ដោយលោកិយ | ជាលោកិយចិត្ត។ |
| ១០ - ដោយកិច្ច | មានកិច្ច ៣ គឺ បដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ |
| ១១ - ដោយអារម្មណ៍ | រូបាវចរកុសលឈានមានអារម្មណ៍ណាជាកម្មដ្ឋាន រូបាវចរវិបាកចិត្តក៏មានអារម្មណ៍នោះដែរ |
| ១២ - ដោយទ្វារ | ជាទ្វារវិមុត្តិចិត្ត។ |
| ១៣ - ដោយវត្ថុ | អាស្រ័យហទយវត្ថុ។ |
| ១៤ - ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ។ |

មើលវីដេអូ ភាគទី ៥១

# គ. រូបាវចរកិរិយាចិត្ត ៥ ដួង

(Form-Sphere Functional Consciousness)

## ១. វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកិរិយាចិត្តំ

បឋមជ្ឈានកិរិយាចិត្ត ប្រកបព្រមដោយ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

First Jhāna Functional consciousness together with initial application, sustained application, joy, happiness and one-pointedness.

ស្កេនដើម្បីមើលមេរៀន

San Sochea Official

442

## ២. វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកិរិយាចិត្តំ

ទុតិយជ្ឈានកិរិយាចិត្ត ប្រកបព្រមដោយ វិចារៈ បីតិ សុខៈ ឯកគ្គតា ។

Second Jhāna Functional consciousness together with sustained application, joy, happiness, and one-pointedness.

## ៣. បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកិរិយាចិត្តំ

តតិយជ្ឈានកិរិយាចិត្ត ប្រកបព្រមដោយ បីតិ សុខៈ ឯកគ្គតា។

Third Jhāna Functional consciousness together with joy, happiness, and one-pointedness.



## ៤. សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកិរិយាចិត្តំ

ចតុត្ថជ្ឈានកិរិយាចិត្ត ប្រកបព្រមដោយ សុខៈ ឯកគ្គតា។

Fourth Jhāna Functional consciousness together with happiness and one-pointedness.

## ៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយាចិត្តំ

បញ្ចមជ្ឈានកិរិយាចិត្ត ប្រកបព្រមដោយ ឧបេក្ខា និង ឯកគ្គតា។

Fifth Jhāna Functional consciousness together with equanimity and one-pointedness.



បាលី និង ពាក្យប្រែ នៃរូបាវចរកិរិយាចិត្តទាំង ៥ ដូងនេះ មានសភាពដូចគ្នានឹងរូបាវចរកុសលចិត្តទាំងអស់ គ្រាន់តែប្តូរពីពាក្យ «កុសលចិត្តំ» មកជា «កិរិយាចិត្តំ» ប៉ុណ្ណោះ។

ម្យ៉ាងទៀត ចេតសិកកើតរួមជាមួយក៏ដូចគ្នានឹងរូបាវចរកុសលចិត្តទាំងអស់ដែរ។

* រូបាវចរកិរិយាចិត្ត ជាចិត្តរបស់ព្រះខីណាស្រព ជាកិរិយា មិនមែនជាកុសល មិនមែនជាអកុសល មិនមែនជាវិបាក ជាទិដ្ឋធម្មសុខវិហារ (នៅជាសុខក្នុងបច្ចុប្បន្ន) គឺដើម្បីនៅជាសុខក្នុងបច្ចុប្បន្ននេះតែប៉ុណ្ណោះ។



## ការចែករូបាវចរកិរិយាចិត្ត ៥ ដួងដោយន័យផ្សេងៗ

| | |
|---|---|
| ១ - ដោយជាតិ | ជាកិរិយាជាតិ។ |
| ២ - ដោយភូមិ | ជារូបភូមិ។ |
| ៣ - ដោយវេទនា | ជាសោមនស្សវេទនា ៤ ដួង<br>ជាឧបេក្ខាវេទនា ១ ដួង។ |
| ៤ - ដោយហេតុ | ជានហេតុ និង ជាតិហេតុកចិត្ត។ |
| ៥ - ដោយសម្បយុត្ត | ជាញាណសម្បយុត្ត។ |
| ៦ - ដោយសង្ខារ | ជាសសង្ខារិកចិត្ត។ |

| | |
|---|---|
| ៧ - ដោយសោភណ | ជារូបាវចរសោភណចិត្ត។ |
| ៨ - ដោយឈាន | ជារូបាវចរកិរិយាឈានចិត្ត។ |
| ៩ - ដោយលោកិយ | ជាលោកិយចិត្ត។ |
| ១០ - ដោយកិច្ច | ធ្វើជវនកិច្ចតែម្យ៉ាង។ |
| ១១ - ដោយអារម្មណ៍ | មានធម្មារម្មណ៍ជាអារម្មណ៍។ |
| ១២ - ដោយទ្វារ | ជាមនោទ្វារ។ |
| ១៣ - ដោយវត្ថុ | អាស្រ័យហទយវត្ថុ។ |
| ១៤ - ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ។ |



## ៣. អរូបាវចរចិត្ត ១២ ដួង

(Formless-sphere Consciousness)

### ក. អរូបាវចរកុសលចិត្ត ៤ ដួង

(Formless-Sphere Moral Consciousness)

- អាកាសានញ្ចាយតនកុសលចិត្តំ
- វិញ្ញាណញ្ចាយតនកុសលចិត្តំ
- អាកិញ្ចញ្ញាយតនកុសលចិត្តំ
- នេវសញ្ញានាសញ្ញាយតនកុសលចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរ កុសលចិត្តានិ នាម ។

- អាកាសានញ្ចាយតនកុសលចិត្ត ១

Moral Jhāna consciousness dwelling on the "Infinity of Space".

- វិញ្ញាណញ្ចាយតនកុសលចិត្ត ១

Moral Jhāna consciousness dwelling on the "Infinity of Consciousness".

- អាកិញ្ចញ្ញាយតនកុសលចិត្ត ១

Moral Jhāna consciousness dwelling on "Nothingness".

- នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១

Moral Jhāna consciousness wherein "Perception neither is nor is not".

ចិត្ត ៤ ដួងនេះ ឈ្មោះថា អរូបាវចរកុសលចិត្ត ។



# អធិប្បាយអាកាសានញ្ចាយតនៈ

អាកាសានញ្ចាយតនៈ មកពី អាកាសានំ + ច + អាយតនៈ

មានន័យថា ជាអាយតនៈ (ជាទីកើត) ដែលអាកាសមិនមានទីបំផុត គឺថា អាកាសានញ្ច នោះឯង ជាអាយតនៈ (គឺជាទីកើត) នៃឈាននោះ ព្រមដោយសម្បយុត្តធម៌ដោយអត្ថថា ជាទីតាំងនៅដូច ទេវាយតនៈ ទីអាស្រ័យនៅនៃពួកទេវតា។

ឈាន ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះអត្ថថា មានអាកាសមិនមានទីបំផុត ជាទីកើតកុសលចិត្ត ដែលសម្បយុត្តជាមួយ អាកាសានញ្ចាយតនៈនោះ ឈ្មោះថា អាកាសានញ្ចាយតនកុសលចិត្ត។

## អាកាសមាន ៤ ប្រការ គឺ ៖

| | |
|---|---|
| ១ - អជដាកាស | បានដល់ អាកាស (មេឃ) |
| ២ - បរិច្ឆិន្នាកាស | បានដល់ អាកាសកសិណ |
| ៣ - កសិណុគ្ឃាដិមាកាស | បានដល់អាកាស ដែលអាស្រ័យមកពីកសិណ ៩ (វៀរអាកាសកសិណ)។ |
| ៤ - បរិច្ឆេទាកាស | បានដល់អាកាសរូប។ |

អាកាសានញ្ចាយតនៈ បានដល់ កសិណុគ្ឃាដិមាកាស ប៉ុណ្ណោះ មិនបានសំដៅដល់អាកាសកសិណទេ។



## វិធីចម្រើនអាកាសានញ្ចាយតនជ្ឈាន (ទី១)

ព្រះយោគីបុគ្គលដែលនឹងចម្រើនអរូបកម្មដ្ឋានឱ្យកន្លងនូវរូបជ្ឈាន នោះ ដំបូងត្រូវបានរូបាវចរបញ្ចមជ្ឈាន ព្រមទាំងមានការជំនាញក្នុង វសី ៥ សិន ក៏ឃើញទោសរបស់រូបជ្ឈាន ដោយប្រការផ្សេងៗ។ ម្យ៉ាងទៀត លោកឃើញទោសនៃរូបរាងកាយ ដែលមានទុក្ខទោស ច្រើន ព្រមទាំងឃើញថា បើមិនមានរូបរាងកាយ ទុក្ខទោសទាំង ឡាយ មានព្យាធិជាដើមក៏លែងមាន ដូច្នេះលោកក៏ចម្រើនឈាន ដែលមិនមានរូប ហៅថា «អរូបជ្ឈាន» មានរបៀបយ៉ាងនេះគឺ ៖

កាលណាព្រះយោគីបុគ្គលឃើញទោសនៃរូបនិង វិធីដែលនឹងរួចចាកពីរូបយ៉ាងនេះហើយក៏ចូលរូបជ្ឈានទី ៥ ធ្វើឱ្យកើតឡើងសិន។

កាលចេញពីឈានពិចារណាឃើញទោសនៃរូបជ្ឈានកម្មដ្ឋាន ដែលជាអារម្មណ៍ហើយ ក៏ចូលឈាននោះ ផ្សាយពង្រីកនិមិត្ត (រូបកម្មដ្ឋាន)នោះឱ្យមិនមានទីបំផុត គឺ ផ្សាយចេញទៅបានដល់ ១ ចក្រវាឡ។ ដោយការផ្សាយពង្រីកទៅៗ នូវរូបនិមិត្តនៃរូបកម្មដ្ឋាន ដែលជាអារម្មណ៍ច្រើនប៉ុណ្ណាក៏មិនមានទីបំផុត អាកាសដែលល្ហល្ហេវនោះ មិនមានការកើត មិនមានការវិនាសរកទីបំផុតមិនបាន។ ការឃើញសេចក្តីមិនមានទីបំផុតនៃអាកាសក៏បើកសញ្ញា គឺមិនដាក់ចិត្តទៅក្នុងរូបនិមិត្តដែលជាអារម្មណ៍នោះ យកចិត្តទុកដាក់តែសភាពនៃអាកាសមិនមានទីបំផុត (អាកាសោ អនន្តោ)។



ក្នុងខណៈដែលចិត្តគិតដល់អាកាសមិនមានទីបំផុតនេះ ពេលនោះនូវមានរូបនិមិត្តដែលពង្រីកផ្សាយទៅដែរ ទាំងឧបចារសមាធិ ក៏កើតឡើងជាលំដាប់។ កាលដាក់ចិត្តដល់អាកាសមិនមានទីបំផុតរឿយៗទៅ ទីបំផុតអប្បនាសមាធិ ក៏កើតឡើង ដោយមានអាកាសដែលមិនមានទីបំផុតនោះជាអារម្មណ៍។ អាកាសដែលមិនមានទីបំផុតនេះ ជាទីតាំងឱ្យកើតបឋម-អរូបជ្ឈានទី ១ ហៅថា អាកាសានញ្ចាយតនកុសលចិត្ត ជាកសិណុគ្ឃាដិ-មាកាសបញ្ញត្តិ ដែលបានបើករូបកសិណចេញហើយ ជាអារម្មណ៍។

កាលអប្បនាវិធី ដែលជាអាទិកម្មិក អរូបជ្ឈានរបស់មន្ទបុគ្គល (អ្នកដឹងយឺត) នឹងកើតឡើងនោះវិថីចិត្តរមែងកើតតាមលំដាប់យ៉ាងនេះគឺ ៖

# អាទិកម្មិករូបជ្ឈានវិថីរបស់មន្ទបុគ្គល

- ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត
- ភវង្គចលនៈ ជាមហាវិបាកញាណសម្បយុត្ត
- ភវង្គុប្បច្ឆេទៈ ជាមហាវិបាកញាណសម្បយុត្ត

(ភវង្គចិត្ត ភវង្គចលនៈ ភវង្គុប្បច្ឆេទៈ) ចិត្តផុតវិថី។

- មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយាចិត្ត
- បរិកម្ម
- ឧបចារៈ
- អនុលោម
- គោត្រភូ

(បរិកម្ម ឧបចារៈ អនុលោម គោត្រភូ) ជាមហាកុសលចិត្តប្រកបដោយ ឧបេក្ខាវេទនា ញាណសម្បយុត្ត ២ ដួង។

- បឋមរូបជ្ឈាន គឺ អាកាសានញ្ចាយតនកុសលចិត្ត។
- ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត។



# អាទិកម្មិករូបជ្ឈានវិថីរបស់តិក្ខបុគ្គល

- ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត
- ភវង្គចលនៈ ជាមហាវិបាកញាណសម្បយុត្ត
- ភវង្គុប្បច្ឆេទៈ ជាមហាវិបាកញាណសម្បយុត្ត

(ភវង្គចិត្ត ភវង្គចលនៈ ភវង្គុប្បច្ឆេទៈ) ចិត្តផុតវិថី។

- មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយាចិត្ត
- ឧបចារៈ
- អនុលោម
- គោត្រភូ

(ឧបចារៈ អនុលោម គោត្រភូ) ជាមហាកុសលចិត្តប្រកបដោយ ឧបេក្ខាវេទនា ញាណសម្បយុត្ត ២ ដួង។

- បឋមរូបជ្ឈាន គឺ អាកាសានញ្ចាយតនកុសលចិត្ត។
- ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត។

មើលវីដេអូ ភាគទី ៥២

# វិញ្ញាណញ្ចាយតនកុសលចិត្ត

**វិញ្ញាណមេវ អនន្តំ វិញ្ញាណានន្តំ បឋមវិញ្ញាណំ** វិញ្ញាណនោះឯង មិនមានទីបំផុត ឈ្មោះថា វិញ្ញាណានន្តំ បានដល់ អរូបជ្ឈានទី ១។

ម្យ៉ាងទៀត ឈ្មោះថា **វិញ្ញាណញ្ច** ព្រោះអត្ថថា ដែលត្រូវអរូបវិញ្ញាណទី ២ គប្បីដល់ គឺគប្បីសម្រេច ។

ដូច្នេះវិញ្ញាណញ្ចាយតនៈ ព្រោះអត្ថថា វិញ្ញាណញ្ច នោះជាអាយតនៈ ព្រោះជាទីតាំងនៃអរូបជ្ឈានទី ២ គឺ **វិញ្ញាណញ្ចាយតនជ្ឈាន**។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



ព្រះយោគីបុគ្គលកាលជំនាញក្នុង អាកាសានញ្ចាយតនឈានហើយមានបំណងនឹងចម្រើននូវអរូបជ្ឈានទី ២ ត្រូវធ្វើវសី ៥ ឱ្យស្ទាត់ហើយពិចារណាឃើញទោសនៃ អាកាសានញ្ចាយតនជ្ឈាន ឃើញសេចក្តីស្ងប់ប្រណិតរបស់វិញ្ញាណញ្ចាយតនជ្ឈាន ហើយក៏ចូលឈានទាញយក បឋមអរូបជ្ឈាន ជាអារម្មណ៍ដោយបង្អោនដោយសភាពរបស់វិញ្ញាណ ដែលមានអាកាសមិនមានទីបំផុតជាអារម្មណ៍ថា គឺ វិញ្ញាណមិនមានទីបំផុត (វិញ្ញាណំ អនន្តំ) រហូតដល់អរូបជ្ឈានទី ២ កើតឡើងដែលមានអាកាសានញ្ចាយតនចិត្ត ជាអារម្មណ៍។ នេះឯងឈ្មោះថា វិញ្ញាណញ្ចាយតនជ្ឈាន ឬថា ទុតិយអរូបជ្ឈានចិត្ត។

## អប្បនាវិថី នៃ ទុតិយអរូបជ្ឈាន

| | | |
|---|---|---|
| - ភវង្គចិត្ត | ជាមហាវិបាកញាណសម្បយុត្ត | ចិត្តផុតវិថី |
| - ភវង្គចលនៈ | ជាមហាវិបាកញាណសម្បយុត្ត | |
| - ភវង្គុប្បច្ឆេទៈ | ជាមហាវិបាកញាណសម្បយុត្ត | |
| - មនោទ្វារាវជ្ជនៈ | ជាអហេតុកកិរិយាចិត្ត | |
| - បរិកម្ម | ជាមហាកុសល ឧបេក្ខាញាណសម្បយុត្ត ២ ដួង | |
| - ឧបចារៈ | | |
| - អនុលោម | | |
| - គោត្រភូ | | |
| - ទុតិយអរូបជ្ឈាន | គឺ វិញ្ញាណញ្ចាយតនកុសលចិត្ត។ | |
| - ភវង្គចិត្ត | ជាមហាវិបាកញាណសម្បយុត្ត ។ | |



## អាកិញ្ចញ្ញាយតនកុសលចិត្ត

អាកិញ្ចញ្ញាយតនៈ មានន័យថា ជាអាយតនៈមួយកន្លែងដែលវិញ្ញាណសូម្បីបន្តិចបន្តួចក៏រមែងមិនមាន។

ព្រះយោគីបុគ្គលកាលបំណងនឹងធ្វើសមាធិឱ្យតាំងមាំប្រណិតឡើង ៗ ដោយការចូលអាកិញ្ចញ្ញាយតនជ្ឈាននោះ គឺ ត្រូវចូលវិញ្ញាណញ្ចាយតនជ្ឈានរហូតជំនាញនូវវសីទាំង ៥។ កាលចេញពីឈានហើយក៏ពិចារណាឃើញទោសរបស់វិញ្ញាណញ្ចាយតនជ្ឈានថា បើដាច់ការចូលឈាននេះជានិច្ចហើយ ឈាននេះអាចវិនាសត្រឡប់ទៅតាំងនៅក្នុងអាកាសានញ្ចាយតនជ្ឈានវិញ ឯសមាធិដែលកើតពីវិញ្ញាណញ្ចាយតនជ្ឈាននេះក៏នៅគ្រោតគ្រាតមិនប្រណីតស្មើនឹងអាកិញ្ចញ្ញាយតនជ្ឈានដែរ ទើបដាក់ចិត្តដល់សភាពនៃសេចក្តីមិនមានអ្វីរបស់អរូបជ្ឈានទី ១ ជាអារម្មណ៍

ប្រៀបដូចជាសាលាធំ ជាទីប្រជុំនៃសង្ឃ ធ្វើសង្ឃកម្ម ដែលជាអារម្មណ៍របស់អរូបជ្ឈានទី ២ នោះ ឥឡូវនេះព្រះសង្ឃធ្វើសង្ឃកិច្ចស្រេចហើយ ក៏ចេញពីសាលាទាំងអស់មិនមានសេសសល់ ចិត្តក៏បង្អោនទៅក្នុងសភាពដែលមិនមានអ្វីទៀតឡើយ (នត្ថិ កិញ្ចិ = មិនមានអ្វីៗ) រហូតអរូបជ្ឈានចិត្តកើតឡើង ដោយមាន នត្ថិភាវបញ្ញត្តិ ជាអារម្មណ៍។ អរូបជ្ឈានចិត្តនេះឈ្មោះថា អាកិញ្ចញ្ញាយតនជ្ឈាន ឬ តតិយអរូបជ្ឈាន (អាកិញ្ចញ្ញាយតន-កុសលចិត្ត)។

**វិថីចិត្តដែលកើតមុនអរូបជ្ឈានទី ៣ នេះ ដូចគ្នានឹងបឋមអរូបជ្ឈាន ឬ ទុតិយអរូបជ្ឈានវិថីដែរ ផ្សេងតែត្រង់ពាក្យថា អាកិញ្ចញ្ញាយតនកុសលចិត្តប៉ុណ្ណោះ។*



# នេវសញ្ញានាសញ្ញាយតនកុសលចិត្ត

នេវសញ្ញានាសញ្ញាយតនៈ មានន័យថា ជាអាយតនៈមួយកន្លែងដែលតែងមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ព្រោះមិនមានសញ្ញាគ្រោតគ្រាត មានតែសញ្ញាល្អិត ។ នេវសញ្ញានាសញ្ញានោះឯង ជាអាយតនៈ ព្រោះសង្គ្រោះចូលក្នុងមនាយតនៈ និង ធម្មាយតនៈ ព្រោះហេតុនោះទើបឈ្មោះថា «នេវសញ្ញានាសញ្ញាយតនជ្ឈាន»។

នេវសញ្ញានាសញ្ញាយតនៈនោះឯង ជាអាយតនៈជាទីតាំងនៃឈានព្រមទាំងសម្បយុត្តធម៌ដោយជានិស្សយប្បច្ច័យ ជាដើម ដូច្នោះហើយទើបឈ្មោះថា «នេវសញ្ញានាសញ្ញាយតនជ្ឈាន»។

ព្រះយោគីបុគ្គល អ្នកចម្រើនអរូបជ្ឈានទី៤នោះត្រូវជំនាញអរូបជ្ឈានទី ៣ ព្រមទាំង វសី ៥ រួចហើយចម្រើនអរូបជ្ឈានទី ៤ ដែលជាឈានប្រណិតបំផុត ដោយពិចារណាឃើញនូវអរូបជ្ឈានទី ៣ នេះថាជាធម៌ស្ងប់ប្រណីត ប៉ុន្តែមិនទាន់ស្ងប់ប្រណិតបំផុតទេ។ ដូច្នេះដើម្បីនឹងចម្រើនអរូបជ្ឈានទី ៤ ត្រូវចូលអរូបជ្ឈានទី ៣ សិន លុះចេញហើយក៏យកចិត្តទុកដាក់ពិចារណាសេចក្តីស្ងប់ប្រណិត ឯតំ សន្តំ ឯតំ បណីតំ នៃសញ្ញាក្នុងអាកិញ្ចញ្ញាយតនជ្ឈាន មិនមែនសញ្ញាដទៃទៀតទេ (វេទនាជាដើមក្នុងទីនេះក៏ស្ងប់ប្រណីតដូចគ្នា)។ ការដែលប្រើសញ្ញាស័ព្ទព្រោះសញ្ញាចេតសិកនេះជាតួចាំនិមិត្តតាំងអំពីការចម្រើនរូបជ្ឈានដំបូង ចម្រើនទៅរហូតដល់អរូបជ្ឈានទី៤ កើត។ កាលណាឈាននេះកើតក៏មានឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ ឬ ចតុត្ថារូបជ្ឈាន គឺ នេវសញ្ញា។

*វិថីចិត្តដែលកើតមុនអរូបជ្ឈានទី ៤ ក៏មានន័យដូចសេចក្តីដែលបានពោលរួចមកហើយ។*



# អរូបាវចរវិបាកចិត្ត ៤ ដួង

**(Formless-sphere Resultant Consciousness)**

- អាកាសានញ្ចាយតនវិបាកចិត្តំ
- វិញ្ញាណញ្ចាយតនវិបាកចិត្តំ
- អាកិញ្ចញ្ញាយតនវិបាកចិត្តំ
- នេវសញ្ញានាសញ្ញាយតនវិបាកចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរវិបាកចិត្តានិ នាម។

ប្រែថា៖

- អាកាសានញ្ចាយតនវិបាកចិត្ត ១

  Resultant Jhāna-consciousness dwelling on the "Infinity of Space."

- វិញ្ញាណញ្ចាយតនវិបាកចិត្ត ១

  Resultant Jhāna-consciousness dwelling on the "Infinity of Consciousness",

- អាកិញ្ចញ្ញាយតនវិបាកចិត្ត ១

  Resultant Jhāna-consciousness dwelling on "Nothingness",

- នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ១

  Resultant Jhāna-consciousness wherein "Perception neither is nor is not."

**ចិត្តទាំង ៤ ដួងនេះ ឈ្មោះថា អរូបាវចរវិបាកចិត្ត។**



ពេលដែលអរូបាវចរវិបាកចិត្តដួងណាមួយនឹងកើតឡើងនោះ មិនបានកើតជាវិថីដូចអរូបាវចរកុសលចិត្តទេ គឺថាមុនចុតិចិត្តនឹងកើតឡើងនោះអរូបាវចរកុសលដួងណាមួយកើតឡើងមុនរួច ទើបចុតិ។ កាលចុតិចិត្តរលត់ហើយ អរូបាវចរវិបាកចិត្តដួងណាមួយក៏កើតឡើងធ្វើកិច្ចបដិសន្ធិ តអំពីចុតិចិត្តនោះទាន់ពេលភ្លាម។

អរូបាវចរកុសលចិត្តដែលកើតមុនចុតិចិត្តមានអារម្មណ៍អ្វី អរូបាវចរវិបាកចិត្ត ដែលកើតបន្ទាប់អំពីចុតិចិត្តនោះ ក៏មានអារម្មណ៍នោះដូចនឹងកុសលរបស់ខ្លួនដែរ។ ឯអរូបាវចរវិបាកចិត្ត ៣ ដួងផ្សេងទៀតក៏មានន័យដូចគ្នានេះដែរ។

អរូបាវចរកុសលចិត្ត ធ្វើជវនកិច្ចតែម្យ៉ាង ចំណែកអរូបាវចរវិបាកចិត្តធ្វើកិច្ច ៣ យ៉ាងគឺ ៖

**១ - បដិសន្ធិ** ធ្វើកិច្ចបដិសន្ធិជាអរូបព្រហ្មបុគ្គលក្នុងអរូបភូមិ ៤ ប៉ុណ្ណោះ។

**២ - ភវង្គកិច្ច** ធ្វើកិច្ចរក្សាភពជាតិកំណើតឱ្យតាំងនៅដរាបរហូតស្មើអាយុនៃសង្ខារក្នុងភពនោះៗ។

**៣ - ចុតិកិច្ច** ធ្វើកិច្ចឃ្លាតចាកអំពីភពនោះៗ ក្នុងវារៈដែលអស់អាយុនៃសង្ខារ។

អរូបាវចរវិបាកចិត្ត ៤ ដួង ជាចិត្តកើតឡើងដោយមិនអាស្រ័យវត្ថុទាំង ៦ ណាមួយឡើយ ហើយមានចំពោះតែអរូបព្រហ្មប៉ុណ្ណោះ។

ក្នុងអរូបព្រហ្មបុគ្គលទាំង ៤ ព្រហ្មបុគ្គលក្នុងអាកាសានញ្ចាយតនភូមិ មានអាយុ ២ ម៉ឺនមហាកប្ប, ព្រហ្មបុគ្គលក្នុងវិញ្ញាណញ្ចាយតនភូមិ មានអាយុ ៤ ម៉ឺនមហាកប្ប, ព្រហ្មបុគ្គលក្នុងអាកិញ្ចញ្ញាយតនភូមិ មានអាយុ ៦ម៉ឺនមហាកប្ប, ព្រហ្មបុគ្គលក្នុងនេវសញ្ញានាសញ្ញាយតនភូមិ មានអាយុ ៨ ម៉ឺន ៤ ពាន់មហាកប្ប។



# អរូបាវចរកិរិយាចិត្ត ៤ ដួង

**(Formless-Sphere Functional Consciousness)**

- អាកាសានញ្ចាយតនកិរិយាចិត្តំ
- វិញ្ញាណញ្ចាយតនកិរិយាចិត្តំ
- អាកិញ្ចញ្ញាយតនកិរិយាចិត្តំ
- នេវសញ្ញានាសញ្ញាយតនកិរិយាចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរកិរិយាចិត្តានិ នាម។

- អាកាសានញ្ចាយតនកិរិយាចិត្ត ១

Functional Jhàna-consciousness dwelling on the “Infinity of Space.”

- វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១

Functional Jhàna-consciousness dwelling on the “Infinity of Consciousness”.

- អាកិញ្ចញ្ញាយតនកិរិយាចិត្ត ១

Functional Jhàna-consciousness dwelling on “Nothingness”.

- នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១

Functional Jhana-consciousness wherein “Perception neither is nor is not.”

472

ចិត្តទាំង ៤ ដួងនេះឈ្មោះថា អរូបាវចរកិរិយាចិត្ត។ អរូបាវចរកិរិយាចិត្ត ៤ ដួងនេះ មានអង្គឈានស្មើគ្នា និងដូចគ្នា គឺ ឧបេក្ខា និង ឯកគ្គតា តែមានអារម្មណ៍ផ្សេងគ្នា មានសភាពដូចគ្នានឹងអរូបាវចរកុសលចិត្តដែរ។

# វិថីរបស់អរូបាវចរកិរិយាចិត្ត

- ភវង្គចិត្ត ជាមហាវិបាកញ្ញាណសម្បយុត្ត
- ភវង្គចលនៈ ជាមហាវិបាកញ្ញាណសម្បយុត្ត } ចិត្តផុតវិថី
- ភវង្គុបច្ឆេទៈ ជាមហាវិបាកញ្ញាណសម្បយុត្ត
- មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយាចិត្ត
- បរិកម្ម
- ឧបចារៈ
- អនុលោម
- គោត្រភូ
  } ជាមហាកិរិយា ឧបេក្ខាញ្ញាណសម្បយុត្ត ២ ដួង
- អរូបាវចរកិរិយាចិត្ត
- ភវង្គចិត្ត ជាមហាវិបាកញ្ញាណសម្បយុត្ត ។

➢ វិថីចិត្តនេះសម្រាប់មន្ទបុគ្គល ចំណែកតិក្ខបុគ្គលមិនមានបរិកម្មទេ។



# អរូបាវចរចិត្តទាំង១២ដួង

## មានចេតសិកកើតរួម ៣០ គឺ ៖

- អញ្ញសមានាចេតសិក ១០

(វៀរ វិតក្កៈ វិចារៈ បីតិ)

- សោភណសាធារណចេតសិក ១៩

- បញ្ញាចេតសិក ១

(វៀរ វិរតិ ៣ អប្បមញ្ញា ២)



# ការចែកអរូបាវចរចិត្ត ១២ ដួងដោយន័យផ្សេងៗ

១ - ដោយជាតិ ជាកុសលជាតិ ៤ ដួង ជាវិបាក ៤ ដួង ជាកិរិយា ៤ ដួង។

២ - ដោយភូមិ ជាអរូបាវចរភូមិទាំង ១២ ដួង។

*ក្នុងភូមិជាទីកើត ៣១ ភូមិនោះអរូបាវចរកុសលចិត្ត៤ដួង និង អរូបាវចរកិរិយាចិត្ត ៤ ដួង កើតបាន ២៦ ភូមិ(វៀរអបាយភូមិ ៤ អសញ្ញសត្តាភូមិ ១) ចំណែកអរូបាវចរវិបាកចិត្ត ៤ ដួង កើតបានចំពោះតែក្នុងអរូបព្រហ្មភូមិ ៤ ប៉ុណ្ណោះ។*

៣ - ដោយវេទនា ជាឧបេក្ខាវេទនាទាំង ១២ ដួង។

៤ - ដោយហេតុ ជានហេតុ និង ជាតិហេតុកចិត្ត។

៥ - ដោយសម្បយុត្ត ជាញាណសម្បយុត្តទាំង ១២ ដួង។

៦ - ដោយសង្ខារ ជាសសង្ខារិកចិត្តទាំង ១២ ដួង។



៧ - ដោយសោភណៈ ជាអរូបាវចរសោភណចិត្ត។

៨ - ដោយឈាន ជាបញ្ចមជ្ឈាន (បញ្ចកន័យ) ទាំង ១២ ដួង។

៩ - ដោយលោកិយ ជាលោកិយចិត្តទាំង ១២ ដួង។

១០ - ដោយកិច្ច អរូបាវចរកុសលចិត្ត ៤ ដួង និង អរូបាវចរកិរិយា ៤ ដួង(ធ្វើជវនកិច្ច) អរូបាវចរវិបាក ៤ ដួង (ធ្វើកិច្ច ៣ គឺ បដិសន្ធិ ភវង្គ ចុតិ)។

១១ - ដោយអារម្មណ៍ មានធម្មារម្មណ៍ ជាអារម្មណ៍ទាំង ១២ ដួង។

១២ - ដោយវត្ថុ អរូបាវចរកុសលចិត្ត ៤ ដួង និង អរូបាវចរកិរិយាចិត្ត ៤ដួង ដែលកើតក្នុងបញ្ចវោការភូមិ អាស្រ័យហទយវត្ថុ បើកើតក្នុងចតុវោការភូមិ មិនចាំបាច់អាស្រ័យវត្ថុក៏កើតឡើងបានដែរ។

១៣ - ដោយទ្វារ អរូបាវចរកុសល ៤ ដួង និង អរូបាវចរកិរិយាចិត្ត ៤ ដួង ដឹងអារម្មណ៍តាម មនោទ្វារ ចំណែកអរូបាវចរវិបាកចិត្ត ៤ ដួងជាទ្វារវិមុត្តិ។

១៤ - ដោយវិញ្ញាណធាតុ ជាមនោវិញ្ញាណធាតុ។



មើលវីដេអូ ភាគទី ៥៣

## ៤. លោកុត្តរសោភណចិត្ត ៨ ដួង

(Supramundane Consciousness)

### ចែកជាពីរប្រភេទ គឺ ៖

ក. លោកុត្តរមគ្គចិត្ត ឬ លោកុត្តរកុសលចិត្ត ៤ ដួង

ខ. លោកុត្តរផលចិត្ត ឬ លោកុត្តរវិបាកចិត្ត ៤ ដួង

ស្កេនដើម្បីមើលមេរៀន
San Sochea Official

ពាក្យថា លោកុត្តរ < លោក + ឧត្តរ ប្រែថា លើសអំពីលោក ឬផុតអំពីលោក មានន័យថា ជាចិត្តមានអារម្មណ៍ផុតពី

សភាវធម៌ដែលមាននៅក្នុងលោក ឬថា ជាចិត្តដែលមានអំណាចទទួលអារម្មណ៍ក្រៅពីលោក ឬផុតចាកលោក ។ អារម្មណ៍របស់លោកុត្តរចិត្តនោះ បានដល់ព្រះនិព្វាន ។

ក្នុងចិត្តទាំង ៨៩ ដួង ចិត្តដែលអាចទទួលព្រះនិព្វានជាអារម្មណ៍បានប្រាកដមានតែ ៨ ដួង ប៉ុណ្ណោះ។ ក្រៅពីនោះសូម្បីមានចិត្តខ្លះអាចដឹងព្រះនិព្វានជាអារម្មណ៍បាន ក៏មិនប្រាកដច្បាស់ ព្រោះហេតុដូច្នោះហើយ ទើបហៅថាចិត្ត ៨ ដួង នោះថា លោកុត្តរចិត្ត ។



## ក. លោកុត្តរកុសលចិត្ត ៤ ដួង

**(Moral Supramundane Consciousness)**

- សោតាបត្តិមគ្គចិត្តំ
- សកទាគាមិមគ្គចិត្តំ
- អនាគាមិមគ្គចិត្តំ
- អរហត្តមគ្គចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរ-កុសលចិត្តានិ នាម។

ប្រែថា៖

-សោតាបត្តិមគ្គចិត្ត ១ ដួង

Sotāpatti Path-consciousness (Stream-entry)

-សកទាគាមិមគ្គចិត្ត ១ ដួង

Sakadāgāmi Path-consciousness (Once-returning)

-អនាគាមិមគ្គចិត្ត ១ ដួង

Anāgāmi Path-consciousness (Non-returning)

-អរហត្តមគ្គចិត្ត ១ ដួង

Arahatta Path-consciousness.

ចិត្តទាំង ៤ ដួងនេះឈ្មោះ លោកុត្តរកុសលចិត្ត។



## ➤ សោតាបត្តិមគ្គចិត្ត

ពាក្យថា សោតាបត្តិមគ្គចិត្ត < សោតៈ+អាបត្តិ + មគ្គៈ + ចិត្ត

- សោតៈ ប្រែថា ក្រសែ គឺថាអរិយមគ្គមានអង្គ ៨ បណ្ឌិតហៅថា សោតៈ (ក្រសែ) ដែលហូរតម្រង់ទៅ គឺចូលកាន់ព្រះនិព្វាន ឬ ដូចជាក្រសែទឹក ដែលហូរទៅកាន់មហាសមុទ្រគឺព្រះនិព្វាន។
- អាបត្តិ ប្រែថា ការដល់ហើយ គឺការសម្រេចតាំងពីខាងដើម ជាការសេពគ្រាដំបូងនូវសោតៈនោះ។
- មគ្គ ដោយអត្ថថា ការស្វែងរកព្រះនិព្វាន ឬ ការទៅសម្លាប់កិលេសទាំងឡាយ ។
- មគ្គចិត្ត គឺចិត្តសម្បយុត្តដោយមគ្គនោះ។

**មគ្គចិត្ត ដែលបានសម្រេចក្រសែដំបូង ឈ្មោះថា សោតាបត្តិមគ្គចិត្ត បានដល់មគ្គចិត្តរបស់ព្រះអរិយបុគ្គលដំបូង ដែលនៅមានបដិសន្ធិទៀតយ៉ាងច្រើន ក៏ ៧ ជាតិទៀតនៅក្នុងលោកនេះ។*

## ➢ សកទាគាមិមគ្គចិត្ត

ពាក្យថា សកទាគាមិមគ្គចិត្ត < សកឹ + អាគាមី + ចិត្ត

- សកឹ ប្រែថា ១ ដង ១ វារៈ
- អាគាមី ប្រែថា ត្រឡប់មក
- សកទាគាមិមគ្គចិត្ត គឺមគ្គចិត្តដែលញ៉ាំងឱ្យបុគ្គលត្រឡប់មកកាន់កាមលោកម្តងទៀត បានដល់មគ្គចិត្តរបស់ព្រះអរិយបុគ្គលទី ២ ដែលត្រឡប់មកបដិសន្ធិ ក្នុងកាមភូមិម្តងទៀតប៉ុណ្ណោះ។



## ➢អនាគាមិមគ្គចិត្ត

ពាក្យថា អនាគាមិមគ្គចិត្ត < ន + អាគាមី + មគ្គ + ចិត្ត

អនាគាមិមគ្គចិត្ត គឺមគ្គចិត្តដែលញ៉ាំងឱ្យបុគ្គលមិនចាំបាច់ត្រឡប់មកកាន់កាមលោក  សូម្បីតែម្តងទៀតទេ បានដល់មគ្គចិត្តរបស់ព្រះអរិយបុគ្គលទី ៣ ដែលមិនត្រូវត្រឡប់មកបដិសន្ធិក្នុងកាមលោក។

## ➢ អរហត្តមគ្គចិត្ត

ពាក្យថា អរហត្តមគ្គចិត្ត < អរហត្ត + មគ្គ + ចិត្ត ឈ្មោះថាព្រះអរហន្ត ដោយអត្ថថា គួរដល់ការបូជាវិសេស ព្រោះភាពជាទក្ខិណេយ្យបុគ្គលដ៏កំពូល ។ម្យ៉ាងទៀត ឈ្មោះថា អរហន្ត ព្រោះមិនមានការត្រឡប់មក ក្នុងការធ្វើបាបទៀតទេ បានដល់ព្រះអរិយបុគ្គលទី ៤។ ភាវៈនៃបុគ្គលទី ៤នោះ ឈ្មោះថាអរហត្ត ។

ពាក្យថា អរហត្ត នោះជាឈ្មោះនៃផលទី ៤ ។

មគ្គដែលជាហេតុនៃអរហត្តនោះ ឈ្មោះថា អរហត្តមគ្គ។ ចិត្តដែលសម្បយុត្តដោយអរហត្តមគ្គនោះ ឈ្មោះថា អរហត្តមគ្គចិត្ត ។



ក្នុងមគ្គចិត្ត ៤ ដួងនោះ ចាត់ថាលោកុត្តរកុសល ព្រោះជាកុសលដែលធ្វើឱ្យឆ្លងផុតចាកលោក ៣ គឺ កាមលោក ១ រូបលោក ១ អរូបលោក ១។

កាមលោក បានដល់ កាមភូមិ ១១ ភូមិ

រូបលោក បានដល់ រូបភូមិ ១៦ ភូមិ

អរូបលោក បានដល់ អរូបភូមិ ៤ ភូមិ រួមទាំងអស់ជា ៣១ ភូមិ។

## ការរួចផុតលោកនោះ មានប្រការដូច្នេះគឺ៖

មគ្គចិត្តដួងទី ១ ហៅថា បឋមមគ្គ គឺសោតាបត្តិមគ្គចិត្ត។
មគ្គចិត្តដួងទី ២ ហៅថា ទុតិយមគ្គ គឺ សកទាគាមិមគ្គចិត្ត

ចិត្ត២ដួងនេះធ្វើឱ្យផុតចាកកាមលោក គឺ អបាយភូមិទាំង ៤។

មគ្គចិត្តដួងទី ៣ ហៅថា តតិយមគ្គ គឺអនាគាមិមគ្គចិត្ត ចិត្ត១ដួងនេះធ្វើឱ្យផុតចាកពីកាមលោក ទាំង ១១ ភូមិ។ មគ្គចិត្តដួងទី ៤ ហៅថា ចតុត្ថមគ្គ គឺអរហត្តមគ្គចិត្ត ចិត្ត១ដួងនេះ ធ្វើឱ្យផុតចាកលោកទាំង៣១ភូមិ។



ដែលហៅថា **លោកុត្តរកុសល** ព្រោះជាកុសលដែលធ្វើឱ្យឆ្លងផុតពីបុថុជ្ជនទៅជាព្រះអរិយបុគ្គលដោយប្រការដូច្នេះគឺ៖

- មគ្គចិត្តដួងទី ១ ធ្វើឱ្យទៅជាព្រះសោតាបន្នបុគ្គល
- មគ្គចិត្តដួងទី ២ ធ្វើឱ្យទៅជាព្រះសកទាគាមិបុគ្គល
- មគ្គចិត្តដួងទី ៣ ធ្វើឱ្យទៅជាព្រះអនាគាមិបុគ្គល
- មគ្គចិត្តដួងទី ៤ ធ្វើឱ្យទៅជាព្រះអរហន្ត

ដែលហៅថា លោកុត្តរកុសល ព្រោះជាកុសលដែលកើតឡើងមានព្រះនិព្វានជាលោកុត្តរធម៌ជាអារម្មណ៍ ហើយការដែលលោកុត្តរកុសលចិត្ត ៤ ដួងនេះកើតឡើងបាន ក៏ព្រោះមានព្រះនិព្វានជាអារម្មណប្បច្ច័យ ទើបកើត។

ដែលហៅថា លោកុត្តរកុសល ព្រោះជាកុសលដែលមានអំណាចប្រសើរ លើសលោកិយកុសលទាំងឡាយ អាចរំលត់អកុសលឱ្យដាច់ជាសមុច្ឆេទបានគឺ ព្រោះហេតុតែមានព្រះនិព្វានជាអារម្មណ៍នោះឯង។



លោកុត្តរកុសលពោលគឺ មគ្គចិត្ត ៤ដួង តាមសេចក្ដីផ្សេងគ្នានៃការប្រកបរបស់អដ្ឋង្គិកមគ្គមានសោតាបត្តិមគ្គជាដើម គឺដោយអំណាចការលះ សំយោជនៈបាន។

ការដែលលះសំយោជនៈបានផ្សេងៗ គ្នា ក៏ព្រោះឥន្ទ្រិយ ៥ មានសទ្ធាជាដើម មានកម្លាំងផ្សេងៗគ្នាគឺ ឥន្ទ្រិយ ៥ របស់សោតាបត្តិមគ្គ មិនចាស់ក្លា របស់សកទាគាមិមគ្គចាស់ក្លា របស់អនាគាមិមគ្គ ចាស់ក្លាជាង របស់អរហត្តមគ្គ ចាស់ក្លាជាទីបំផុតនោះឯង ។

# វិថីរបស់សោតាបត្តិមគ្គចិត្ត

- ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត
- ភវង្គចលនៈ ជាមហាវិបាកញាណសម្បយុត្ត
- ភវង្គុប្បច្ឆេទៈ ជាមហាវិបាកញាណសម្បយុត្ត
  } ចិត្តផុតវិថី
- មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយាចិត្ត
- បរិកម្ម
- ឧបចារៈ
- អនុលោម
- គោត្រភូ
  } ជាមហាកុសលញាណសម្បយុត្ត ៤ ដួង ណាមួយ
- មគ្គ សោតាបត្តិមគ្គចិត្ត
- ផល
- ផល
  } សោតាបត្តិផលចិត្ត
- ភវង្គចិត្ត ជាមហាវិបាកញាណសម្បយុត្ត ។

➢ វិថីចិត្តនេះសម្រាប់មន្ទបុគ្គល ចំណែកតិក្ខបុគ្គលមិនមានបរិកម្មទេ។



## សោតាមគ្គចិត្តកាលកើតឡើងនឹងមានវិថីចិត្តយ៉ាងនេះគឺ ៖




➢ វិថីចិត្តនេះសម្រាប់មន្ទបុគ្គល ចំណែកតិក្ខបុគ្គលមិនមានបរិកម្មទេ។

# វិថីរបស់សកទាគាមិមគ្គចិត្តជាដើមឡើងទៅ

- ភវង្គចិត្ត ជាមហាវិបាកញ្ញាណសម្បយុត្ត
- ភវង្គចលនៈ ជាមហាវិបាកញ្ញាណសម្បយុត្ត } ចិត្តផុតវិថី
- ភវង្គុប្បច្ឆេទៈ ជាមហាវិបាកញ្ញាណសម្បយុត្ត
- មនោទ្វារាវជ្ជនៈ ជាអហេតុកកិរិយាចិត្ត
- បរិកម្ម
- ឧបចារៈ
- អនុលោម
- វោទានៈ } ជាមហាកុសលញ្ញាណសម្បយុត្ត ៤ ដួង ណាមួយ
- មគ្គ សកទាគាមិមគ្គចិត្ត អនាគាមិមគ្គចិត្ត អរហត្តមគ្គចិត្ត
- ផល
- ផល } សកទាគាមិផលចិត្ត អនាគាមិផលចិត្ត អរហត្តផលចិត្ត
- ភវង្គចិត្ត ជាមហាវិបាកញ្ញាណសម្បយុត្ត ។

➢ វិថីចិត្តនេះសម្រាប់មន្ទបុគ្គល ចំណែកតិក្ខបុគ្គលមិនមានបរិកម្មទេ។



# វិថីរបស់សកទាគាមិមគ្គចិត្តជាដើមឡើងទៅ




➢ វិថីចិត្តនេះសម្រាប់មន្ទបុគ្គល ចំណែកតិក្ខបុគ្គលមិនមានបរិកម្មទេ។

# អកុសលធម៌ ៩កង

អកុសលធម៌ គឺជាធម៌ដែលជាអកុសល ដែលព្រះអរិយបុគ្គលគប្បីលះ (ប្រហារ) ទាំងអស់ មាន ៩ កង ឬ ៩ ប្រភេទ គឺ៖

១ - អាសវៈ ធម៌ដែលត្រាំក្នុងខន្ធសន្តាន មាន៤ គឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ និង អវិជ្ជាសវៈ។

២ - ឱឃៈ ធម៌ដែលប្រៀបដូចអន្លង់ទឹកញាំងសត្វឱ្យលិចលង់ក្នុងសង្សារវដ្ត មាន៤ គឺ កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ និងអវិជ្ជោឃៈ។

៣ - យោគៈ ធម៌ដែលប្រកបសត្វទុកក្នុងភព មាន៤ គឺ កាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ និងអវិជ្ជាយោគៈ។

៤ - គន្ថៈ ធម៌ជាគ្រឿងចងសត្វទុក មាន៤ គឺ អភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ និងឥទំសច្ចាភិនិវេសកាយគន្ថៈ។



៥ - ឧបាទានៈ ធម៌ដែលជាគ្រឿងប្រកាន់ មាន៤ គឺ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន និងអត្តវាទុបាទាន។

៦ - នីវរណធម៌ ជាគ្រឿងរារាំងនូវសេចក្តីល្អ មាន៦ គឺ កាមឆន្ទៈ ព្យាបាទ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា និងអវិជ្ជា។

៧ - អនុស័យៈ ធម៌ដែលដេកសម្ងំក្នុងខន្ធសន្តាន មាន៧ គឺ កាមរាគានុស័យ ទិដ្ឋានុស័យ បដិឃានុស័យ ភវរាគានុស័យ មានានុស័យ វិចិកិច្ឆានុស័យ និងអវិជ្ជានុស័យ។

៨ - សញ្ញោជនៈ ធម៌ជាគ្រឿងរួបរិតសត្វទុក មាន១០ គឺ កាមរាគៈ (កាមរាគសញ្ញោជន) ភវរាគៈ មានៈ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ឥស្សា មច្ឆរិយៈ បដិឃៈ និង អវិជ្ជាសញ្ញោជនៈ។

៩ - កិលេសៈ ធម៌ជាគ្រឿងសៅហ្មង មាន១០ គឺ លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បកិលេស។

# មគ្គចិត្តលះអកុសលធម៌ ៩ភេទ

មើលវីដេអូ ភាគទី ៥៤

## សោតាបត្តិមគ្គ លះអកុសលធម៌មួយចំនួន ( សមុច្ឆេទប្បហាន )

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| អាសវៈ | កាមាសវៈ | ភវាសវៈ | ទិដ្ឋាសវៈ | អវិជ្ជាសវៈ | | | | | | | |
| ឱឃៈ | កាមោឃៈ | ភវោឃៈ | ទិដ្ឋោឃៈ | អវិជ្ជោឃៈ | | | | | | | |
| យោគៈ | កាមយោគៈ | ភវយោគៈ | ទិដ្ឋិយោគៈ | អវិជ្ជាយោគៈ | | | | | | | |
| គន្ថៈ | អភិជ្ឈា | ព្យាបាទ | សីលព្វតបរា... | ឥទំសច្ចាភិ... | | | | | | | |
| ឧបាទានៈ | កាមុបាទាន | ទិដ្ឋុបាទាន | សីលព្វតុបាទាន | អត្តវាទុបាទាន | | | | | | | |
| នីវរណធម៌ | កាមឆន្ទៈ | ព្យាបាទ | ថីនមិទ្ធៈ | ឧទ្ធច្ចកុក្កុច្ចៈ (គ្រោតគ្រាត) | វិចិកិច្ឆា | អវិជ្ជា | | | | | |
| អនុស័យៈ | កាមរាគានុស័យ | បដិឃានុស័យ | ភវរាគានុស័យ | ទិដ្ឋានុស័យ | មានានុស័យ | វិចិកិច្ឆានុស័យ | អវិជ្ជានុស័យ | | | | |
| សញ្ញោជនៈ | កាមរាគៈ | ភវរាគៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | សីលព្វតបរា... | ឥស្សា | មច្ឆរិយៈ | បដិឃៈ | អវិជ្ជាសញ្ញោ.. | |
| កិលេសៈ | លោភៈ | ទោសៈ | មោហៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | ថីនៈ | ឧទ្ធច្ចៈ | អហិរិកៈ | អនោត្តប្បៈ | |

ចំណាំ សោតាបត្តិមគ្គចិត្ត លះអកុសលធម៌ដែលមានអក្សរពណ៌ក្រហម

ស្កេនដើម្បីមើលមេរៀន

San Sochea Official



## សកទាគាមិមគ្គចិត្ត

## លះអកុសលធម៌ដែលនៅសល់ ឲ្យស្រាលស្តើង ( តនុក្ករប្បហាន )

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| អាសវៈ | កាមាសវៈ | ភវាសវៈ | ទិដ្ឋាសវៈ | អវិជ្ជាសវៈ | | | | | | | |
| ឱឃៈ | កាមោឃៈ | ភវោឃៈ | ទិដ្ឋោឃៈ | អវិជ្ជោឃៈ | | | | | | | |
| យោគៈ | កាមយោគៈ | ភវយោគៈ | ទិដ្ឋិយោគៈ | អវិជ្ជាយោគៈ | | | | | | | |
| គន្ថៈ | អភិជ្ឈា | ព្យាបាទ | សីលព្វតបរា... | ឥទំសច្ចាភិ... | | | | | | | |
| ឧបាទានៈ | កាមុបាទាន | ទិដ្ឋុបាទាន | សីលព្វតុបាទាន | អត្តវាទុបាទាន | | | | | | | |
| នីវរណធម៌ | កាមឆន្ទៈ | ព្យាបាទ | ថីនមិទ្ធៈ | ឧទ្ធច្ចកុក្កុច្ចៈ (គ្រោតគ្រាត) | .វិចិកិច្ឆា | អវិជ្ជា | | | | | |
| អនុស័យៈ | កាមរាគានុស័យ | បដិឃានុស័យ | ភវរាគានុស័យ | ទិដ្ឋានុស័យ | មានានុស័យ | វិចិកិច្ឆានុស័យ | អវិជ្ជានុស័យ | | | | |
| សញ្ញោជនៈ | កាមរាគៈ | ភវរាគៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | សីលព្វតបរា... | ឥស្សា | មច្ឆរិយៈ | បដិឃៈ | អវិជ្ជាសញ្ញោ.. | |
| កិលេសៈ | លោភៈ | ទោសៈ | មោហៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | ថីនៈ | ឧទ្ធច្ចៈ | អហិរិកៈ | អនោត្តប្បៈ | |

ចំណាំ សកទាគាមិមគ្គចិត្ត ធ្វើឲ្យអកុសលធម៌ដែលសល់ (ពណ៌ខ្មៅ) ស្រាលស្តើង។

# អនាគាមិមគ្គចិត្ត

## លះអកុសលធម៌មួយចំនួនទៀត ( សមុច្ឆេទប្បហាន )

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| អាសវៈ | កាមាសវៈ | ភវាសវៈ | ទិដ្ឋាសវៈ | អវិជ្ជាសវៈ | | | | | | |
| ឱឃៈ | កាមោឃៈ | ភវោឃៈ | ទិដ្ឋោឃៈ | អវិជ្ជោឃៈ | | | | | | |
| យោគៈ | កាមយោគៈ | ភវយោគៈ | ទិដ្ឋិយោគៈ | អវិជ្ជាយោគៈ | | | | | | |
| គន្ថៈ | អភិជ្ឈា | ព្យាបាទ | សីលព្វតបរា... | ឥទំសច្ចាភិ... | | | | | | |
| ឧបាទានៈ | កាមុបាទាន | ទិដ្ឋុបាទាន | សីលព្វតុបាទាន | អត្តវាទុបាទាន | | | | | | |
| នីវរណធម៌ | កាមឆន្ទៈ | ព្យាបាទ | ថីនមិទ្ធៈ | ឧទ្ធច្ចកុក្កុច្ចៈ (គ្រោតគ្រាត) | វិចិកិច្ឆា | អវិជ្ជា | | | | |
| អនុស័យៈ | កាមរាគានុស័យ | បដិឃានុស័យ | ភវរាគានុស័យ | ទិដ្ឋានុស័យ | មានានុស័យ | វិចិកិច្ឆានុស័យ | អវិជ្ជានុស័យ | | | |
| សញ្ញោជនៈ | កាមរាគៈ | ភវរាគៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | សីលព្វតបរា... | ឥស្សា | មច្ឆរិយៈ | បដិឃៈ | អវិជ្ជាសញ្ញោ.. |
| កិលេសៈ | លោភៈ | ទោសៈ | មោហៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | ថីនៈ | ឧទ្ធច្ចៈ | អហិរិកៈ | អនោត្តប្បៈ |

ចំណាំ អនាគាមិមគ្គចិត្ត លះអកុសលធម៌ដែលមានអក្សរពណ៌ផ្កាឈូក



# អរហត្តមគ្គចិត្ត

## លះអកុសលធម៌ដែលនៅសល់ទាំងអស់ ( សមុច្ឆេទប្បហាន )

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| អាសវៈ | កាមាសវៈ | ភវាសវៈ | ទិដ្ឋាសវៈ | អវិជ្ជាសវៈ | | | | | | |
| ឱឃៈ | កាមោឃៈ | ភវោឃៈ | ទិដ្ឋោឃៈ | អវិជ្ជោឃៈ | | | | | | |
| យោគៈ | កាមយោគៈ | ភវយោគៈ | ទិដ្ឋិយោគៈ | អវិជ្ជាយោគៈ | | | | | | |
| គន្ថៈ | អភិជ្ឈា | ព្យាបាទ | សីលព្វតបរា... | ឥទំសច្ចាភិ... | | | | | | |
| ឧបាទានៈ | កាមុបាទាន | ទិដ្ឋុបាទាន | សីលព្វតុបាទាន | អត្តវាទុបាទាន | | | | | | |
| នីវរណធម៌ | កាមឆន្ទៈ | ព្យាបាទ | ថីនមិទ្ធៈ | ឧទ្ធច្ចកុក្កុច្ចៈ (គ្រោតគ្រាត) | វិចិកិច្ឆា | អវិជ្ជា | | | | |
| អនុស័យៈ | កាមរាគានុស័យ | បដិឃានុស័យ | ភវរាគានុស័យ | ទិដ្ឋានុស័យ | មានានុស័យ | វិចិកិច្ឆានុស័យ | អវិជ្ជានុស័យ | | | |
| សញ្ញោជនៈ | កាមរាគៈ | ភវរាគៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | សីលព្វតបរា... | ឥស្សា | មច្ឆរិយៈ | បដិឃៈ | អវិជ្ជាសញ្ញោ.. |
| កិលេសៈ | លោភៈ | ទោសៈ | មោហៈ | មានៈ | ទិដ្ឋិ | វិចិកិច្ឆា | ថីនៈ | ឧទ្ធច្ចៈ | អហិរិកៈ | អនោត្តប្បៈ |

ចំណាំ អរហត្តមគ្គចិត្ត លះអកុសលធម៌ដែលនៅសល់ទាំងអស់
គឺពួកអកុសលធម៌ដែលមានអក្សរពណ៌ខ្មៅ ។

## មគ្គចិត្តលះអកុសលចិត្ត១២ដួងដូច្នេះ គឺ៖

១ - សោតាបត្តិមគ្គចិត្ត — លះអកុសលចិត្ត ៥ ដួង គឺ លោភមូលចិត្ត ទិដ្ឋិគតសម្បយុត្ត ៤ ដួង និងមោហមូលចិត្ត វិចិកិច្ឆាសម្បយុត្ត ១ ដួង។

២ - សកទាគាមិមគ្គចិត្ត — ធ្វើឲ្យអកុសលចិត្តដែលនៅសល់កាន់តែស្រាលស្តើង។

៣ - អនាគាមិមគ្គចិត្ត — លះទោសមូលចិត្ត ២ ដួងបន្ថែមទៀត ។

៤ - អរហត្តមគ្គចិត្ត — លះអកុសលចិត្ត ៥ ដួងដែលនៅសល់ គឺ លោភមូលចិត្ត ទិដ្ឋិគតវិប្បយុត្ត ៤ ដួង និងមោហមូលចិត្ត ឧទ្ធច្ចសម្បយុត្ត ១ ដួង។



## មគ្គចិត្តលះអកុសលកម្មបថ ១០ ដូច្នេះ គឺ៖

១ - សោតាបត្តិមគ្គចិត្ត — លះបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ និងមិច្ឆាទិដ្ឋិ ។

២ - សកទាគាមិមគ្គចិត្ត — ធ្វើឲ្យអកុសលកម្មបថដែលនៅសល់កាន់តែស្រាលស្តើង។

៣ - អនាគាមិមគ្គចិត្ត — លះបិសុណាវាចា ផរុសវាចា និងព្យាបាទ បន្ថែមទៀត។

៤ - អរហត្តមគ្គចិត្ត — លះអកុសលកម្មបថ ២ ទៀតដែលនៅសល់ គឺ សម្ផប្បលាបវាទ និងអភិជ្ឈា ។

# ព្រះសោតាបន្ន ៣ ប្រភេទ

១. ឯកពីជីសោតាបន្ន — ឈ្មោះថា ឯកពីជី ព្រោះអត្ថថា មានពូជ (ការកើត) ១ជាតិទៀត គឺព្រះសោតាបន្នកើតឡើងតែមួយដងទៀតក៏បាន សម្រេចនូវអរហត្តផល ហើយបរិនិព្វាន។

២. កោលំកោលសោតាបន្ន — ឈ្មោះថាកោលំកោល ព្រោះអត្ថថា ទៅពីត្រកូលមួយទៅកាន់ត្រកូលមួយ គឺព្រះសោតាបន្នដែលត្រូវកើត ២ ជាតិទៅ ៦ ជាតិទៀត ទើបនឹងបរិនិព្វាន។

៣. សត្តក្ខត្តុបរមសោតាបន្ន — ឈ្មោះថា សត្តក្ខត្តុបរម ព្រោះអត្ថថា មាន៧ ជាតិទៀតយ៉ាងច្រើន គឺព្រោះសោតាបន្នត្រូវកើតមិនហួសពី៧ជាតិទៀតឡើយ ហើយបរិនិព្វាន។



# ព្រះសកទាគាមី ៥ប្រភេទ

១. ឥធ បត្វា ឥធ បរិនិព្វាយី — ព្រះសកទាគាមី អ្នកសម្រេចក្នុងមនុស្សលោកនេះ ហើយបរិនិព្វានក្នុងមនុស្សលោកនេះ។

២. តត្ថ បត្វា តត្ថ បរិនិព្វាយី — ព្រះសកទាគាមី អ្នកសម្រេចក្នុងទេវលោកនោះ ហើយបរិនិព្វានក្នុងទេវលោកនោះ។

៣. ឥធ បត្វា តត្ថ បរិនិព្វាយី — ព្រះសកទាគាមីអ្នកសម្រេចក្នុងមនុស្សលោកនេះ ហើយបរិនិព្វានក្នុងទេវលោកនោះ។

៤. តត្ថ បត្វា ឥធ បរិនិព្វាយី — ព្រះសកទាគាមី អ្នកសម្រេចក្នុងទេវលោកនោះ ហើយបរិនិព្វានក្នុងមនុស្សលោកនេះ។

៥. ឥធ បត្វា តត្ថ និព្វត្តិត្វា ឥធ បរិនិព្វាយី — ព្រះសកទាគាមី អ្នកសម្រេចក្នុងមនុស្សលោកនេះ បានកើតក្នុងទេវលោកនោះ ហើយចុតិពីទេវលោកនោះ រួចមកកើតក្នុងមនុស្សលោក ទើបបរិនិព្វានក្នុងមនុស្សលោកនេះ។

# ព្រះអនាគាមី ៥ប្រភេទ

១. អន្តរាបរិនិព្វាយី — បានដល់ព្រះអនាគាមី អ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយហើយបរិនិព្វាន មុនពាក់កណ្តាលអាយុខេយ្យ នៃភូមិនោះ។

២. ឧបហច្ចបរិនិព្វានយី — បានដល់ព្រះអនាគាមី អ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយហើយបរិនិព្វាន កន្លងពាក់កណ្តាលអាយុខេយ្យ នៃភូមិនោះ។

៣. អសង្ខារបរិនិព្វានយី — បានដល់ព្រះអនាគាមី អ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយហើយសម្រេចព្រះអរហត្តបរិនិព្វាន ដោយស្រួល មិនចាំបាច់ព្យាយាមច្រើន។



៤. សសង្ខារបរិនិព្វាយី បានដល់ព្រះអនាគាមី អ្នកបដិសន្ធិក្នុងសុទ្ធាវាសភូមិណាមួយហើយសម្រេចព្រះអរហត្តបានដោយលំបាក ចាំបាច់ត្រូវព្យាយាមច្រើន ទើបបរិនិព្វានក្នុងទីនោះ។

៥. ឧទ្ធំសោតោ អកនិដ្ឋគាមី បានដល់ព្រះអនាគាមី អ្នកបដិសន្ធិតាំងពីសុទ្ធាវាសភូមិខាងក្រោមណាមួយ គឺអវិហាភូមិ (មានអាយុ១០០០ មហាកប្ប) ចុតិហើយកើតក្នុងអតប្បាភូមិ (មានអាយុ ២០០០ មហាកប្ប) ចុតិហើយកើតក្នុងសុទស្សាភូមិ (មានអាយុ៤០០០ មហាកប្ប) ចុតិហើយកើតក្នុងសុទស្សីភូមិ (មានអាយុ ៨០០០ មហាកប្ប) ចុតិហើយកើតក្នុងអកនិដ្ឋាភូមិ (មានអាយុ ១៦០០០មហាកប្ប) ទើបបរិនិព្វាន។

# ព្រះអរហន្ត ២ប្រភេទ

១. ព្រះអរហន្តដែលសម្រេចដោយ បញ្ញាវិមុត្តិ

២. ព្រះអរហន្តដែលសម្រេចដោយ ចេតោវិមុត្តិ

ព្រះអរហន្តអ្នកបញ្ញាវិមុត្តិ មិនមែនជាឈានលាភី (មិនសម្រេចឈាន) ចំណែកព្រះអរហន្តអ្នកចេតោវិមុត្តិ ជាឈានលាភី ខ្លះបានវិជ្ជា៣គឺ បុព្វេនិវាសានុស្សតិញ្ញាណ ចុតូបបាតញ្ញាណ និងអាសវក្ខយញ្ញាណ ខ្លះបានអភិញ្ញា៦ គឺឥទ្ធិវិធ (សម្តែងឫទ្ធិបាន) ទិព្វសោត (ត្រចៀកដូចជាទិព្វ) ចេតោបរិយញ្ញាណ (កំណត់ដឹងចិត្តអ្នកដទៃបាន) និងវិជ្ជា៣ជាគម្រប់៦។ ម្យ៉ាងទៀតលោកដែលបានបដិសម្ភិទា (បញ្ញាបែកព្រម) ៤ គឺ អត្ថបដិសម្ភិទា (បញ្ញាបែកព្រមក្នុងអត្ថ) ធម្មបដិសម្ភិទា (បញ្ញាបែកព្រមក្នុងធម៌) និរុត្តិបដិសម្ភិទា (បញ្ញាបែកព្រមក្នុងសព្វពាក្យបញ្ញត្តិភាសា) និងបដិភាណបដិសម្ភិទា (បញ្ញាបែកព្រមក្នុងញាណ) ហៅថា បដិសម្ភិទប្បត្តោ។ ចំណែកឯលោកដែលមិនបានបដិសម្ភិទា៤ ហៅថា អប្បដិសម្ភិទប្បត្តោ។



# បច្ចវេក្ខណវិថី ១៩ វារៈ

មើលវីដេអូ ភាគទី ៥៥

កាលព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ តែងមានការដឹងប្រាកដដោយខ្លួនឯង ដូចពាក្យនៅក្នុងព្រះធម្មគុណពោលថា សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថា នឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង។ បច្ចវេក្ខណវិថីទាំងនោះ ប្រព្រឹត្តទៅដូច្នេះ៖

ស្កេនដើម្បីមើលមេរៀន
San Sochea Official

# បច្ចវេក្ខណវិថីរបស់សោតាបន្នបុគ្គល មាន ៥ វិថី






# បច្ចវេក្ខណវិថីរបស់សកទាគាមិបុគ្គល មាន ៥ វិថី



# បច្ចវេក្ខណវិថីរបស់អនាគាមិបុគ្គល មាន ៥ វិថី






# បច្ចវេក្ខណវិថីរបស់ព្រះអរហន្ត មាន ៤ វិថី



ចំពោះព្រះអរិយបុគ្គលដែលមិនឈ្លាសក្នុងកិលេសបញ្ញត្តិ លោកមិន ពិចារណាកិលេសដែលលះ និងកិលេសដែលនៅសល់ទេ លោកពិចារណាចំពោះតែ មគ្គ ផល និងនិព្វាន ប៉ុណ្ណោះ ដូច្នេះ បច្ចវេក្ខណវិថីរបស់លោក មានត្រឹមតែ ១២ វារៈ ។



## ខ. លោកុត្តរវិបាកចិត្ត ៤ ដួង

(Resultant Supramundane Consciousness)

សោតាបត្តិផលចិត្តំ សកទាគាមិផលចិត្តំ
អនាគាមិផលចិត្តំ អរហត្តផលចិត្តញ្ចេតិ
ឥមានិ ចត្តារិបិ លោកុត្តរវិបាកចិត្តានិ នាម ។

ប្រែថា៖

- សោតាបត្តិផលចិត្ត ១ Sotāpatti Fruit-consciousness
- សកទាគាមិផលចិត្ត ១ Sakadāgāmi Fruit-consciousness
- អនាគាមិផលចិត្ត ១ Anāgāmi Fruit-consciousness
- អរហត្តផលចិត្ត ១ Arahatta Fruit-consciousness.

ចិត្តទាំង ៤ ដួងនេះឈ្មោះថា លោកុត្តរវិបាកចិត្ត ។

**សួរថា** ហេតុអ្វីលោកុត្តរវិបាកក៏មាន ៤ ដួងដូចមគ្គចិត្តដែរ?

**ឆ្លើយថា** ព្រោះជាផលរបស់លោកុត្តរកុសលនោះៗ គឺអាស្រ័យមគ្គចិត្ត ជាហេតុ ជាបច្ច័យឱ្យកើតឡើង ព្រោះហេតុនោះទើបហៅថា ផលចិត្ត។ ផលចិត្តនេះមិនមានតួនាទីប្រហារនូវកិលេសណាមួយដូចជាមគ្គចិត្តទេ ប៉ុន្តែមានព្រះនិព្វានជាអារម្មណ៍ និងប្រកបព្រមដោយពោធិបក្ខិយធម៌ទាំង៣៧ប្រការដូចគ្នា។

516

- ក្នុងលោកុត្តរចិត្ត មិនមានកិរិយាចិត្តទេ ព្រោះមគ្គចិត្តកើតឡើងមួយខណៈក៏ប្រហារកិលេសដាច់ជាសមុច្ឆេទ ដូច្នេះមគ្គចិត្តកើតឡើងប្រហារកិលេសបានហើយនឹងមិនកើតឡើងជាលើកទី ២ ទៀតឡើយ។
  ចំណែកផលចិត្តកើតបានច្រើនដង គឺដែលជាផលសមាបត្តិ មានព្រះនិព្វានជាអារម្មណ៍ក៏ដើម្បីការនៅជាសុខក្នុងភពបច្ចុប្បន្ន ព្រោះហេតុនេះទើបលោកុត្តរចិត្ត ដែលជាកិរិយាមិនមាន។
- លោកុត្តរចិត្ត ៨ ដួងដោយសង្ខេបគឺ មគ្គចិត្ត ៤ ដួង និង ផលចិត្ត ៤ ដួងនេះ។

## លោកុត្តរចិត្តទាំង ៨ ដួង មួយដួងៗ មានចេតសិកកើតរួម ៣៦ គឺ៖

- អញ្ញសមានាចេតសិក ១៣
- សោភណសាធារណចេតសិក ១៩
- វិរតិចេតសិក ៣
- បញ្ញាចេតសិក ១ (វៀរ អប្បមញ្ញា ២)






# លោកុត្តរចិត្តបែបពិស្ដារ

លោកុត្តរចិត្តបែបពិស្ដារ ៤០ ដួង ដោយសម្ដែងតាមអង្គឈាន គឺថា ចែកលោកុត្តរចិត្តដួងនីមួយៗ ជា ៥ យ៉ាង ដោយតាមសេចក្ដី ខុសគ្នា នៃការប្រកបជាមួយអង្គឈាន គឺ៖

- បឋមជ្ឈានមានអង្គ ៥ សោតាបត្តិមគ្គចិត្ត មាន ១
- ទុតិយជ្ឈានមានអង្គ ៤ សោតាបត្តិមគ្គចិត្ត មាន ១
- តតិយជ្ឈានមានអង្គ ៣ សោតាបត្តិមគ្គចិត្ត មាន ១
- ចតុត្ថជ្ឈានមានអង្គ ២ សោតាបត្តិមគ្គចិត្ត មាន ១
- បញ្ចមជ្ឈានមានអង្គ ២ សោតាបត្តិមគ្គចិត្ត មាន ១

ដូច្នេះ សោតាបត្តិមគ្គចិត្ត មាន ៥ សោតាបត្តិផលចិត្ត ក៏មាន ៥ សកទាគាមិមគ្គចិត្តមាន ៥ សកទាគាមិផលចិត្ត មាន ៥ អនាគាមិមគ្គចិត្តមាន ៥ អនាគាមិផលចិត្តមាន ៥ អរហត្តមគ្គចិត្ត មាន ៥ អរហត្តផលចិត្ត ក៏មាន ៥ ដូចគ្នា រួមជាមគ្គចិត្ត ២០ដួង និង ផលចិត្ត ២០ ដួង បូករួមបញ្ចូលគ្នា ត្រូវជាលោកុត្តរចិត្ត ៤០ ដួងដោយពិស្តារ។



## លោកុត្តរកុសលចិត្ត ៤ ដួង ឬ ២០ ដួង

**១- សោតាបត្តិមគ្គចិត្ត ៥**
- បឋមជ្ឈានសោតាបត្តិមគ្គចិត្ត ១
- ទុតិយជ្ឈានសោតាបត្តិមគ្គចិត្ត ១
- តតិយជ្ឈានសោតាបត្តិមគ្គចិត្ត ១
- ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្ត ១
- បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្ត ១

**២- សកទាគាមិមគ្គចិត្ត ៥**
- បឋមជ្ឈានសកទាគាមិមគ្គចិត្ត ១
- ទុតិយជ្ឈានសកទាគាមិមគ្គចិត្ត ១
- តតិយជ្ឈានសកទាគាមិមគ្គចិត្ត ១
- ចតុត្ថជ្ឈានសកទាគាមិមគ្គចិត្ត ១
- បញ្ចមជ្ឈានសកទាគាមិមគ្គចិត្ត ១

**៣- អនាគាមិមគ្គចិត្ត ៥**
- បឋមជ្ឈានអនាគាមិមគ្គចិត្ត ១
- ទុតិយជ្ឈានអនាគាមិមគ្គចិត្ត ១
- តតិយជ្ឈានអនាគាមិមគ្គចិត្ត ១
- ចតុត្ថជ្ឈានអនាគាមិមគ្គចិត្ត ១
- បញ្ចមជ្ឈានអនាគាមិមគ្គចិត្ត ១

**៤- អរហត្តមគ្គចិត្ត ៥**
- បឋមជ្ឈានអរហត្តមគ្គចិត្ត ១
- ទុតិយជ្ឈានអរហត្តមគ្គចិត្ត ១
- តតិយជ្ឈានអរហត្តមគ្គចិត្ត ១
- ចតុត្ថជ្ឈានអរហត្តមគ្គចិត្ត ១
- បញ្ចមជ្ឈានអរហត្តមគ្គចិត្ត ១

# លោកុត្តរវិបាកចិត្ត ៤ ដួង ឬ ២០ ដួង

**១- សោតាបត្តិផលចិត្ត ៥**

- បឋមជ្ឈានសោតាបត្តិផលចិត្ត ១
- ទុតិយជ្ឈានសោតាបត្តិផលចិត្ត ១
- តតិយជ្ឈានសោតាបត្តិផលចិត្ត ១
- ចតុត្ថជ្ឈានសោតាបត្តិផលចិត្ត ១
- បញ្ចមជ្ឈានសោតាបត្តិផលចិត្ត ១

**២- សកទាគាមិផលចិត្ត ៥**

- បឋមជ្ឈានសកទាគាមិផលចិត្ត ១
- ទុតិយជ្ឈានសកទាគាមិផលចិត្ត ១
- តតិយជ្ឈានសកទាគាមិផលចិត្ត ១
- ចតុត្ថជ្ឈានសកទាគាមិផលចិត្ត ១
- បញ្ចមជ្ឈានសកទាគាមិផលចិត្ត ១

**៣- អនាគាមិផលចិត្ត ៥**

- បឋមជ្ឈានអនាគាមិផលចិត្ត ១
- ទុតិយជ្ឈានអនាគាមិផលចិត្ត ១
- តតិយជ្ឈានអនាគាមិផលចិត្ត ១
- ចតុត្ថជ្ឈានអនាគាមិផលចិត្ត ១
- បញ្ចមជ្ឈានអនាគាមិផលចិត្ត ១

**៤- អរហត្តផលចិត្ត ៥**

- បឋមជ្ឈានអរហត្តផលចិត្ត ១
- ទុតិយជ្ឈានអរហត្តផលចិត្ត ១
- តតិយជ្ឈានអរហត្តផលចិត្ត ១
- ចតុត្ថជ្ឈានអរហត្តផលចិត្ត ១
- បញ្ចមជ្ឈានអរហត្តផលចិត្ត ១



## ចេតសិកសម្បយុត្តជាមួយ លោកុត្តរឈានចិត្តទាំង ៤០ ដួង មាន ៥ ន័យ គឺ ៖

## ន័យទី ១

## លោកុត្តរបឋមជ្ឈានចិត្ត ៨ ដួង មានចេតសិកកើតរួម ៣៦ គឺ ៖

- អញ្ញសមានាចេតសិក ១៣
- សោភណសាធារណចេតសិក ១៩
- វិរតិចេតសិក ៣
- បញ្ញាចេតសិក ១

(វៀរ អប្បមញ្ញា ២)



## ន័យទី ២
## លោកុត្តរទុតិយជ្ឈានចិត្ត ៨ ដួង
## មានចេតសិកកើតរួម ៣៥ គឺ ៖

- អញ្ញសមានាចេតសិក ១២
  (វៀរ វិតក្កៈ)
- សោភណសាធារណចេតសិក ១៩
- វិរតិចេតសិក ៣
- បញ្ញាចេតសិក ១
  (វៀរ អប្បមញ្ញា ២)






## ័យទី ៣
## លាកុត្តរតតិយជ្ឈានចិត្ត ៨ ដួង
## នចេតសិកកើតរួម ៣៤ គឺ ៖

អញ្ញសមានាចេតសិក ១១
(វៀរ វិតក្កៈ និង វិចារៈ)
សោភណសាធារណចេតសិក ១៩
វិរតិចេតសិក ៣
បញ្ញាចេតសិក ១
(វៀរ អប្បមញ្ញា ២)



## ន័យទី ៤
## លោកុត្តរចតុត្ថជ្ឈានចិត្ត ៨ ដួង
## មានចេតសិកកើតរួម ៣៣ គឺ ៖

- អញ្ញសមានាចេតសិក ១០
  (វៀរ វិតក្កៈ វិចារៈ និង បីតិ)
- សោភណសាធារណចេតសិក ១៩
- វិរតិចេតសិក ៣
- បញ្ញាចេតសិក ១
  (វៀរ អប្បមញ្ញា ២)






## ន័យទី ៥
## លោកុត្តរបញ្ចមជ្ឈានចិត្ត ៨ ដួង
## មានចេតសិកកើតរួម ៣៣ គឺ ៖

- អញ្ញសមានាចេតសិក ១០
  (វៀរ វិតក្កៈ វិចារៈ និង បីតិ)
- សោភណសាធារណចេតសិក ១៩
- វិរតិចេតសិក ៣
- បញ្ញាចេតសិក ១
  (វៀរ អប្បមញ្ញា ២)



មើលវីដេអូ ភាគទី ៥៦

# ការចែកលោកុត្តរចិត្ត ៨ ដួងដោយន័យផ្សេងៗ

| | |
|---|---|
| ១ - ដោយជាតិ | ជាកុសលជាតិ ៤ ដួង ជាវិបាក ៤ ដួង។ |
| ២ - ដោយភូមិ | ជាលោកុត្តរភូមិទាំង ៨ ដួង។ |
| ៣ - ដោយវេទនា | ជាសោមនស្សវេទនា និងឧបេក្ខាវេទនា។ |
| ៤ - ដោយហេតុ | ជានហេតុ និង ជាតិហេតុកចិត្ត។ |
| ៥ - ដោយសម្បយុត្ត | ជាញាណសម្បយុត្តទាំង ៨ ដួង។ |
| ៦ - ដោយសង្ខារ | ជាសសង្ខារិកចិត្តទាំង ៨ ដួង។ |
| ៧ - ដោយសោភណៈ | ជាសោភណចិត្ត។ |
| ៨ - ដោយឈាន | ជាឈានចិត្ត។ |

ស្កេនដើម្បីមើលមេរៀន

San Sochea Official



| | |
|---|---|
| ៩ - ដោយលោកិយ | ជាលោកុត្តរចិត្ត។ |
| ១០ - ដោយកិច្ច | ធ្វើជវនកិច្ច ។ |
| ១១ - ដោយអារម្មណ៍ | មានព្រះនិព្វានជាអារម្មណ៍ ជាធម្មារម្មណ៍។ |
| ១២ - ដោយទ្វារ | ជាមនោទ្វារ។ |
| ១៣ - ដោយវត្ថុ | វៀរសោតាបត្តិមគ្គចិត្ត ១ ដួង ដែលអាស្រ័យ ហទយវត្ថុ។ លោកុត្តរចិត្តសល់ ៧ ដួងទៀតអាស្រ័យហទយវត្ថុក្នុងបញ្ចវោការភព និង មិនអាស្រ័យហទយវត្ថុក្នុងចតុវោការភព។ |
| ១៤ - ដោយវិញ្ញាណធាតុ | ជាមនោវិញ្ញាណធាតុ។ |

# ការចែកចិត្ត ៨៩ ដួង ឬ ១២១ ដួងដោយន័យផ្សេងៗ

## ១ - ដោយជាតិ

- អកុសលចិត្ត ១២ ដួង ជាអកុសលជាតិ
- កុសលចិត្ត ២១ ដួង ឬ ៣៧ ដួង ជាកុសលជាតិ
- វិបាកចិត្ត ៣៦ដួង ឬ ៥២ ដួង ជាវិបាកជាតិ
- កិរិយាចិត្ត ២០ ដួង ជាកិរិយាជាតិ ។



## ២ - ដោយភូមិ

- កាមាវចរចិត្ត ៥៤ ដួង ជាកាមភូមិ
- រូបាវចរចិត្ត១៥ ដួង ជារូបាវចរភូមិ
- អរូបាវចរចិត្ត ១២ ដួង ជាអរូបាវចរភូមិ
- លោកុត្តរចិត្ត ៨ ដួង ឬ ៤០ ដួង ជាលោកុត្តរភូមិ

## ៣ - ដោយវេទនា

- សុខសហគតចិត្ត ១ ដួង ជាសុខវេទនា។
- ទុក្ខសហគតចិត្ត ១ ដួង ជាទុក្ខវេទនា។
- សោមនស្សសហគតចិត្ត ៦២ ដួង ជាសោមនស្សវេទនា។
- ឧបេក្ខាសហគតចិត្ត ៥៥ ដួង ជាឧបេក្ខាវេទនា។
- ទោមនស្សសហគតចិត្ត ២ ដួង ជា ទោមនស្សវេទនា។

## ៤ - ដោយហេតុ

- ចិត្ត ៨៩ ដួង ឬ ១២១ ដួង ជានហេតុ
- ចិត្តមិនមានហេតុប្រកប ១៨ ដួង ជា អហេតុកចិត្ត
- ចិត្តដែលមានហេតុប្រកប ៧១ ឬ ១០៣ ដួង ជាសហេតុកចិត្ត។

## ៥ - ដោយសម្បយុត្ត

- ជាញាណសម្បយុត្ត ៧៩ ដួង
- ជាញាណវិប្បយុត្ត ១២ ដួង
- ជាទិដ្ឋិគតសម្បយុត្ត ៤ ដួង
- ជាទិដ្ឋិគតវិប្បយុត្ត ៤ ដួង
- ជាបដិឃសម្បយុត្ត២ ដួង
- ជាវិចិកិច្ឆាសម្បយុត្ត ១ ដួង
- ឧទ្ធច្ចសម្បយុត្ត ១ ដួង
- អហេតុកចិត្ត ១៨ ដួង ចាត់ជាវិប្បយុត្តចិត្ត។

532

## ៦ - ដោយសង្ខារ

- ជាអសង្ខារិក ៣៧ ដួង
- ជាសសង្ខារិក ៥២ ដួង ឬ ៨៤ ដួង។

## ៧ - ដោយសោភណៈ

- ជាអសោភណចិត្ត ៣០ ដួង
- ជាសោភណចិត្ត ៥៩ ឬ ៩១ ដួង។

## ៨ - ដោយឈាន

- ជាកាមាវចរចិត្ត ៥៤ ដួង ជាអឈានចិត្ត
- ចិត្តនៅសល់ ៦៧ ដួងជាឈានចិត្ត។

## ៩ - ដោយលោកិយ

- ចិត្ត ៨១ ដួង ជាលោកិយចិត្ត
- ចិត្ត ៨ ឬ ៤០ ដួង ជាលោកុត្តរចិត្ត។

| | |
|---|---|
| ១០ - ដោយកិច្ច | ចិត្ត ៨៩ ដួង ឬ ១២១ ដួង ធ្វើកិច្ចបាន ១៤ កិច្ច។ |
| ១១ - ដោយអារម្មណ៍ | ចិត្ត ៨៩ ដួង ឬ ១២១ ដួងមានអារម្មណ៍ ៦។ |
| ១២ - ដោយទ្វារ | ចិត្ត ៨៩ ដួង ឬ ១២១ ដួង អាស្រ័យទ្វារ ៦ និង ទ្វារវិមុត្តិ (កាលធ្វើ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច)។ |
| ១៣ - ដោយវត្ថុ | ចិត្ត ១១៧ ដួង កើតត្រង់វត្ថុ ៦ ចិត្ត ៤ ដួង មិនអាស្រ័យវត្ថុ។ |
| ១៤ - ដោយវិញ្ញាណធាតុ | ចិត្ត៨៩ ដួង ឬ ១២១ ដួង ជាវិញ្ញាណធាតុ ៧។ |



មើលវីដេអូ ភាគទី ៥៧

## ពាក្យគួរយល់ដឹង

សម្បយុត្ត ប្រែថា ប្រកបព្រមហើយ បានដល់ ចិត្តប្រកបជាមួយនឹងចេតសិក ដូចពាក្យថា ទិដ្ឋិគតសម្បយុត្តំ ប្រែថា ចិត្តប្រកបដោយការ យល់ខុស ញាណសម្បយុត្តំ ចិត្តប្រកបដោយបញ្ញា ជាដើម ។

ស្កេនដើម្បីមើលមេរៀន
San Sochea Official

**សម្បយោគ** ប្រែថា ការប្រកបរួមគ្នា បានដល់ការប្រកបរួមគ្នា របស់ចេតសិកទាំងឡាយ ដែលមិនប្រាសចាកអំពីចិត្ត គឺថា តែងតែកើតរួមជាមួយនឹងចិត្ត តាមសមគួរ។

**សង្គហៈ** ប្រែថា ការរួបរួម ឬការសង្គ្រោះ ក្នុងទីនេះ លោកសំដៅយកការរាប់ចំនួនចេតសិកក្នុងចិត្ត ៨៩ ឬ ១២១ ដួង ។



## សម្បយោគដោយពិស្តារ មាន ១៦ ន័យ គឺ ៖

### អញ្ញសមានាចេតសិក តាំងពីន័យទី ១ - ៧

**ន័យទី ១** បានដល់ សព្វចិត្តសាធារណចេតសិក ៧ មានផស្សៈជាដើម ប្រកបជាមួយចិត្តបានទាំងអស់

| | | | |
|---|---|---|---|
| ន័យទី ២ | វិតក្កៈ | ប្រកបជាមួយចិត្តបាន ៥៥ | ប្រកបមិនបាន ៦៦ |
| ន័យទី ៣ | វិចារៈ | ប្រកបជាមួយចិត្តបាន ៦៦ | ប្រកបមិនបាន ៥៥ |
| ន័យទី ៤ | អធិមោក្ខៈ | ប្រកបជាមួយចិត្តបាន ៧៨ | ប្រកបមិនបាន ១១ |
| ន័យទី ៥ | វីរិយៈ | ប្រកបជាមួយចិត្តបាន ៧៣ | ប្រកបមិនបាន ១៦ |
| ន័យទី ៦ | បីតិ | ប្រកបជាមួយចិត្តបាន ៥១ | ប្រកបមិនបាន ៧០ |
| ន័យទី ៧ | ឆន្ទៈ | ប្រកបជាមួយចិត្តបាន ៦៩ ឬ ១០១ | ប្រកបមិនបាន ២០ |

## អកុសលចេតសិក តាំងតែពីន័យទី ៨ - ១២ គឺ ៖

| | | |
|---|---|---|
| ន័យទី ៨ | មោចតុក្កៈ ៤ | ប្រកបជាមួយអកុសលចិត្តបាន ១២ |
| ន័យទី ៩ | លោតិកៈ ៣ | ប្រកបជាមួយលោភចិត្តបាន ៨ |
| ន័យទី ១០ | ទោចតុក្កៈ ៤ | ប្រកបជាមួយទោសមូលចិត្តបាន ២ |
| ន័យទី ១១ | ថីទុកៈ ២ | ប្រកបជាមួយអកុសលចិត្តសសង្ខារិក ៥ |
| ន័យទី ១២ | វិចិកិច្ឆា | ប្រកបជាមួយវិចិកិច្ឆាសម្បយុត្តចិត្តបាន ១ |



## សោភណចេតសិក តាំងតែពីន័យទី ១៣ ដល់ ១៦ គឺ ៖

ន័យទី ១៣ សោភណសាធារណចេតសិក ១៩ ប្រកបជាមួយសោភណចិត្តបាន ៥៩ ឬ ៩១ ដួង

ន័យទី ១៤ វិរតិចេតសិក ៣ ប្រកបជាមួយសោភណចិត្តបាន ១៦ ឬ ៤៨ ដួង

ន័យទី ១៥ អប្បមញ្ញាចេតសិក ២ ប្រកបជាមួយសោភណចិត្តបាន ២៨ ដួង

ន័យទី ១៦ បញ្ញាចេតសិក ១ ប្រកបជាមួយសោភណចិត្តបាន ៤៧ ដួង ។

## អធិប្បាយសម្បយោគ ១៦ ន័យ ៖

ន័យទី ១ សព្វចិត្តសាធារណចេតសិក ៧ ប្រកបជាមួយចិត្តបានទាំងអស់នោះ មានសេចក្ដីច្បាស់ហើយ។

ន័យទី ២

វិតក្កចេតសិក ប្រកបជាមួយចិត្តបាន ៥៥ គឺ ៖

- អកុសលចិត្ត ១២
- អហេតុកចិត្ត ៨ (វៀរទ្វិបញ្ចវិញ្ញាណ)
- កាមាវចរសោភណចិត្ត ២៤
- បឋមជ្ឈានចិត្ត ១១

វិតក្កចេតសិក មិនប្រកបជាមួយចិត្ត ៦៦ គឺ ៖

- ទ្វិបញ្ចវិញ្ញាណ ១០
- ទុតិយជ្ឈានចិត្ត ១១
- តតិយជ្ឈានចិត្ត ១១
- ចតុត្ថជ្ឈានចិត្ត ១១
- បញ្ចមជ្ឈានចិត្ត ២៣



ន័យទី ៣ វិចារចេតសិក ប្រកបជាមួយចិត្តបាន ៦៦ គឺ ៖

- អកុសលចិត្ត ១២
- បឋមជ្ឈានចិត្ត ១១
- អហេតុកចិត្ត ៨
- ទុតិយជ្ឈានចិត្ត ១១
- កាមាវចរសោភណចិត្ត ២៤

វិចារចេតសិក មិនប្រកបជាមួយចិត្ត ៥៥ គឺ ៖

- ទ្វិបញ្ចវិញ្ញាណ ១០
- តតិយជ្ឈានចិត្ត ១១
- ចតុត្ថជ្ឈានចិត្ត ១១
- បញ្ចមជ្ឈានចិត្ត ២៣

**ន័យទី ៤** អធិមោក្ខចេតសិក ប្រកបជាមួយចិត្តបាន ៧៨ ឬ ១១០ គឺ៖

- អកុសលចិត្ត (វៀរវិចិកិច្ឆាចិត្ត) ១១
- អហេតុកចិត្ត ៨ (វៀរទ្វិបញ្ចវិញ្ញាណ)
- កាមាវចរសោភណចិត្ត ២៤
- មហគ្គតចិត្ត ២៧
- លោកុត្តរចិត្ត ៨ ឬ ៤០

អធិមោក្ខចេតសិក មិនប្រកបជាមួយចិត្ត ១១ គឺ ៖

- វិចិកិច្ឆាសម្បយុត្តចិត្ត ១
- ទ្វិបញ្ចវិញ្ញាណ ១០



**ន័យទ ៥** វីរិយចេតសិក ប្រកបជាមួយចិត្តបាន ៧៣ ឬ ១០៥ គឺ ៖

- អកុសលចិត្ត ១២
- កាមាវចរសោភណចិត្ត ២៤
- មនោទ្វារាវជ្ជនចិត្ត ១
- មហគ្គតចិត្ត ២៧
- ហសិតុប្បាទចិត្ត ១
- លោកុត្តរចិត្ត ៨ ឬ ៤០

វីរិយចេតសិក មិនប្រកបជាមួយចិត្ត ១៦ គឺ ៖ អហេតុកចិត្ត ១៦

**ន័យទី ៦** បីតិចេតសិក ប្រកបជាមួយចិត្តបាន ៥១ គឺ ៖

- សោមនស្សលោភមូលចិត្ត ៤
- សោមនស្សសន្តីរណចិត្ត ១
- សោមនស្សហសិតុប្បាទចិត្ត ១
- សោមនស្សកាមាវចរសោភណចិត្ត ១២
- បឋមជ្ឈានចិត្ត ១១
- ទុតិយជ្ឈានចិត្ត ១១
- តតិយជ្ឈានចិត្ត ១១

បីតិចេតសិក មិនប្រកបជាមួយចិត្ត ៧០ គឺ ៖

- ឧបេក្ខាលោភមូលចិត្ត ៤
- ទោសមូលចិត្ត ២
- មោហមូលចិត្ត ២
- ឧបេក្ខាអហេតុកៈ ១៤
- កាយវិញ្ញាណ ២
- ឧបេក្ខាកាមាវចរសោភណចិត្ត ១២
- ចតុត្ថជ្ឈានចិត្ត ១១
- បញ្ចមជ្ឈានចិត្ត ២៣



**ន័យទី ៧** ឆន្ទចេតសិក ប្រកបជាមួយចិត្តបាន ៦៩ ឬ ១០១ គឺ ៖

- លោភមូលចិត្ត ៨
- ទោសមូលចិត្ត ២
- កាមាវចរសោភណចិត្ត ២៤
- មហគ្គតចិត្ត ២៧
- លោកុត្តរចិត្ត ៨ ឬ ៤០

ឆន្ទចេតសិក មិនប្រកបជាមួយចិត្ត ២០ គឺ ៖

- មោហមូលចិត្ត ២
- អហេតុកចិត្ត ១៨

**ចំណាំ** ការដែលរាប់ចិត្តដោយសង្ខេប ឬដោយពិស្តារនោះ បើចេតសិកណាប្រកបជាមួយលោកុត្តរចិត្តទាំងអស់ ក៏រាប់ចិត្តនោះដោយសង្ខេប គឺ ៨៩ ដួង បើចេតសិកណា ប្រកបជាមួយលោកុត្តរចិត្តមិនបានទាំងអស់ទេ ក៏រាប់ចិត្តនោះដោយពិស្តារ គឺ ១២១ ដួង។

មួយទៀត វិតក្កៈនិងវិចារៈដែលប្រកបជាមួយលោកុត្តរចិត្ត ដូចបានពោលហើយនោះ ជាការរាប់លោកុត្តរចិត្តរបស់ព្រះអរិយបុគ្គលដែលបានឈាន បើវិតក្កៈ និងវិចារៈរបស់ព្រះអរិយបុគ្គលជាសុក្ខវិបស្សកៈ វិតក្កៈ និងវិចារៈនោះ តែងប្រកបជាមួយនឹងលោកុត្តរចិត្តបានទាំងអស់ (៨ដួង)។ ចំណែកបីតិចេតសិក បើលោកុត្តរចិត្តនោះ កើតព្រមនឹងសោមនស្សវេទនា បីតិតែងប្រកបបាន បើលោកុត្តរចិត្តនោះ កើតព្រមនឹងឧបេក្ខាវេទនា បីតិក៏មិនអាចប្រកបជាមួយបាន។



## អកុសលចេតសិក ១៤ ប្រកបជាមួយអកុសលចិត្ត ១២ តាំងពីន័យទី ៨ ដល់ ១២ ដូចតទៅនេះ គឺ ៖

| | | |
|---|---|---|
| ន័យទី ៨ | មោចតុក្កៈ | ប្រកបជាមួយអកុសលចិត្ត ១២ |
| ន័យទី ៩ | លោតិកៈ | ប្រកបជាមួយលោភមូលចិត្ត ៨ |
| ន័យទី ១០ | ទោចតុក្កៈ | ប្រកបជាមួយទោសមូលចិត្ត ២ |
| ន័យទី ១១ | ថីទុកៈ | ប្រកបនឹងអកុសលចិត្តសសង្ខារិក ៥ |
| ន័យទី ១២ | វិចិកិច្ឆា | ប្រកបនឹងវិចិកិច្ឆាសម្បយុត្តចិត្ត ១ |

មើលវីដេអូ ភាគទី ៥៨

## សោភណចេតសិក ២៥ ប្រកបជាមួយសោភណចិត្ត ៥៩ ឬ ៩១ តាំងពីន័យទី ១៣ ដល់ទី ១៦ រួម ៤ ន័យ ៖

**ន័យទី ១៣** សោភណសាធារណចេតសិក ១៩ មានសទ្ធាជាដើម ប្រកបបានទូទៅក្នុង សោភណចិត្ត ៥៩ ឬ ៩១ គឺ កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត២៧ លោកុត្តរចិត្ត ៨ ឬ ៤០ (គឺកើតនៅក្នុងសោភណចិត្តគ្រប់ដួង)។

ស្កេនដើម្បីមើលមេរៀន

San Sochea Official



**ន័យទី ១៤** វិរតិចេតសិក ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ប្រកបជាមួយសោភណចិត្តបាន ១៦ ឬ ៤៨ គឺមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៨ ឬ ៤០។

- វិរតិចេតសិក ៣ នេះ កើតក្នុងមហាកុសលចិត្ត ៨ រមែងមិនកើតព្រមគ្នាទាំង ៣ ទេ ព្រោះមានអារម្មណ៍ផ្សេងគ្នា តែកាលកើតក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ រមែងកើតបានព្រមគ្នាទាំង ៣ ព្រោះជាអង្គមគ្គ មានព្រះនិព្វានជាអារម្មណ៍តែមួយដូចគ្នា។
- វិរតិចេតសិក ៣ នេះ មិនកើតក្នុងមហាវិបាកចិត្ត ៨ មហាកិរិយាចិត្ត ៨ និងមហគ្គតចិត្ត ២៧ ទេ ព្រោះមហាវិបាកចិត្ត ៨ មិនមានវិរមិតព្វវត្ថុ (វត្ថុគប្បីវៀរ) និងព្រោះមហាកិរិយាចិត្ត ៨ ជាចិត្តរបស់ព្រះអរហន្ត ដែលលោកបានប្រហារទុច្ចរិតកម្មដោយសមុច្ឆេទប្បហានៈហើយ និងដែលមិនកើតក្នុងមហគ្គតចិត្ត ២៧ នោះ ព្រោះមហគ្គតចិត្ត ២៧ មានអារម្មណ៍ជាមហគ្គតៈ មិនមានវិរមិតព្វវត្ថុ។

នយ័ទី ១៥ អប្បមញ្ញាចេតសិក ២ គឺ ករុណានិងមុទិតាចេតសិក កើតក្នុងចិត្ត ២៨ គឺ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ រូបាវចរចិត្ត ១២ (វៀរបញ្ចមជ្ឈាន)។

➢ អប្បមញ្ញាចេតសិក ២ នេះ កេចិអាចារ្យពោលថា កើតក្នុងចិត្ត ២០ គឺ ៖ មហាកុសលសោមនស្សចិត្ត ៤ មហាកិរិយាសោមនស្សចិត្ត ៤ រូបាវចរចិត្ត ១២ ។
មិនកើតក្នុងមហាកុសលចិត្ត និងមហាកិរិយាចិត្តដែលជាឧបេក្ខាវេទនា ។



➢ អប្បមញ្ញាចេតសិក ២ នេះ មិនកើតក្នុងមហាវិបាកចិត្ត ៨ ក្នុងរូបាវចរ-បញ្ចមជ្ឈានចិត្ត ៣ ក្នុងអរូបាវចរចិត្ត ១២ និងលោកុត្តរចិត្ត ៨ ឬ ៤០ នោះ ព្រោះមហាវិបាកចិត្ត ៨ នឹងកើតឡើងបាន ក៏ត្រូវអាស្រ័យកាមារម្មណ៍ ដែលជាអារម្មណ៍បរមត្ថ ចំណែកអប្បមញ្ញាចេតសិក មានទុក្ខិតសត្តបញ្ញត្តិ និងសុខិតសត្តបញ្ញត្តិជាអារម្មណ៍ ដែលមិនប្រកបជាមួយនឹងរូបាវចរបញ្ចមជ្ឈានចិត្ត ៣ ព្រោះរូបាវចរបញ្ចមជ្ឈានចិត្ត ៣ មានមជ្ឈត្តសត្តបញ្ញត្តិជាអារម្មណ៍ ដែលមិនកើតក្នុងអរូបាវចរ ១២ ព្រោះអរូបាវចរទាំងនេះ មានអារម្មណ៍ប្រណីតជាង និងមិនកើតក្នុងលោកុត្តរ ៨ ឬ ៤០ នោះ ព្រោះលោកុត្តរចិត្តមាននិព្វានជាអារម្មណ៍ ។

ន័យទី ១៦ បញ្ញាចេតសិក ១ កើតក្នុងចិត្តបាន ៤៧ ឬ ៧៩ គឺ កាមាវចរសោភណញាណសម្បយុត្តចិត្ត ១២ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ ឬ ៤០



## អនិយតយោគីចេតសិក និង និយតយោគីចេតសិក

១ - **អនិយតយោគីចេតសិក** ជាចេតសិកដែលកើតក្នុងចិត្តបានមិនប្រាកដ គឺគ្រាខ្លះក៏ប្រកប គ្រាខ្លះក៏មិនប្រកប ក្នុងខណៈដែលប្រកបជាមួយចិត្ត មិនប្រកបព្រមគ្នាខ្លះ ប្រកបព្រមគ្នាខ្លះ បានដល់ ចេតសិក ១១ គឺ មានៈ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ ថីនៈ មិទ្ធៈ លោកិយវិរតិ ៣ និងអប្បមញ្ញា ២។

- ចេតសិក ១១ នេះ ចែកចេញជា ៣ ប្រភេទ គឺ៖

  ក - នានាកទាចិចេតសិក មាន ៨

  ខ - កទាចិចេតសិកមាន ១

  គ - សហាកទាចិចេតសិក មាន ២

## ក - នានាកទាចិចេតសិក

❖ ចេតសិកទាំង ៨ នេះ គឺ៖

- ទោចតុក្កៈ ៣ គឺ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ (វៀរទោសៈ)
- លោកិយវិរតិ ៣ គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ
- អប្បមញ្ញា ២ គឺ ករុណា មុទិតា

ជាចេតសិកប្រកបជាមួយចិត្តមិនបានប្រាកដទេ គឺ គ្រាខ្លះក៏ប្រកប គ្រាខ្លះក៏មិនប្រកប កាលប្រកបក្នុងចិត្ត (ចេតសិក ៨ នេះ) ក៏ប្រកបម្តងមួយៗ ប៉ុណ្ណោះ មិនប្រកបព្រមនឹងចេតសិក ៧ ទៀតឡើយ ព្រោះដូច្នោះ ទើបហៅថា នានាកទាចិចេតសិក ។



## ខ - កទាចិចេតសិក

មានចេតសិក កាលកើតឡើង រមែងប្រកបជាមួយនឹងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ណាមួយ ប៉ុន្តែគ្រាខ្លះក៏មិនប្រកប បើមានសេចក្តីសម្គាល់ថា ខ្លួនមាន ឬមានសេចក្តីប្រកាន់ថា យើងល្អជាងគេជាដើម មានចេតសិក នេះក៏កើតឡើងរួមជាមួយលោភមូលចិត្ត ៤ នោះ ដែលមិនប្រកបជាមួយនឹងសេចក្តីឃើញខុសទេ ចេតសិកនេះ ទើបចាត់ទុកនៅក្នុងប្រភេទដែលមិនប្រាកដ ព្រោះហេតុដូច្នោះ ទើបលោកហៅថា កទាចិចេតសិក។

## គ - សហកទាចិចេតសិក

ថីនៈ និងមិទ្ធចេតសិក ទាំង ២ នេះ កើតរួមជាមួយគ្នាជានិច្ច មិនប្រាសចាកគ្នា តែក៏ចាត់ចូលនៅក្នុងប្រភេទចេតសិកដែលមិនប្រាកដដែរ ព្រោះគ្រាខ្លះក៏ប្រកបជាមួយចិត្ត គ្រាខ្លះក៏មិនប្រកប បើចិត្តជាអសង្ខារិក ជាចិត្តមានកម្លាំង ថីនៈ និងមិទ្ធៈ ក៏មិនចូលទៅប្រកប បើខណៈចិត្តនោះជាសសង្ខារិក ជាចិត្តមិនមានកម្លាំង ក្នុងគ្រាខ្លះចេតសិកទាំង ២ នេះ រមែងចូលទៅប្រកបព្រមគ្នាទាំង ២ ចេតសិក ហើយកើតតែក្នុងអកុសលចិត្តប៉ុណ្ណោះ ដូច្នេះទើបលោកហៅថា សហកទាចិចេតសិក។



២ - និយតយោគីចេតសិក បានដល់ចេតសិក ដែលប្រកបជាមួយនឹងចិត្ត បានពិតប្រាកដ បានដល់ ចេតសិក ៤១ គឺ ៖

ក - សព្វចិត្តសាធារណចេតសិក ៧ ក្នុងវេលាណាចិត្ត ៨៩ ឬ ១២១ កើតឡើង វេលានោះ សព្វចិត្តសាធារណចេតសិក ៧ រមែងកើតរួមជាមួយជានិច្ច។

ខ - បកិណ្ណកចេតសិក ៦ ក្នុងវេលាណាចិត្ត ៥៥ ចិត្ត ៦៦ ចិត្ត ៧៨ ឬ១១០ ចិត្ត ៧៣ឬ១០៥ ចិត្ត ៥១ ចិត្ត ៦៩ឬ១០១ កើតឡើង វេលានោះ បកិណ្ណកចេតសិកទាំង ៦ នេះ គឺ វិតក្កៈ វិចារៈ អធិមោក្ខៈ វីរិយៈ បីតិ ឆន្ទៈ ក៏កើតរួមជាមួយចិត្តនោះៗ តាមលំដាប់ជានិច្ច។

គ - មោចតុក្កចេតសិក ៤ ក្នុងវេលាណា អកុសលចិត្ត ១២ កើតឡើង វេលានោះ មោចតុក្កចេតសិក គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ រមែងកើតជាមួយចិត្តនោះដោយប្រាកដ។

ឃ - លោភចេតសិក ១ វេលាណា លោភមូលចិត្ត ៨ កើតឡើង វេលានោះ លោភចេតសិក រមែងកើតជាមួយលោភមូលចិត្ត ដោយប្រាកដជានិច្ច។

ង - ទិដ្ឋិចេតសិក ១ វេលាណា ទិដ្ឋិគតសម្បយុត្តចិត្ត ៤ កើតឡើង វេលានោះ ទិដ្ឋិចេតសិក រមែងកើតជាមួយចិត្តនោះដោយពិត។



ច - ទោសចេតសិក ១ វេលាណា ទោសមូលចិត្ត កើតឡើង វេលានោះ ទោសចេតសិក រមែងចូលទៅប្រកបជាមួយចិត្តនោះ ដោយប្រាកដជានិច្ច។

ឆ - វិចិកិច្ឆាចេតសិក វេលាណា វិចិកិច្ឆាសម្បយុត្តចិត្ត កើតឡើង វេលានោះ វិចិកិច្ឆាចេតសិក រមែងចូលទៅប្រកបជាមួយចិត្តនោះ ដោយប្រាកដជានិច្ច។

ជ - សោភណសាធារណចេតសិក ១៩ វេលាណា សោភណចិត្ត ៥៩ ឬ ៩១ កើតឡើង វេលានោះ សោភណសាធារណចេតសិក ១៩ រមែងកើតជាមួយសោភណចិត្តនោះ គ្រប់ដួងដោយប្រាកដជានិច្ច។

ឈ - បញ្ញាចេតសិក ១ វេលាណា ចិត្តសម្បយុត្តដោយញាណ ៤៧ ឬ ៧៩ កើតឡើង វេលានោះ បញ្ញាចេតសិក រមែងកើតរួមជាមួយចិត្តនោះ ដោយប្រាកដជានិច្ច។

ញ - វិរតិចេតសិក ៣ កាលកើតក្នុងលោកុត្តរចិត្ត ៨ ឬ ៤០ ក៏ជានិយតយោគីចេតសិក តែហៅថា និយតឯកតោចេតសិក ព្រោះជាអង្គមគ្គ។

# ចប់



MP Printing House
រោងពុម្ព ម៉ៅ ផុន
MAO PHON PRINTING HOUSE
Tel: 078 777 800 / 088 8888 908 / 012 990 524
រោងពុម្ព ម៉ៅ ផុន phonmao@yahoo.com

# តារាងចិត្ត ៨៩ ឬ ១២១ ដួង



# ចេតសិក ៥២

### អញ្ញសមានា ១៣

១- ផស្សៈ
២- វេទនា
៣- សញ្ញា
៤- ចេតនា
៥- ឯកគ្គតា
៦- ជីវិតិន្ទ្រិយ
៧- មនសិការៈ
៨- វិតក្កៈ
៩- វិចារៈ
១០- អធិមោក្ខៈ
១១- វីរិយៈ
១២- បីតិ
១៣- ឆន្ទៈ

### អកុសលចេតសិក ១៤

១- មោហៈ
២- អហិរិកៈ
៣- អនោត្តប្បៈ
៤- ឧទ្ធច្ចៈ
៥- លោភៈ
៦- ទិដ្ឋិ
៧- មានៈ
៨- ទោសៈ
៩- ឥស្សា
១០- មច្ឆរិយៈ
១១- កុក្កុច្ចៈ
១២- ថីនៈ
១៣- មិទ្ធៈ
១៤- វិចិកិច្ឆា

### សោភណចេតសិក ២៥

១- សទ្ធា
២- សតិ
៣- ហិរិ
៤- ឱត្តប្បៈ
៥- អលោភៈ
៦- អទោសៈ
៧- តត្រមជ្ឈត្តតា
៨- កាយបស្សទ្ធិ
៩- ចិត្តបស្សទ្ធិ
១០- កាយលហុតា
១១- ចិត្តលហុតា
១២- កាយមុទុតា
១៣- ចិត្តមុទុតា
១៤- កាយកម្មញ្ញតា
១៥- ចិត្តកម្មញ្ញតា
១៦- កាយបាគុញ្ញតា
១៧- ចិត្តបាគុញ្ញតា
១៨- កាយុជុកតា
១៩- ចិត្តុជុកតា
២០- សម្មាវាចា
២១- សម្មាកម្មន្តៈ
២២- សម្មាអាជីវៈ
២៣- ករុណា
២៤- មុទិតា
២៥- បញ្ញា

9 789924 360650 >

MP Printing House
រោងពុម្ព ម៉ៅ ផុន
MAO PHON Printing House